ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដី នៅក្នុងឃុំចំណាក្រោម
# ស្រុកស្ទោង ខេត្តកំពង់ធំ
# ឆ្នាំ២០១៧ ដល់ ២០៣២





រៀបចំដោយ : ក្រុមហ៊ុនផ្ដល់សេវាកម្ម SBK R&D

សម្របសម្រួលដោយ : ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកស្ទោង

គាំទ្របច្ចេកទេសដោយ : អង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ(NIO-MLMUPC) និងថ្នាក់ខេត្ត(PIO)



ឧបត្ថម្ភថវិកាដោយ : រាជរដ្ឋាភិបាលកម្ពុជា (RGC), ADB_Loan, GAFSP_Grant និងSCF_ADB

# មាតិកា


អារម្ភកថា ........ VII

សេចក្តីផ្តើម ........ 1

ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំចំណាក្រោម ........ 3

១.១.ស្ថានភាពឃុំ ........ 3

១.១.១.ទីតាំងរដ្ឋបាលឃុំ ........ 3

១.១.២.ប្រជាសាស្ត្រ ........ 6

ក. ចំនួនប្រជាជន ........ 6

គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់ ........ 8

ឃ. របររកទទួលទាន ........ 8

ង. ចំណូលស្រុក និងចំណាកស្រុក ........ 10

១.១.៣. ស្ថានភាពសេដ្ឋកិច្ច ........ 11

ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ ........ 11

ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ ........ 11

គ. ស្ថានភាពបំណុលសរុប និងអត្រាការប្រាក់ ........ 13

១.១.៤. ស្ថានភាពសិក្សាធិការ ........ 14

ក. ស្ថានភាពអប់រំ ........ 14

ខ .ស្ថានភាពអក្ខរកម្ម ........ 16

គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត ........ 17

១.១.៥. ស្ថានភាពសុខាភិបាល ........ 17

១.១.៦. ស្ថានភាពយេនឌ័រ ........ 20

១.២. ស្ថានភាពភូមិសាស្ត្រ ........ 22

១.២.១. ទីតាំងភូមិសាស្ត្រ ........ 22

១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល) ........ 30

១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ........ 31

១.២.៤. បរិក្ខាសាធារណៈ ........ 33

ក. គ្រួសារដែលប្រើប្រាស់ថាមពលអគ្គិសនី ........ 33

ខ. ប្រព័ន្ធទឹកស្អាត ........ 33

១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន ........ 34

១.៣.១. ស្ថានភាពការកាន់កាប់ និងគ្រប់គ្រងដី ........ 34

ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ....36
ខ. ដីកសិកម្ម....37
គ. ដីព្រៃ/គម្របព្រៃ....40
ឃ. ផ្ទៃទឹក និងខ្សែទឹក....42
១.៣.២. ផលិតកម្មកសិកម្ម....44
ក. ផលិតកម្មដំណាំស្បៀង....44
ខ. ផលិតកម្មដំណាំរួមផ្សំ....46
១.៣.៣. ធនធានធម្មជាតិ....46
ក. ធនធានព្រៃឈើ....46
ខ. ធនធានជលផល....47
គ. ធនធានរ៉ែ....48
**១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល**....48
១.៤.១. ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ....48
១.៤.២. ខ្សែសង្វាក់ និងចរាចរផលិតផល....49
១.៤.៣. ឧបសគ្គ និងឱកាស....51
**ជំពូក ២ ៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត**....52
**២.១. តម្រូវការសម្រាប់អនាគត**....52
២.១.១. ផែនការអភិវឌ្ឍន៍ឃុំ....52
ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ (២០១៨ ដល់ ២០២២)....52
ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដែលបានអនុម័តរួច....60
២.១.២. ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២....61
២.១.៣. តម្រូវការដីធ្លីជាមូលដ្ឋាន....62
ក. ដីលំនៅឋាន....62
ខ. ដីកសិកម្ម....63
គ. ដីព្រៃឈើ....64
ឃ. ធនធានទឹក....64
ង. ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត....65
ង.១.វិស័យអប់រំ....65
ង.២. វិស័យសុខាភិបាល....67

ង.៣. អគ្គិសនី ......................................................................................................................67
ង.៤. ទីលានចាក់សំរាម ................................................................................................................67
ង.៥. ស្រះទឹក និងអណ្ដូងទឹក ..........................................................................................................68
២.២. តំបន់រសើប ........................................................................................................................68
**២.៣. ការប្រឈម** ........................................................................................................................70
២.៣.២. ការប្រឈមដោយ ការអនិរ័ឡនីដែលពុំមាននិរន្តរភាព ........................................................................70
**២.៤. ឱកាស** ...........................................................................................................................71
២.៤.១. ដោយអំណោយផលពីធម្មជាតិ ...................................................................................................71
២.៤.២. ដោយបច្ចេកវិទ្យាថ្មីៗ ..........................................................................................................71
២.៤.៣. ដោយគម្រោងវិនិយោគ ..........................................................................................................72
**២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ** ..........................................................................................72
**ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២** .....................................................76
**៣.១. តម្រូវការ ស្ថានភាព និងសក្ដានុពលដីជាក់ស្ដែង** ............................................................................76
៣.១.១. តម្រូវការដីទៅតាមប្រភេទ ......................................................................................................76
៣.១.២. ស្ថានភាពនៃដីធ្លី និងសក្ដានុពល ...............................................................................................76
៣.២.១. ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ ..........................................................................................77
៣.២.២. ផែនទីប្រើប្រាស់ដីអនាគត ......................................................................................................79
៣.២.៣. សេចក្ដីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត ......................................................................82
ក. ដីលំនៅឋាន ភូមិ ..................................................................................................................82
ខ. ដីស្រែវស្សា .......................................................................................................................82
គ. ស្រែប្រាំង .........................................................................................................................83
ឃ. ដីស្រែប្រាំង និងស្រែវស្សា .......................................................................................................84
ង. ព្រៃគុម្ពោត .......................................................................................................................84
ច. ព្រៃល្បោះ ........................................................................................................................85
ឆ. ព្រៃលិចទឹក .......................................................................................................................85
ជ. ស្រះទឹក ..........................................................................................................................85
ឈ. ដីបឹង ............................................................................................................................86
ញ. អាងស្តុកទឹក ......................................................................................................................86
**៣.៣. ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី** ................................................................................87

**៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព**.....87
៣.៤.១. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព.....88
ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម.....88
ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និងធនធានសំខាន់ៗផ្សេងៗទៀត.....89
៣.៤.២. គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព.....90
**៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២)**.....91

## បញ្ជីតារាង

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ.....3
តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ.....6
តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ.....7
តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម.....8
តារាង 5៖ តារាងមុខរបរ.....9
តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ.....10
តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧.....10
តារាង 8៖ ស្ថិតិប្រជាជនចំណាកស្រុក.....11
តារាង 9៖ តារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ២០១៧.....12
តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧.....15
តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ.....16
តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត.....17
តារាង 13៖ សុខភាពមាតានិងទារក.....18
តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព.....19
តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំចំណាក្រោម.....20
តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹងឃុំចំណាក្រោម ស្រុកស្ទោង.....24
តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ.....27
តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ.....30
តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន.....31
តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី.....33
តារាង 21៖ ស្ថិតិប្រភពទឹកប្រើប្រាស់.....33
តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន ឃុំចំណាក្រោម.....36
តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស.....45
តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស.....46
តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស.....47
តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស.....47

តារាង 27៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ........ 49
តារាង 28៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ទីផ្សារនិងខ្សែសង្វាក់ផលិតផល........ 51
តារាង 29៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត........ 52
តារាង 30៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)........ 61
តារាង 31៖ ចំណោលប្រជាសាស្ត្រតាមក្រុមអាយុ (០៥ឆ្នាំ)........ 62
តារាង 32៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២........ 63
តារាង 33៖ តម្រូវការដីសម្រាប់ដីកសិកម្មក្នុងឆ្នាំ២០៣២........ 63
តារាង 34៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ២០១៨ ដល់ឆ្នាំ២០៣២........ 66
តារាង 36៖ បញ្ហាប្រឈម និងសក្តានុពល (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)........ 72
តារាង 37៖ តារាងប្រើប្រាស់ដីនាពេលអនាគតឃុំចំណាក្រោម........ 78
តារាង 38៖ តារាងផែនការផ្អែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត........ 79
តារាង 39៖ តារាងផែនការផ្អែកសេវាកម្មនាពេលអនាគត........ 79

## បញ្ជីដ្យាក្រាម

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ២០១៧........ 7
ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យមគិតជាគីឡូម៉ែត្រ ពីភូមិទៅកាន់មណ្ឌលសុខភាព........ 20
ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ........ 30
ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់........ 50

## បញ្ជីផែនទី

ផែនទី 1៖ ផែនទីទីតាំងឃុំចំណាក្រោម ស្រុកស្ទោង........ 4
ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាលឃុំចំណាក្រោម........ 5
ផែនទី 3៖ ផែនទីសណ្ឋានដីឃុំចំណាក្រោម........ 23
ផែនទី 4៖ ផែនទីបង្ហាញប្រព័ន្ធគ្សេត្រ-បរិស្ថានឃុំចំណាក្រោម........ 24
ផែនទី 5៖ ផែនទីប្រព័ន្ធធារាសាស្ត្រនៅក្នុងឃុំចំណាក្រោម........ 29
ផែនទី 6៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធឃុំចំណាក្រោម........ 32
ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញក្នុងឃុំចំណាក្រោម........ 34
ផែនទី 8៖ ផែនទីប្រើប្រាស់ដីលម្អិតក្នុងឃុំចំណាក្រោម........ 35
ផែនទី 9៖ ផែនទីគម្រោងអាទិភាពឃុំចំណាក្រោម........ 60
ផែនទី 10៖ ផែនទីតំបន់រសើបឃុំចំណាក្រោម........ 69
ផែនទី 11៖ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ........ 75
ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគតក្នុងឃុំចំណាក្រោម........ 81

## បញ្ជីរូបភាព


រូបភាព 1៖ សាលារៀនបឋមសិក្សា 15
រូបភាព 2៖ មណ្ឌលសុខភាពឃុំចំណាក្រោម 19
រូបភាព 3៖ ប្រព័ន្ធធារាសាស្រ្ត 29
រូបភាព 4៖ ប្រព័ន្ធគមនាគមន៍ 31
រូបភាព 5៖ លំនៅឋាន ភូមិ 37
រូបភាព 6៖ ដីស្រែវស្សា 38
រូបភាព 7៖ ដីស្រែប្រាំង 39
រូបភាព 8៖ ដីស្រែប្រាំង និងស្រែវស្សា 40
រូបភាព 9៖ ព្រៃគុម្ពោត 41
រូបភាព 10៖ ព្រៃល្បោះ 41
រូបភាព 11៖ ព្រៃលិចទឹក 42
រូបភាព 12៖ ស្រះទឹក 43
រូបភាព 13៖ បឹង 43
រូបភាព 14៖ អាងស្តុកទឹក 44
រូបភាព 15៖ ដំណាំស្រូវ 45
រូបភាព 16៖ ផលនេសាទ 48
រូបភាព 17៖ ផលិតផលកសិកម្ម 49

# អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ គឺ ជាឧបករណ៍មួយដ៏សំខាន់ក្នុងការជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ផ្ទាល់ ក៏ដូចជាដល់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ជាពិសេសការគ្រប់គ្រងនិងប្រើប្រាស់ដី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះក្រោយពេលមានផែនការប្រើប្រាស់ដីនេះអាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់នៅក្នុងឃុំ សង្កាត់នេះទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និងការអនុម័តនៅថ្នាក់រាជធានី ខេត្ត តាមនីតិវិធីដូចដែលធ្លាប់អនុវត្តក្នុងការកសាង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច កន្លងមក ដោយមានគ្រប់ភាគីពាក់ព័ន្ធចូលរួមធ្វើការសម្រេច ។ ក្នុងទឹកចិត្តសោមនស្សរីករាយជាអនេក ខ្ញុំមានកិត្តិយសសូមបង្ហាញនូវរបាយការណ៍បច្ចេកទេសស្តីពីផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោមមានចក្ខុវិស័យរហូតដល់ឆ្នាំ២០៣២ដែលក្រុមការងារបានប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំឡើងអស់រយៈពេលជាងពីរឆ្នាំកន្លងមកនេះ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងកម្មវិធីកសិកម្មនិងសន្តិសុខស្បៀងពិភពលោក (GAFSP) ដែលបានគាំទ្រឧបត្ថម្ភថវិកា ក្រុមហ៊ុនផ្តល់សេវាកម្មមកជួយសិក្សារៀបចំផែនការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានទទួលគ្រប់គ្រងគម្រោងនិងគាំទ្របច្ចេកទេស រដ្ឋបាលខេត្តកំពង់ធំ និងរដ្ឋបាលស្រុកស្ទោង ដែលបានសម្របសម្រួលដល់កិច្ចដំណើរការរបស់គម្រោង និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនៅក្នុងដំណើរការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោមនេះ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម នេះនឹងបានចូលរួមចំណែកដល់ការអភិវឌ្ឍន៍ឃុំចំណាក្រោមប្រកបដោយចីរភាព ថែមទាំងត្រូវបានប្រើប្រាស់ដោយមានការចូលរួម និងគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ៕

ថ្ងៃ ចន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

ចំណាក្រោម ថ្ងៃទី...០៣...ខែ...សីហា...ឆ្នាំ២០២០

ប្រធានក្រុមប្រឹក្សាឃុំ

ហេង_អ៊ុនហ៊ី

# សេចក្តីផ្តើម

ស្ថិតនៅក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ដោយឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាល ដែលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាល បានបន្តធ្វើការជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ នៅក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបទៅដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជា នៅក្រោមការដឹកនាំប្រកបទៅដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជាសំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន ឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ឃុំចំណាក្រោម ជាឃុំមួយក្នុងចំណោមឃុំចំនួន១៣ ស្ថិតក្នុងស្រុកស្ទោង ខេត្តកំពង់ធំ គឺជាតំបន់ជនបទមានផ្ទៃដីសរុបចំនួន ២៣ ៦២៨ហិកតា មានព្រំប្រទល់ខាងជើងជាប់នឹង ឃុំបន្ទាយស្ទោង ឃុំចំណាលើ ស្រុកស្ទោង ខាងត្បូងជាប់នឹង ឃុំផាត់សណ្តាយ និង ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខាងកើតជាប់នឹង ឃុំសាន់គ ខាងលិចជាប់ឃុំសំព្រោជ ស្រុកស្ទោង ដែលមានប្រជាជនសរុបចំនួន ១៣ ៩១៨នាក់ ក្នុងនោះស្ត្រី ៧ ២៥៥នាក់ ហើយមានប្រជាពលរដ្ឋ ៩១,៤%ជាកសិករ ។ ឃុំចំណាក្រោមមានផ្ទៃដីស្រែសរុបទំហំ ១៤ ៩៥២,៤៨ហិកតា គឺជាផ្ទៃដីដែលមានទំហំធំទូលាយមានវិសាលភាពស្រូបអស់ ៦៣,២៦ % នៃផ្ទៃដីសរុបរបស់ឃុំ ជាបង្អែកដ៏មានសក្តានុពលតែមួយគត់សម្រាប់ការអភិវឌ្ឍន៍ឃុំចំណាក្រោមប្រកបដោយចីរភាព ។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងអភិវឌ្ឍន៍ឃុំចំណាក្រោមប្រកបដោយចីរភាពនេះ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ និងស្រុកស្ទោង ព្រមទាំងក្រុមប្រឹក្សាឃុំចំណាក្រោមក្រោមការទទួលសិទ្ធិផ្តល់សេវាកម្មរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោមដោយក្រុមហ៊ុន SBK Co.LTd និងមានការគ្រប់គ្រងគាំទ្របច្ចេកទេសដោយអង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PIO) និងអង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIO)នៃក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ព្រមទាំងមានការគាំទ្រនិងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម ចក្ខុវិស័យឆ្នាំ ២០៣២ សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍន៍ឃុំ ពាក់ព័ន្ធការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ ដើម្បីជាមូលដ្ឋានជួយដល់ក្រុមប្រឹក្សាឃុំចំណាក្រោមផ្ទាល់ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងសមធម៌ ក្នុងនោះមានការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែលជាកត្តាស្នូលនៃការអភិវឌ្ឍន៍ឃុំ ធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានភាពប្រសើរឡើងរួចផុតពីភាពក្រីក្រ ជាពិសេសនោះ ការប្រើប្រាស់ដីកសិកម្មនៅក្នុងឃុំចំណាក្រោមឱ្យអស់សក្តានុពលដែលមាន ក្នុងការផលិតស្រូវ ដើម្បីបង្កើនការនាំចេញអង្ករឱ្យបានច្រើននៅពេលខាងមុខឆ្លើយតបបានទៅនឹងគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាលដែលនៅសល់ពីការហូបចុក តាមរយៈការប្រើប្រាស់ផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោមនេះ ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ឃុំ នៅតាមអណត្តិនីមួយៗរបស់ខ្លួន ។ ផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោមត្រូវបានរៀបចំឡើង ដោយមានការសិក្សាស្រាវជ្រាវច្បាស់លាស់ លើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ និងបរិស្ថាន ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់

ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ។ ចំពោះនីតិវិធីនៃការរៀបចំផែនការនេះវិញ ត្រូវបានរៀបចំឡើងដោយផ្អែកទៅលើអនុក្រឹត្យ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ព្រមទាំងប្រកាសរួម ស្តីពីនីតិវិធីលម្អិតសម្រាប់ការរៀបចំ និងអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ និងឯកសារណែនាំអនុវត្តស្តីពីការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ/សង្កាត់ ដែលមានដំណើរការរៀបចំផែនការដូចមានសង្ខេបក្នុងដ្យាក្រាមខាងក្រោម៖

ដ្យាក្រាម៖ ដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីនៅក្នុងឃុំ សង្កាត់




សម្គាល់៖ ប្រអប់បង្ហាញទំហំការងារដែលត្រូវអនុវត្តតាមឯកសារណែនាំ

# ជំពូក ១៖ ព័ត៌មានស្តីពីស្ថានភាពឃុំចំណាក្រោម

## ១.១.ស្ថានភាពឃុំ

ឃុំចំណាក្រោម មានរឿងរ៉ាវដំណាលតៗគ្នាមកថា កាលដើមឡើយនៅលើទីតាំងនេះមានលោមេស្រុកម្នាក់គាត់ឈ្មោះ ខុង បានមករស់នៅក្នុងភូមិមួយដែលមានឈ្មោះថា ភូមិចំណារ ដែលក្រោយមកមានមនុស្សមកតាំងទីលំនៅនៅលើទីតាំងនេះបន្តិចម្តងៗរហូតបង្កើតជាឃុំហើយត្រូវបានគេនាំគ្នាដាក់ឈ្មោះថា " **ឃុំចំណារ**" ។ អំណើះតមកដល់រៀងពេលបច្ចុប្បន្ននេះ ឃុំចំណារនេះក៏បានកែប្រែឈ្មោះជា " **ឃុំចំណាក្រោម**" វិញតាមប្រកាសរបស់ក្រសួងមហាផ្ទៃលេខ៤៩៣ប្រ.ក ចុះថ្ងៃទី ៣០ មេសា ២០០១។

### ១.១.១.ទីតាំងរដ្ឋបាលឃុំ

ឃុំចំណាក្រោម គឺជាឃុំមួយដែលស្ថិតនៅភាគអាគ្នេយ៍ និងមានចម្ងាយប្រហែល ៨គីឡូម៉ែត្រ ពីរួមស្រុក ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលស្រុកស្ទោង ខេត្តកំពង់ធំ មានផ្ទៃដីសរុបចំនួន ២៣ ៦២៨ហិកតា (ប្រភពទិន្នន័យ៖ ក្រុមការងារ GIS អេស ប៊ី ខេ) និងមានព្រំប្រទល់ជាប់នឹង៖

- ខាងជើង ជាប់នឹងឃុំបន្ទាយស្ទោង ឃុំចំណាលើ ស្រុកស្ទោង
- ខាងកើត ជាប់នឹង ឃុំសាន់គ និងឃុំកំពង់គោ ស្រុកកំពង់ស្វាយ
- ខាងត្បូង ជាប់នឹងឃុំផាត់សណ្តាយ និងឃុំកំពង់គោ ស្រុកកំពង់ស្វាយ
- ខាងលិច ជាប់នឹងឃុំសំព្រោជ ស្រុកស្ទោង (ភ្ជាប់ជាមួយផែនទីរដ្ឋបាលឃុំ)។

ឃុំនេះមានចំនួន ១០ភូមិ គឺភូមិព្រះនង្គ័ល ភូមិសំព័រ ភូមិស្រីរងិត ភូមិស្វាយអៀ ភូមិនាងនយ ភូមិសណ្តាន់ ភូមិស្ពានគ្រង ភូមិជីអាប់ ភូមិចំណាក់ និងភូមិលៀប ។

តារាង 1៖ ស្ថានភាពទូទៅនៃឃុំ

| **ខេត្ត** | កំពង់ធំ | លេខកូដខេត្តៈ៦ |
|---|---|---|
| **ស្រុក** | ស្ទោង | លេខកូដស្រុកៈ ៦០៨ |
| **ឃុំ** | ចំណាក្រោម | លេខកូដឃុំៈ ៦០៨០២ |
| ចំនួន១០ភូមិ | ១. ភូមិព្រះនង្គ័ល | លេខកូដភូមិៈ ៦០៨០២០១ |
| | ២. ភូមិសំព័រ | លេខកូដភូមិៈ ៦០៨០២០២ |
| | ៣. ភូមិស្រីរងិត | លេខកូដភូមិៈ ៦០៨០២០៣ |
| | ៤. ភូមិស្វាយអៀ | លេខកូដភូមិៈ ៦០៨០២០៤ |
| | ៥. ភូមិនាងនយ | លេខកូដភូមិៈ ៦០៨០២០៥ |
| | ៦. ភូមិសណ្តាន់ | លេខកូដភូមិៈ ៦០៨០២០៦ |
| | ៧. ភូមិស្ពានគ្រង | លេខកូដភូមិៈ ៦០៨០២០៧ |
| | ៨. ភូមិជីអាប់ | លេខកូដភូមិៈ ៦០៨០២០៨ |
| | ៩. ភូមិចំណាក់ | លេខកូដភូមិៈ ៦០៨០២០៩ |
| | ១០. ភូមិលៀប | លេខកូដភូមិៈ ៦០៨០២១០ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

ផែនទី 1៖ ផែនទីទីតាំងឃុំចំណាក្រោម ស្រុកស្ទោង



ផែនទី 2៖ ផែនទីព្រំប្រទល់រដ្ឋបាលឃុំចំណាក្រោម



## ១.១.២.ប្រជាសាស្ត្រ

### ក. ចំនួនប្រជាជន

នៅក្នុងឃុំចំណាក្រោម មានចំនួន ១០ភូមិ ដែលមានគ្រួសារសរុបចំនួន ២ ៨២៨ គ្រួសារ មានប្រជាជនសរុប ១៣ ៩១៨នាក់ ក្នុងនោះស្ត្រី ៧ ២៥៥នាក់ ហើយប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើង មានចំនួន ៨ ០៧៥នាក់ ក្នុងនោះដែរស្ត្រីមានចំនួន ៤២៥៨នាក់ ។ នៅក្នុងឃុំនេះភូមិដែលមានប្រជាជនច្រើនជាងគេ គឺភូមិស្ពានគ្រង ដែលមានគ្រួសារសរុបចំនួន ៤៨៩ គ្រួសារ ស្មើនឹង ១៧,៣ ភាគរយ និងមានប្រជានជនសរុបចំនួន ២ ៣២៧នាក់ នៅក្នុងស្ត្រីមានចំនួន ១ ២០០នាក់ ហើយប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ១ ៤១៧នាក់ ក្នុងនោះស្ត្រីមានចំនួន ៧២៧នាក់ ចំណែកឯភូមិដែលមានប្រជាជនតិចជាងគេ គឺភូមិលៀបមានចំនួន ៧៨គ្រួសារ ស្មើនឹង ២,៨ភាគរយ មានប្រជាជនសរុបចំនួន ៣៦៣នាក់ ស្ត្រីចំនួន ១៨១នាក់ ហើយប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានចំនួន ២១៤នាក់ ក្នុងនោះស្ត្រីមានចំនួន ១០៤នាក់ ។

តារាង 2៖ ទិន្នន័យគ្រួសារ និងចំនួនប្រជាជនតាមបណ្តាភូមិ

| ឈ្មោះភូមិ | គ្រួសារ | គិតជា% | មនុស្ស | | | ១៨ឆ្នាំឡើង | | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ព្រះនង្គ័ល | ៣៦៩ | ១៣,០ | ១ ៧៨៧ | ៩១៥ | ៨៧២ | ១១២៧ | ៥៤៦ | ៥៨១ |
| សំព័រ | ៣៣៣ | ១១,៨ | ១ ៥៩២ | ៧៧៥ | ៨១៧ | ៨០៦ | ៣៩២ | ៤១៤ |
| ស្រីរងឹត | ២២៦ | ៨,០ | ១ ១២២ | ៥៦២ | ៥៦០ | ៦៣៣ | ៣៣២ | ៣០១ |
| ស្វាយអៀ | ២៧៣ | ៩,៧ | ១ ៣៣១ | ៦៨៤ | ៦៤៧ | ៨១១ | ៤១៦ | ៣៩៥ |
| នាងនយ | ២២៨ | ៨,១ | ១ ០៣៦ | ៤៩៧ | ៥៣៩ | ៦៤៤ | ៣២៦ | ៣១៨ |
| សណ្តាន់ | ២៣៧ | ៨,៤ | ១ ៣៣២ | ៥៦៣ | ៧៦៩ | ៥៦៥ | ២១៧ | ៣៤៨ |
| ស្ពានគ្រង | ៤៨៩ | ១៧,៣ | ២ ៣២៧ | ១១២៧ | ១ ២០០ | ១ ៤១៧ | ៦៩០ | ៧២៧ |
| ជីអាប់ | ៣១៨ | ១១,២ | ១ ៧៣៣ | ៧២៦ | ១ ០០៧ | ១ ១២៤ | ៤២៩ | ៦៩៥ |
| ចំណាក់ | ២៧៧ | ៩,៨ | ១២៩៥ | ៦៣២ | ៦៦៣ | ៧៣៤ | ៣៥៩ | ៣៧៥ |
| លៀប | ៧៨ | ២,៨ | ៣៦៣ | ១៨២ | ១៨១ | ២១៤ | ១១០ | ១០៤ |
| **សរុប** | **២ ៨២៨** | **១០០** | **១៣ ៩១៨** | **៦ ៦៦៣** | **៧ ២៥៥** | **៨ ០៧៥** | **៣ ៨១៧** | **៤ ២៥៨** |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

ដ្យាក្រាម 1៖ ស្ថិតិប្រជាជនឆ្នាំ២០១៧




ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

បើយោងតាមតារាងស្ថិតិប្រជាជនតាមក្រុមអាយុនៅឆ្នាំ២០១៧ ក្នុងឃុំចំណាក្រោម ដែលមានអាយុចាប់ 0ឆ្នាំដល់អាយុ៦១ឆ្នាំបង្ហាញឲ្យឃើញថា មានចំនួនសរុបចំនួន ១៣ ៩១៨នាក់ មានស្ត្រីចំនួន ៩៨២នាក់ ក្នុងនោះ ប្រជាជនដែលមានអាយុចាប់ពី ២៥ដល់៦៥ឆ្នាំមានចំនួន ៦ ៣៧៤នាក់ គឺប្រហាក់ប្រហែលនឹង ៤៦ភាគរយ ជិតពាក់កណ្ដាលនៃប្រជាពលរដ្ឋសរុប ដែលជាមនុស្សពេញកម្លាំងពលកម្ម ក្រៅពីនេះអាយុពីកើតដល់អាយុ ២៤ឆ្នាំ មានចំនួន ៧ ៥៤៤នាក់ ស្មើនឹង ៥៤ភាគរយ និងប្រជាពលរដ្ឋមានអាយុពី៦១ឆ្នាំឡើងមានចំនួន ១ 0៧0នាក់ ស្មើនឹង ៨ ភាគរយ ដូចមានរៀបចំសង្ខេបក្នុងតារាងខាងក្រោម ។ ដូច្នេះឃើញថាអ្នកពេញកម្លាំងពលកម្មពលកម្ម មួយនាក់រកចំណូលបានជាមធ្យមត្រូវចិញ្ចឹមបន្ថែមមួយនាក់ទៀតលើសបន្តិច ។

តារាង 3៖ ស្ថិតិប្រជាជន ឆ្នាំ២០១៧ តាមក្រុមអាយុ

| **តាមក្រុមអាយុ** | **២០១៧** | | | **ផ្សេងៗ** |
|---|---|---|---|---|
| | **សរុប** | **ប្រុស** | **ស្រី** | |
| អាយុពី0-២ឆ្នាំ | ៦៣៦ | ៣២៥ | ៣១១ | កុមារ |
| អាយុពី៣-៤ | ៧៣៨ | ៣៧៣ | ៣៦៥ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៥ឆ្នាំ | ៥៧៧ | ២៧៦ | ៣0១ | អាយុចូលរៀនសាលាមត្តេយ្យ |
| អាយុពី៦ឆ្នាំ | ៦៤៦ | ៣0៦ | ៣៤0 | អាយុចូលរៀនសាលាបឋម |
| អាយុពី៧-១១ឆ្នាំ | ១២0៩ | ៦៣១ | ៥៧៨ | អាយុចូលរៀនសាលាបឋម |
| អាយុពី១២-១៤ឆ្នាំ | ១0២៥ | ៤៨២ | ៥៤៣ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី១៥-១៧ឆ្នាំ | ១0១២ | ៤៥៣ | ៥៥៩ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី១៨-២៤ឆ្នាំ | ១៧0១ | ៨0៣ | ៨៩៨ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី២៥-៣៥ឆ្នាំ | ១៩៥៤ | ៩៨២ | ៩៧២ | អាយុពេញពលកម្ម |
| អាយុពី៣៦-៤៥ឆ្នាំ | ១៥៣៨ | ៧៦៣ | ៧៧៥ | អាយុពេញពលកម្ម |
| អាយុពី៤៦-៦0ឆ្នាំ | ១៨១២ | ៧៤0 | ១0៧២ | អាយុពេញពលកម្ម |
| អាយុពី៦១ឆ្នាំឡើង | ១0៧0 | ៥២៩ | ៥៤១ | អាយុចូលនិវត្តន៍ |
| **សរុប** | **១៣ ៩១៨** | **៦ ៦៦៣** | **៧ ២៥៥** | |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

### ខ. អត្រាកំណើន ដង់ស៊ីតេ និងបម្លាយប្រជាជន

ដោយយោងទៅតាមអត្រាកំណើនគ្រួសារ និងប្រជាជនពីចន្លោះឆ្នាំ២០១៣ដល់ឆ្នាំ២០១៧ បង្ហាញឲ្យឃើញថា អត្រាកំណើនប្រជាជននៅក្នុងឃុំចំណាក្រោម អត្រាកំណើននេះមានកើនឡើងខ្ពស់នៅឆ្នាំ ២០១៧ ដែលមានអត្រាកំណើនប្រជាជនមានចំនួន ៣,៣៨ភាគរយ ដែលមានប្រជាជនចំនួន ១៣៩១៨នាក់ មូលហេតុនៃការកើនឡើងនេះដោយសារ កម្រិតជីវភាពល្អប្រសើរ ចំណូលស្រុក អត្រាកំណើតច្រើន អត្រាមរណៈទាប ។ ហើយនៅក្នុងនោះអត្រាកំណើនគ្រួសារជាមធ្យម ៧២គ្រួសារ/ឆ្នាំ និងចំនួនអត្រាកំណើនប្រជាជនជាមធ្យម ៣៥៣នាក់/ឆ្នាំ។ តាមការស្រាវជ្រាវបានបង្ហាញថា គ្រួសារខ្លះបានយល់ដឹងពីកម្មវិធីពន្យាកំណើតជាបណ្តើរៗ ។ នៅក្នុងឃុំចំណាក្រោមមានដង់ស៊ីតេប្រជាជនជាមធ្យម ២៣៦នាក់/គ.ម² ។ ប្រជាជនភាគច្រើនចូលចិត្តរស់នៅជាលក្ខណៈប្រមូលផ្តុំគ្នានៅតាមដងផ្លូវ ឬតាមទីប្រជុំជន ជាពិសេសនៅតាមបណ្តោយផ្លូវជាតិលេខ៦ និងផ្លូវសំខាន់ៗនៅក្នុងឃុំ ។

តារាង 4៖ ស្ថិតិប្រជាជនតាមបណ្តាឆ្នាំ និងការគណនាអត្រាកំណើនមធ្យម

| ចំនួន | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | កំណើនមធ្យម (%) |
|---|---|---|---|---|---|---|
| ចំនួនប្រជាជនសរុប | ១២ ៩៥៨ | ១៣ ១០១ | ១៣ ៣២២ | ១៣ ៤៦៣ | ១៣ ៩១៨ | |
| កំណើនមធ្យម(%) | ៥,៤៤ | ១,១០ | ១,៦៩ | ១,០៦ | ៣,៣៨ | ២,៥៣% |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

**☛ចំណាំ**

- អត្រាកំណើនសម្រាប់ចន្លោះឆ្នាំនីមួយៗ៖ (ឆ្នាំចុងក្រោយ-ឆ្នាំដំបូង)x១០០/ឆ្នាំដំបូង
- អត្រាកំណើនមធ្យមប្រចាំឆ្នាំ៖ (បូកសរុបអត្រាកំណើនតាមឆ្នាំនិមួយ/ចំនួនឆ្នាំ)

### គ. ជនជាតិ ជំនឿសាសនា ប្រពៃណី ទំនៀមទម្លាប់

នៅក្នុងឃុំចំណាក្រោមមានជនជាតិខ្មែរ និងខ្មែរកាត់ចិន ហើយភាគច្រើនកាន់សាសនាព្រះពុទ្ធ និងចំនួនតិចតួចកាន់សាសនាគ្រិស្ត ហើយប្រជាជនភាគច្រើននៅក្នុងឃុំគោរពប្រពៃណីនិងទំនៀមទម្លាប់បែបខ្មែរ ដូចជា ពិធីរៀបមង្គលការប្រារព្ធពីធីបុណ្យទាននៅតាមវត្តអារាមនិង និមន្តព្រះសង្ឃសូត្រមន្តតាមផ្ទះ ពិធីបូជាសព និងមួយចំនួនតិចមានទំនៀមទម្លាប់បែបចិន ដូចជាពិធីសែនព្រេនដូនតា ពីធីបញ្ចុះសព និងភាគតិចបំផុតមានទំនៀមទម្លាប់បែបសាសនាគ្រិស្ត ដូចជា មានប្រារព្ធពិធីចូលព្រះវិហារគ្រឹស្តនៅរៀងរាល់ថ្ងៃអាទិត្យជាដើម។ល។ និយាយរួមប្រជាជនក្នុងឃុំតែងតែប្រារព្ធពិធីបុណ្យទានតាមប្រពៃណីទំនៀមទំលាប់ពីបុរាណរៀងមកតាមជំនឿបែបខ្មែរ បែបចិន និងបែបគ្រឹស្តសាសនា ។

### ឃ. របររកទទួលទាន

នៅឃុំចំណាក្រោម មានប្រជាជនប្រកបមុខរបរកសិកម្មជាចម្បង មានចំនួន ៥ ៦៣៥នាក់ ស្មើនឹង ៩១,៤ភាគរយ ហើយនៅក្នុងនោះអ្នកដែលមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្មមានចំនួន ២ ១១៨នាក់ ស្មើនឹង ៧៨,៣ភាគរយ ចំណែកអ្នកដែលប្រកបមុខរបរសិប្បកម្មមិនមាននោះទេ និងអ្នកមានមុខរបរចម្បងផ្នែកសេវាកម្មចំនួន ៥៣៣នាក់ ស្មើនឹង ៨,៦ភាគរយ ហើយបន្ទាប់បន្សំផ្នែកនេះមានចំនួន ២១,៧ភាគរយ មុខរបរទាំងអស់នោះមានដូចជា៖ នេសាទត្រី ធ្វើស្រែ ចិញ្ចឹមសត្វ ចិញ្ចឹមក្រពើ ឡើងត្នោត ដាំដំណាំបន្លែ កម្មករសំណង់ ស៊ីឈ្នួល

ដកស្ទូងតិចតួច លក់ដូរ(បបរនំបញ្ចុក ចេក ចៀន) ជាងចម្លាក់ ជាងទង ជាងជួសជុលកង់ម៉ូតូ រថយន្ត ជាងកាត់ដេរ ជាងកាត់សក់ ជាមន្ត្រី រាជការ អាជីវកលក់ដូរ ធ្វើការជាមួយវិស័យឯកជន និងអង្គការនានា ហើយភាគច្រើនមានជំនាញច្បាស់លាស់ ។

តារាង 5៖ តារាងមុខរបរ

| បរិយាយ | | ២០១៧ |
|---|---|---|
| សរុបអ្នកមានមុខរបរចម្បង | | ៦ ៣៧៥នាក់ |
| %សរុបអ្នកមានមុខរបរចម្បង | | ៩១,0% |
| %ស្រីមានមុខរបរចម្បង(គិតក្នុងស្រី១៨-៦០ឆ្នាំ) | | ៧៧,២% |
| %ប្រុសមានមុខរបរចម្បង(គិតក្នុងប្រុស១៨-៦០ឆ្នាំ) | | ៨០,៩% |
| **សរុបអ្នកមានមុខរបរចម្បងក្នុងផ្នែកកសិកម្ម** | | **៥ ៥៤៧%** |
| **%អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម(គិតក្នុងមុខរបរចម្បង)** | | **៨៧,0%** |
| **%ស្រីមានមុខរបរចម្បងផ្នែកកសិកម្ម(គិតក្នុងមុខរបរចម្បង)** | | **៤៥,៣%** |
| ក្នុងនោះ | %អ្នកមានមុខរបរធ្វើស្រែ | ៨៣,៩% |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលវែង | 0,0% |
| | %អ្នកមានមុខរបរដាំដំណាំចម្ការរយៈពេលខ្លី | 0,២% |
| | %អ្នកមានមុខរបរដាំដំណាំបន្លែ | 0,១% |
| | %អ្នកមានមុខរបរនេសាទ | ២,១% |
| | %អ្នកមានមុខរបរចិញ្ចឹមសត្វ | 0,៨% |
| | %អ្នកមានមុខរបរពីអនុផលព្រៃឈើ | 0,0% |
| **សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសិប្បកម្ម** | | **0នាក់** |
| **%អ្នកបម្រើការងារក្នុងផ្នែកសិប្បកម្ម** | | **0,0%** |
| **សរុបអ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **៨២៨នាក់** |
| **%អ្នកបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **១៣%** |
| **%ស្រីបម្រើការងារ(មុខរបរចម្បង) ក្នុងផ្នែកសេវាកម្ម** | | **៦,៣%** |
| ក្នុងនោះ | %អ្នកបម្រើការងារលក់ដូរ និងជំនួញ | 0,៦% |
| | %អ្នកបម្រើការងារជាជាងជួសជុល | 0,២% |
| | %អ្នកបម្រើការងារក្នុងផ្នែកដឹកជញ្ជូន | 0,0% |
| | %អ្នកបម្រើការងារស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ | ៣,១% |
| | %អ្នកបម្រើការងារក្នុងវិស័យឯកជន(កម្មកររោងចក្រ បុគ្គលិកអង្គការ) | ៨,៧% |
| | %អ្នកបម្រើការងារជាមន្ត្រីរាជការ | 0,៤% |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

ប្រជាពលរដ្ឋនៅក្នុងឃុំចំណាក្រោម បានបង្កើតមុខរបរបន្ទាប់បន្សំបន្ថែមទៀត ក្រៅពីមុខរបរចម្បង ដើម្បីទ្រទ្រង់ជីវភាពក្នុងគ្រួសារឲ្យកាន់តែប្រសើរឡើង យោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ២០១៧ បានបង្ហាញឲ្យ

ឃើញថា ប្រជាជនមានមុខរបរបន្ទាប់បន្សំផ្នែកសិកម្មមាន ២ ៥៨២នាក់ ស្មើនឹង ៨២,៣ ភាគរយ ដែលក្នុងនោះមានស្រ្តីចំនួន ១ ២៦១នាក់ ស្មើនឹង ៤០,២ភាគរយ និងអ្នកដែលមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្មមានចំនួន ១៧,៧ភាគរយ ក្នុងនោះមានស្រី ៩,៧ភាគរយ ។

ដូច្នេះតាមពត៌មានខាងលើបានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋនៅក្នុងឃុំចំណាក្រោមក្រៅពីប្រកបរបរធ្វើស្រែជាចម្បង មានប្រជាពលរដ្ឋមួយចំនួនប្រមាណជិតពាក់កណ្តាលបានខិតខំប្រកបរបរទទួលទានបន្ទាប់បន្សំថែមទៀត ដូចជា លក់ដូរនិងជំនួញ ផ្នែកដឹកជញ្ជូន និង កម្មករសំណង់។ល។ ចំណែកអ្នកមានរបរផ្នែកសេវាកម្មជាចម្បងមានស្ទើរតែទាំងអស់បានខិតខំប្រកបរបរកសិកម្មដែលជាមុខរបរបន្ទាប់បន្សំបន្ថែមទៀតផងដែរ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោមនេះ៖

តារាង 6៖ តារាងមុខរបរបន្ទាប់បន្សំ

| បរិយាយ | ២០១៧ | ២០១៧ ចំនួន(នាក់) |
|---|---|---|
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៨២,៣% | ២ ៥៨២នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកកសិកម្ម | ៤០,២% | ១ ២៦១នាក់ |
| %អ្នកមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ១៧,៧% | ០នាក់ |
| %ស្រីមានមុខរបរបន្ទាប់បន្សំផ្នែកសេវាកម្ម | ៩,៧% | ៣០៣នាក់ |

### ង. ចំណូលស្រុក និងចំណាកស្រុក

កត្តាដែលធ្វើឲ្យមានការផ្លាស់ប្តូរលំនៅឋាន គឺដោយសារនៅភូមិចាស់ដែលគាត់បានរស់នៅពិបាកក្នុងការរកស៊ី និងគ្មានការងារធ្វើនៅក្នុងភូមិ ព្រមទាំងមូលហេតុមួយចំនួនទៀត ដូចជា ៖ ស្ថានភាពដី នៅក្នុងមូលដ្ឋានមួយចំនួនមានការប្រែប្រួលដោយដីខូច ងាប់សារជាតុបំរុង ហើយឡើងខ្សោះ ឬហិរជាដើម ខ្វះប្រភពទឹកធ្វើអោយទទួលបានទិន្នផលទាប តម្លៃផលិតផលកសិកម្មមិនទៀងទាត់និងគ្មានទីផ្សារផលិតផល ចំណែកសមាជិកគ្រួសារកើនឡើង និងមួយចំនួនជាប់បំណុលធនាគារនិងមីក្រូហិរញ្ញវត្ថុជាដើម។ល។ ការផ្លាស់ប្តូរលំនៅឋានប្រជាពលរដ្ឋមួយចំនួនទៅរស់នៅទីប្រជុំជនឃុំ/សង្កាត់ ស្រុក/ក្រុង រាជធានី/ខេត្ត និងធ្វើការងារនៅប្រទេសផ្សេងៗ ។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកគ្រប់ប្រភេទ ក្នុងគោលបំណងលើកស្ទួយតម្លៃសេដ្ឋកិច្ចគ្រួសារ ។ តាមរបាយការណ៍របស់រដ្ឋបាលឃុំ នៅក្នុងឃុំចំណាក្រោម គ្រួសារផ្លាស់លំនៅឋានចូលមានចំនួន៤១គ្រួសារ ក្នុងនោះមនុស្សសរុបមានចំនួន ៤១នាក់ ស្រីចំនួន ២១នាក់ និងគ្រួសារផ្លាស់លំនៅឋានចេញមានចំនួន ៦៣គ្រួសារ មនុស្សសរុបមានចំនួន ៦៣នាក់ ស្រីមានចំនួន ២៧នាក់ ។

តារាង 7៖ ស្ថិតិប្រជាជនផ្លាស់ប្តូរទីលំនៅក្នុងឆ្នាំ២០១៦-២០១៧

| ល.រ | បរិយាយ | ចំនួនគ្រួសារ | ចំនួនប្រជាជនសរុប | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | ចំនួនគ្រួសារផ្លាស់លំនៅឋានចូល | ៤១ | ៤១ | ២១ |
| ២ | ចំនួនគ្រួសារផ្លាស់លំនៅឋានចេញ | ៦៣ | ៦៣ | ២៧ |

ប្រភពទិន្នន័យ៖ *ក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

បើដោយយោងតាមទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ២០១៧ ប្រជាជនក្នុងឃុំចំណាក្រោមមួយចំនួនបានធ្វើចំណាកស្រុកចេញទៅរកស៊ីនៅស្រុកផ្សេងៗ ឬទៅប្រទេសជិតខាងដូចជា៖ ថៃ ជប៉ុន និងកូរ៉េជាដើម។ នៅក្នុងឃុំចំណាក្រោមទាំងមូលមានប្រជាពលរដ្ឋធ្វើចំណាកស្រុកចំនួន ១ ៧៨២នាក់ ស្រីចំនួន ៩១៩នាក់ នៅក្នុងនោះចំនួនអ្នកធ្វើ ចំណាកស្រុកក្នុងប្រទេសមានចំនួន ១ ២០០នាក់ ស្រីមានចំនួន ៦៨៤នាក់ និងចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេសមាន ៥៨២នាក់ ស្រីចំនួន ២៣៥នាក់ ហើយកត្តាដែលបណ្តាលឲ្យមានចំណាកស្រុកបែបនេះដោយសារ៖

- ដីបង្កបង្កើនផលសម្រាប់វិស័យកសិកម្មតិចតួច ធ្វើស្រែបានផលតិច
- ការធ្វើស្រែចម្ការបានតែមួយរដូវ និងគ្មានទីផ្សារគ្រប់គ្រាន់សម្រាប់លក់ផលិតផល
- មិនមានការងារគ្រប់គ្រាន់នៅក្នុងស្រុក
- ជំពាក់បំណុលធនាគារ ឬឯកជនមិនមានលទ្ធភាពសង
- គ្មានមុខរបរច្បាស់លាស់ និងមានប្រាក់ចំណូលប្រចាំថ្ងៃទាប។
- កំណើនសមាជិកគ្រួសារមានមានការកើនឡើង។
- ដោយធ្វើស្រែប្រើឧបករណ៍ពាក់កណ្តាលស្វ័យប្រវត្តិធ្វើឲ្យកម្លាំងពលកម្មថយចុះ។
- គ្រួសារមានដីតិចតួច មិនគ្រប់គ្រាន់ក្នុងការចិញ្ចឹមគ្រួសារ បន្ទាប់មកលក់ចេញទៅស្រុកផ្សេង។

តារាង ៩៖ ស្ថិតិប្រជាជនចំណាកស្រុក

| បរិយាយ | ២០១៦ | | | ២០១៧ | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ចំនួនអ្នកធ្វើចំណាកស្រុកក្នុងប្រទេស | ៧២៣ | ២៥០ | ៤៧៣ | ១ ២០០ | ៥១៦ | ៦៨៤ |
| ចំនួនអ្នកធ្វើចំណាកស្រុកក្រៅប្រទេស | ៥៨២ | ៣៥១ | ២៣១ | ៥៨២ | ៣៤៧ | ២៣៥ |
| **សរុប** | **១ ៣០៥** | **៦០១** | **៧០៤** | **១ ៧៨២** | **៨៦៣** | **៩១៩** |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

### ១.១.៣. ស្ថានភាពសេដ្ឋកិច្ច

#### ក. ប្រភពចំណូលចម្បង និងបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋ

បើយោងតាមរបាយការណ៍ ស្តីពីការវិភាគប្រព័ន្ធអេកូឡូស៊ីបរិស្ថាន នៅត្រង់ចំណុចនៃការវិភាគចំណាត់ថ្នាក់ទ្រព្យធនបានឱ្យដឹងថា គ្រួសារដែលមានជីវភាពគ្រាន់បើ មធ្យម និងក្រ មានប្រភពចំណូលដូចគ្នា គឺមានប្រភពចំណូលទី១ គឺស្រូវ ប្រភពចំណូលទី២ គឺចំណាកស្រុកទៅភ្នំពេញ និងថៃ និងប្រភពចំណូលទី៣ គឺលក់ដូរ។ ចំណែកគ្រួសារមានជីវភាពក្រណាស់មានប្រភពចំណូលតែមួយគត់គឺលក់កម្លាំងពលកម្ម។

#### ខ. កម្រិតជីវភាពរស់នៅ ចំណូល ចំណាយប្រចាំថ្ងៃ ប្រចាំឆ្នាំ

បើយោងទៅតាមរបាយការណ៍ CAEA ឆ្នាំ២០១៧ បានធ្វើចំណាត់ថ្នាក់ធនធានជា ៤ចំណាត់ថ្នាក់មានដូចជា៖ គ្រួសារដែលមានជីវភាពបង្គួរ ឬគ្រាន់បើមានចំនួន ១៨៦គ្រួសារ ស្មើនឹង ៦,៥៤ភាគរយ ទូទាំងឃុំ ហើយគ្រួសារក្រមធ្យមចំនួន ២ ០៦៤គ្រួសារ ស្មើនឹង ៧២,៦ភាគរយ និងគ្រួសារក្រមានចំនួន ៣២៩គ្រួសារ ស្មើនឹង ១១,៥៧% ហើយគ្រួសារក្រណាស់/គ្មានដីមានចំនួន ២៦៤គ្រួសារ ស្មើនឹង ៩,២៣ភាគរយ នៃប្រជាជនទូទាំងឃុំ

ប្រជាពលរដ្ឋនៅក្នុងឃុំនេះមានចំណូលប្រចាំថ្ងៃចាប់ពី ២៥ ០០០ ទៅ ៣០ ០០០រៀល/គ្រួសារ និងប្រចាំឆ្នាំចាប់ពី ៩ ១២៥ ០០០ ទៅ ១០ ៩៥០ ០០០រៀល/គ្រួសារ ចំណែកការចំណាយប្រចាំឆ្នាំមានដូចជា៖ ស្បៀងអាហារ សម្លៀកបំពាក់ ឧបករណ៍ប្រើប្រាស់សម្ភារសិក្សា និងថ្នាំសង្កូវ ព្រមទាំងចំណាយផ្សេងៗចាប់ពី ៣ ៦៥០ ០០០ ទៅ ៥ ៤៧៥ ០០០រៀល/គ្រួសារ ។

តារាង ១៖ តារាងចំណាត់ថ្នាក់ទ្រព្យធននៅក្នុងឆ្នាំ២០១៧

| ចំណាត់ថ្នាក់ធនធាន | បង្គួរ/គ្រាន់បើ | មធ្យម | ក្រ | ក្រណាស់/គ្មានដី | សរុប |
|---|---|---|---|---|---|
| តំបន់ទី I | ៦,៥៤% | ៧២,៦% | ១១,៥៧% | ៩,២៣% | ១00% |
| ទូទាំងឃុំ | ៦,៥៤% | ៧២,៦% | ១១,៥៧% | ៩,២៣% | ១00% |
| ចំនួនគ្រួសារ | ១៨៦ | ២ ០៦៤ | ៣២៩ | ២៦៤ | ២ ៨៤៣ |
| ទំហំគ្រួសារ | ៥នាក់/គ្រួសារ | ៥នាក់/គ្រួសារ | ៥នាក់/គ្រួសារ | ៥នាក់/គ្រួសារ | |
| កម្លាំងពលកម្ម | ៣នាក់/គ្រួសារ | ៣នាក់/គ្រួសារ | ២នាក់/គ្រួសារ | ២នាក់/គ្រួសារ | |
| ទំហំដីកាន់កាប់សរុប(Ha) | ៥ | ២,៥ | 0,៥ | 0,១៥ | |
| ចំនួន ប្រភេទក្បាលដី | ៤ | ៣ | ២ | ១ | |
| ដីលំនៅឋាន(Ha) | 0,២0 | 0,១៥ | 0,១0 | 0,0២ | |
| ដីស្រែ(Ha) | ៤,៨0 | ២,៣៥ | 0,៤0 | 0,00 | |
| ដីដាំបន្លែ(Ha) | មានតិចតួច | មានតិចតួច | មានតិចតួច | មានតិចតួច | |
| ប្រភេទពូជស្រូវដាំដុះ | ៨៥ ៥៤៥១ សែនក្រអូប ផ្ការំដួល នាងគង់ | ៨៥ ៥៤៥១ សែនក្រអូប ផ្ការំដួល នាងគង់ | ៨៥ ៥៤៥១ សែនក្រអូប ផ្ការំដួល នាងគង់ | គ្មាន | |
| ដំណាំទី១៖ស្រូវ(Ha) | ៤,៨0 | ២,៣៥ | 0,៤0 | 0,00 | |
| ដំណាំទី២៖បន្លែ(Ha) | មានតិចតួច | មានតិចតួច | មានតិចតួច | មានតិចតួច | |
| ការចិញ្ចឹមត្រីគ្រួសារ | មានតិចតួច | មានតិចតួច | គ្មាន | គ្មាន | |
| ចំនួនគោក្បាល/គ្រួសារ | ៣ | ៣ | ១ | គ្មាន | |
| ចំនួនក្របីក្បាល/គ្រួសារ | ១ | ១ | ១ | គ្មាន | |
| ចំនួនជ្រូក | មិនទាន់ច្បាស់ | មិនទាន់ច្បាស់ | មិនទាន់ច្បាស់ | មិនទាន់ច្បាស់ | |
| ការប្រើប្រាស់ | សាច់រ៉ាយ | សាច់រ៉ាយ ឆក | បង់សំណាញ់ | សន្ទូច | |

| | | | | | |
|---|---|---|---|---|---|
| ឧបករណ៍នេសាទ | ប្រើស១០០ ឆ្នុក | ប្រើស១០០ ឆ្នុក មង លន់ សំណាញ់ ទ្រូ សន្ទូច ឈឺប សាបត្រី...... | ឆក ទ្រូ ចង សន្ទូច អួស ឈឺប លន់ មង ដាក់បត្រី... | ទ្រូ បាច | |
| ប្រភពចំណូលទី១៖ | ដំណាំស្រូវ | ដំណាំស្រូវ | ដំណាំស្រូវ | កម្លាំង ពលកម្ម | |
| ប្រភពចំណូលទី២៖ | ចំណាកស្រុក (ភ្នំពេញ និង ប្រទេសថៃ) | ចំណាកស្រុក (ភ្នំពេញ និង ប្រទេសថៃ) | ចំណាកស្រុក (ភ្នំពេញ និង ប្រទេសថៃ) | កម្លាំង ពលកម្ម | |
| ប្រភពចំណូលទី៣៖ | លក់ដូរ | លក់ដូរ | លក់ដូរ | កម្លាំង ពលកម្ម | |
| ការងារក្រៅពីកសិកម្ម (ប្រភេទពលកម្ម) | កម្មកររោង ចក្រ លក់ដូរ សំណង់ | កម្មកររោង ចក្រ លក់ដូរ សំណង់ | កម្មកររោងចក្រ លក់ដូរ សំណង់ | កម្លាំង ពលកម្ម | |
| ប្រើប្រាស់ឥណទាន | ៩០% | ៥០% | ៣៥% | ៥% | |

ប្រភពទិន្នន័យ៖ *របាយការណ៍ក្សេត្រ-បរិស្ថានឃុំឆ្នាំ២០១៧*

### គ. ស្ថានភាពចំណូលសរុប និងអត្រាការប្រាក់

ប្រជាពលរដ្ឋនៅក្នុងឃុំចំណាក្រោម ធ្វើការប្រើប្រាស់សេវាកម្ចីលុយពីមីក្រូហិរញ្ញវត្ថុនិង ធនាគារ នៅក្នុងរូបភាពផ្សេងៗដែលមានចំនួន ៩០១នាក់ សម្រាប់ឆ្នាំ២០១៦ និងឆ្នាំ២០១៧ មានចំនួន ៩២៦នាក់ មានការកើនឡើងចំនួន ២៥នាក់ បើធៀបនឹងឆ្នាំ២០១៦ ដើម្បីប្រើប្រាស់សម្រាប់៖

- អ្នកបង្គួរ៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារ យកមកចងការបន្ត និងពង្រីកមុខរបរដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ
- អ្នកមធ្យម៖ មានលទ្ធភាពខ្ចីប្រាក់ពីធនាគារយកមកចងការបន្ត និងពង្រីកមុខរបរដូចជា កសិកម្ម សិប្បកម្ម និងលក់ដូរ
- អ្នកក្រ៖ ពុំមានលទ្ធភាពខ្ចីប្រាក់ពីធនាគារ/ឯកជន គ្មានទ្រព្យប្រចាំ
- អ្នកក្រណាស់៖ លក់ពលកម្ម និងចំណាកស្រុក

នៅក្នុងឃុំចំណាក្រោម មិនមានទីតាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារនោះទេ ហើយនៅក្នុងនោះដែរ ប្រជាពលរដ្ឋទទួលបានសេវាកម្ចីលុយពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងធនាគារមួយចំនួនដូចជា៖ ធនាគារអេស៊ីលីដា ធនាគារស្ថាបនា ធនាគារប្រៃសណីយ៍ អេប៊ីអេ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ហត្ថាកសិករ ប្រាសាក់ អេអឹមខេ វីសិនហ្វាន់ ក្រេឌីត អិលអូអិលស៊ី ហ្វូណន និរន្តរ៍ បណ្តាញសេដ្ឋកិច្ច និងសហគមន៍សន្សំប្រាក់ចំនួន៧ភូមិទៀត។ សម្រាប់អត្រាការប្រាក់ អាស្រ័យលើចំនួនទឹកប្រាក់ដែលខ្ចី កាលណាចំនួនទឹកប្រាក់កាន់តែច្រើន អាត្រាការប្រាក់កាន់តែទាប ០,៩ភាគរយ ហើយកាលណាចំនួនទឹកប្រាក់កាន់តែតិច អត្រាការប្រាក់កាន់តែច្រើន ១,៨ភាគរយ ។ ទាំងធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ទាំងអស់មាន អាត្រាការប្រាក់ គឺប្រហាក់ប្រហែលគ្នា ហើយប្រជាពលរដ្ឋ

ទូទៅអាចទទួលសេវាកម្មពីធនាគារ កាណាឌីយ៉ា អេស៊ីលីដា ប្រៃសណីយ៍ និងស្ថាប័នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនរួមមានដូចជា៖ ស្ថាបនា ហត្ថាកសិករ ប្រាសាក់ អេអឹមខេ ក្រេឌីត បណ្ដាញសេដ្ឋកិច្ច មហានគ អម្រិត វីសិនហ្វាន់។ល។ ចំណែកអ្នកខ្ចត់ខ្សោយដែលខ្ចីប្រាក់បន្តពីអ្នកមានជីវភាពបង្គួរនិងមធ្យម មានអត្រាការប្រាក់ខ្ពស់គឺចាប់ពី ១,៥ភាគរយ ទៅ ១០ភាគរយ ។

### ឃ. ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់ ឬក្រោមរូបភាពផ្សេងៗ

ជាទូទៅនៅក្នុងឃុំចំណាក្រោម ការប្រើប្រាស់មីក្រូឥណទានជាសាច់ប្រាក់សុទ្ធដើម្បីយកទៅប្រើប្រាស់ពង្រីកមុខរបរ ចងការបន្ត ទិញសម្ភារៈកសិកម្ម ទិញជី និងប្រើប្រាស់តាមតម្រូវការចាំបាច់ផ្សេងៗទៀត ក៏នៅមានក្រោមរូបភាពប្រជាពលរដ្ឋមួយចំនួនទៅទទួលយកជីដាក់ស្រូវមុន និងសន្យាសងប្រាក់នៅពេលប្រមូលផលស្រូវផងដែរ ។

### ង. ចំណូលពីប្រភពផ្សេងៗ

ប្រជាពលរដ្ឋនៅក្នុងឃុំចំណាក្រោម ពួកគាត់អាចទទួលបាននូវប្រភពចំណូលពីប្រភពផ្សេងៗដូចជា៖

- ចំណាកស្រុកក្រៅប្រទេស (ពលករផ្នែក កសិកម្ម ឧស្សាហកម្ម) ដូចជាប្រទេសថៃ ជាដើម
- និងចំណូលមួយចំនួនតូចទៀត បានមកពីគ្រួសារឬបងប្អូនដែលរស់នៅជាអចិន្ត្រៃយ៍នៅបរទេស ដែលពួកគាត់បានផ្ញើមកដើម្បីផ្គត់ផ្គង់គ្រួសារនៅស្រុកខ្មែរ ។

## ១.១.៤. ស្ថានភាពសិក្សាធិការ

### ក. ស្ថានភាពអប់រំ

យោងតាមផែនការអភិវឌ្ឍន៍ឃុំចំណាក្រោម ០៥ឆ្នាំ(២០១៧-២០២២) បានឱ្យដឹងថា ជារៀងរាល់ឆ្នាំកុមារាកុមារី គ្រប់អាយុចូលរៀន បានចុះឈ្មោះចូលរៀនគ្រប់គ្នា ទោះបីជាកុមារ ស្ថិតនៅក្នុងស្ថានភាពគ្រួសារក្រីក្រ គ្រួសារដែលជាស្ត្រីមេម៉ាយ ឬក្មេងកំព្រា កុមារពិការក៏ដោយក្តី ។ មកដល់ពេលបច្ចុប្បន្ន វិស័យអប់រំនៅក្នុងឃុំ មានការរីកចម្រើនជាងមុន ដូចជា ៖ អគារសិក្សាត្រូវបានសាងសង់ថ្មីៗ និងមានការកែលម្អបន្ទប់រៀនថែមទៀត នៅតាមសាលារៀនគ្រប់កម្រិត ដែលផ្តល់លទ្ធភាពឱ្យសិស្សបានរៀនសូត្រគ្រប់ពេលពុំមានការខ្វះខាតឡើយ។ ចំណុចអវិជ្ជមានក៏មាននៅក្នុងឃុំផងដែរដូចជា៖ ខ្វះគ្រូបង្រៀន មិនទាន់មានសាលាមត្តេយ្យសហគមន៍គ្រប់គ្រាន់នៅតាមភូមិនៅឡើយ មានអ្នកមិនចេះអក្សរ (អនក្ខរជន) ជាពិសេសមនុស្សមានវ័យចំណាស់ពួកគាត់ ពុំសូវមានស្មារតីសិក្សារៀនសូត្រទេ ទោះបីមានការយកចិត្តទុកដាក់ជម្រុញលើកទឹកចិត្តពីអាជ្ញាធរមូលដ្ឋានយ៉ាងណាក៏ដោយ ។

រូបភាព 1៖ សាលារៀនបឋមសិក្សា





នៅក្នុងឃុំចំណាក្រោម មានកម្រិតសិក្សាចាប់ពីមត្តេយ្យសិក្សារហូតដល់អនុវិទ្យាល័យ នៅក្នុងនោះមិនមានសាលាវិទ្យាល័យទេ ប៉ុន្តែមាននៅឃុំផ្សេង ។ សម្រាប់ឃុំនេះ មានសាលាមត្តេយ្យចំនួន ០៦កន្លែង ០៦បន្ទប់ ០៦ថ្នាក់ ហើយសិស្សកំពុងរៀនមានចំនួន ១១៩នាក់ ក្នុងនោះមានស្រីចំនួន ៥៩នាក់ និងគ្រូបង្រៀនមានចំនួន ០៦នាក់ ក្នុងនោះ ០៥នាក់ជាស្ត្រី ។ សាលាបឋមសិក្សាវិញមានចំនួន ១០កន្លែង មាន៦៣បន្ទប់ ៦២ថ្នាក់ ហើយសិស្សដែលកំពុងរៀនមានចំនួនសរុប ២០៤៣នាក់ សិស្សស្រីចំនួន ១០១៥នាក់ និងគ្រូបង្រៀនចំនួន ៦៩នាក់ ស្ត្រី៤២នាក់។ ចំណែកឯអនុវិទ្យាល័យមានចំនួន ០១កន្លែង ១០បន្ទប់ ០៨ថ្នាក់ ហើយសិស្សដែលកំពុងរៀនចំនួន ៤០៦នាក់ ស្រីចំនួន ២៤០នាក់ និងមានគ្រូបង្រៀនចំនួន ០៩នាក់ ក្នុងនោះស្រី ០៦នាក់ ។ អាជ្ញាធរពាក់ព័ន្ធគួរធ្វើឲ្យប្រាកដថាកូនចៅរបស់ប្រជាពលរដ្ឋគ្រប់រូបបានទទួលនូវការអប់រំល្អដោយស្មើភាពគ្នា ហើយយ៉ាងតិចបំផុតបានរៀនចប់ថ្នាក់ទី០៩ និងមានចំណេះដឹងជាមូលដ្ឋានគ្រឹះគ្រប់គ្រាន់សម្រាប់អនាគតល្អប្រសើរ ជម្រុញការអប់រំឲ្យមានគុណភាព ដើម្បីធ្វើយ៉ាងណាឲ្យសាលារៀនមានគ្រូបង្រៀនល្អ កម្មវិធីសិក្សាល្អ និងបរិស្ថានសិក្សាល្អ គាំទ្រដល់យុវជននិងយុវនារីដែលមិនមានលទ្ធភាពបន្តការសិក្សាដល់ថ្នាក់វិទ្យាល័យ និងមហាវិទ្យាល័យឲ្យទទួលបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទុនសម្រាប់បង្កើតមុខរបរដោយខ្លួនឯង ។

តារាង 10៖ ស្ថិតិសាលារៀន ស្ថានភាពអប់រំ និងសិក្សាធិការក្នុងឃុំឆ្នាំ២០១៧

| ស្ថានភាពសាលា | ចំនួនសាលារៀន | | | ចំនួនសិស្សកំពុងសិក្សា | | គ្រូបង្រៀន | |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | សរុប | ស្រី | សរុប | ស្រី |
| ១. សាលាមត្តេយ្យ | ៦ | ៦ | ៦ | ១១៩ | ៥៩ | ៦ | ៥ |
| ២. សាលាបឋមសិក្សា | ១០ | ៦៣ | ៦២ | ២ ០៤៣ | ១ ០១៥ | ៦៩ | ៤២ |
| ៣. អនុវិទ្យាល័យ | ១ | ១០ | ៨ | ៤០៦ | ២៤០ | ៩ | ៦ |
| ៤. វិទ្យាល័យ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| **សរុប** | **១៧** | **៧៩** | **៧៦** | **២ ៥៦៥** | **១ ៣១៤** | **៨៤** | **៥៣** |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

ខ .ស្ថានភាពអក្ខរកម្ម

នៅក្នុងឃុំចំណាក្រោម ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៥-៤៥ឆ្នាំ មានចំនួន ៦ ២០៥ នាក់ ហើយក្នុងចំណោមអ្នកទាំងនោះមាន ១៧,៤ភាគរយ ដែលមិនចេះអក្សរ ហើយបើគិតទៅតាមក្រុមអាយុយើងឃើញថា នៅក្នុងឃុំចំណាក្រោម មានអ្នកមិនចេះអក្សរអាយុចាប់ពី១៥-២៤ឆ្នាំ មានចំនួន ១៧៩នាក់ ស្មើនឹង ៦,៦ភាគរយ អាយុចាប់ពី ២៥-៤៥ឆ្នាំ មានចំនួន ៨៩៩នាក់ ស្មើនឹង ២៥,៧ភាគរយ ។

ប្រជាពលរដ្ឋភាគច្រើនដែលមិនចេះអក្សរ គឺដោយសារមិនបានចូលរៀន មូលហេតុដោយសារសាលារៀននៅឆ្ងាយពីភូមិឃុំប្រជាពលរដ្ឋនៅតែមានកង្វះមធ្យោបាយធ្វើដំណើរទៅកាន់សាលារៀន ខ្វះថវិកាសម្រាប់ទិញសម្ភារសិក្សា សម្លៀកបំពាក់ និងផ្នត់គំនិតរបស់ឪពុកម្តាយចាស់គំរិល ឬមិនជឿនលឿន ។ ទោះបីយ៉ាងនោះក្តី នៅក្នុងឃុំនៅមានថ្នាក់អក្ខរកម្មជាប្រចាំ តែពួកគាត់ពុំទាន់មានពេលវេលាចូលសិក្សា ព្រោះជាប់រវល់ប្រកបរបរចិញ្ចឹមជីវិត ជាហេតុនាំមកនូវការភ្លេចអក្សរ ក្នុងចំណោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខកម្មករន្លងមក ។

**- អនុវិស័យអប់រំក្រៅប្រព័ន្ធ**

ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយត្រូវបានពង្រឹង តាមរយៈការពិនិត្យឡើងវិញគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធនិងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធនិងការកសាងផែនទី ក៏ដូចជា ការពិនិត្យឡើងវិញនូវកម្មវិធីចូលរៀនឡើងវិញនិងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធនិងកម្មវិធីសមមូល ។ ដើម្បីជម្រុញអោយផែនការយុទ្ធសាស្ត្រអនុវិស័យអប់រំក្រៅប្រព័ន្ធបានទទួលជោគជ័យ ត្រូវបន្តអនុវត្តសកម្មភាពដូចខាងក្រោម៖

១. បន្តពង្រឹងសកម្មភាពមជ្ឈមណ្ឌលសិក្សាសហគមន៍ បណ្ណាល័យ និងមណ្ឌលអានដែលមានស្រាប់
២. បន្តពង្រឹងការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សា
៣. អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
៤. បន្តអនុវត្តការងារអក្ខរកម្មតាមការជាក់ស្តែង
៥. បន្តអនុវត្តកម្មវិធីចូលរៀនឡើងវិញ។

តារាង 11៖ ស្ថិតិអ្នកមិនចេះអក្សរ

| បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|
| ចំនួនអ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ២៣៦នាក់ | ១៧៩នាក់ |
| %អ្នកមិនចេះអក្សរអាយុ១៥-២៤ឆ្នាំ | ៨,៧% | ៦,៦% |
| ចំនួនអ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ៨៤៥នាក់ | ៨៩៩នាក់ |
| %អ្នកមិនចេះអក្សរអាយុ២៥-៤៥ឆ្នាំ | ២៤,៩% | ២៥,៧% |
| សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ | ៦ ១២៤នាក់ | ៦ ២០៥នាក់ |
| %អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | ១៧,៧% | ១៧,៤% |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

### គ. ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

បើយោងទៅតាមប្រភពទិន្នន័យមន្ទីរផែនការខេត្តឆ្នាំ២០១៧បានបង្ហាញឲ្យឃើញថាលទ្ធភាពក្នុងការបន្តការសិក្សារបស់សិស្សនៅក្នុងឃុំចំណាក្រោម ទៅថ្នាក់ខ្ពស់ទៀតមានដូចខាងក្រោម៖

- អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ២៧៣ នាក់ ស្រីមានចំនួន ១៣២នាក់
- អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យសរុបចំនួន ៣២៥នាក់ ស្រីមានចំនួន ១៥២នាក់
- អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ៧៣នាក់ ស្រីមានចំនួន ៤៨ នាក់
- អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យសរុបចំនួន ៤៤ នាក់ ស្រីមានចំនួន ២៣នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ២១នាក់ ស្រីមានចំនួន ០៦នាក់។
- អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យសរុបចំនួន ០៨នាក់ ស្រីចំនួន ០៤នាក់
- អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន ០៣នាក់ ស្រីចំនួន ០២នាក់
- អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈពុំមាននៅក្នុងឃុំនោះទេ

តារាង 12៖ ស្ថានភាព និងលទ្ធភាពក្នុងការបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀត

| ការអប់រំតាមក្រុមអាយុ | សរុប | ស្រី |
|---|---|---|
| អាយុពី១២-១៤ឆ្នាំរៀនអនុវិទ្យាល័យ | ២៧៣ | ១៣២ |
| អាយុពី១៥-១៧ឆ្នាំរៀនអនុវិទ្យាល័យ | ៣២៥ | ១៥២ |
| អាយុពី១៥-១៧ឆ្នាំរៀនវិទ្យាល័យ | ៧៣ | ៤៨ |
| អាយុពី១៨-២៤ឆ្នាំរៀនវិទ្យាល័យ | ៤៤ | ២៣ |
| អាយុពី១៨-២៤ឆ្នាំរៀនសកលវិទ្យាល័យ | ២១ | ០៦ |
| អាយុពី២៥-៣៥ឆ្នាំរៀនសកលវិទ្យាល័យ | ០៨ | ០៤ |
| អាយុពី១៨-២៤ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ០៣ | ០២ |
| អាយុពី២៥-៣៥ឆ្នាំរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ | ០០ | ០០ |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំ ចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

## ១.១.៨. ស្ថានភាពសុខាភិបាល

មណ្ឌលសុខភាព គឺជាកន្លែងផ្តល់សេវាអប់រំសុខភាពថែទាំ និងព្យាបាលអ្នកជម្ងឺផ្សេងៗ ដែលជាកន្លែងសាធារណៈរបស់រដ្ឋ ។ ឃុំចំណាក្រោម មានមណ្ឌលសុខភាពចំនួន០១កន្លែង ដែលស្ថិតនៅក្នុងភូមិសណ្តាន់ខាងកើតសាលាឃុំចម្ងាយ ១ ០០០ម ហើយភូមិដែលនៅឆ្ងាយជាងគេ៧គីឡូម៉ែត្រ គឺភូមិលៀប ។ ដែលមានពេទ្យចំនួន៥នាក់ ពេទ្យឆ្មបចំនួន៤នាក់ មានបន្ទប់ចំនួន៧ និងគ្រែចំនួន៣ ចំណែកគ្រូខ្មែរមិនមានទេ ។ ប្រភេទជម្ងឺដែលកាចសាហាវ ឬជម្ងឺឆ្លងដែលកើតញឹកញាប់ គឺជម្ងឺរលាកផ្លូវដង្ហើម ។ ស្ថានភាពមាតា និងទារក នៅក្នុងឃុំចំណាក្រោម មានស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅចំនួន១២នាក់ ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង១ឆ្នាំកន្លងទៅ មានចំនួន២២៥នាក់ ទារកដែលបានកើតរស់ដោយឆ្មបបុរាណចំនួន ១២នាក់ ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យមានចំនួន ២២៥នាក់ ចំនួនមរណៈភាពមាតា

បន្ទាប់ពីសម្រាលកូនក្នុងចន្លោះ០-១ខែ ដោយឆ្មបបុរាណមិនមាននោះទេ មរណៈភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ០-១ខែដោយឆ្មបពេទ្យមិនមានទេ ចំនួនមរណៈភាពទារកក្នុងចន្លោះអាយុ០-១ខែ ដោយឆ្មបបុរាណមិនមាននោះទេ រណៈភាពទារកក្នុងចន្លោះអាយុ០-១ខែដោយឆ្មបពេទ្យមានចំនួន ០១នាក់ ចំនួនទារកដែលបានចុះសំបុត្រកំណើតមានចំនួន ១៤៩នាក់ កុមារដែលមានអាយុចន្លោះពី៩-១២ខែមានចំនួន ១០៦នាក់ ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួនមាន ៨១នាក់ សម្រាប់ការចាក់ថ្នាំបង្ការជម្ងឺផ្សេងៗធ្វើនៅមណ្ឌលសុខភាព និងតាមភូមិជូនប្រជាពលរដ្ឋ មានជម្ងឺមួយចំនួនដូចជា៖ ជម្ងឺកញ្ជ្រិល ស្វិតដៃជើង ក្អកមាន់ របេង តេតាណូស រលាកថ្លើមប្រភេទបេ ផ្តាសាយបក្សី គ្រុនចាញ់ រាករូស និងគ្រុនឈាម ។ ករណី ជម្ងឺធ្ងន់ធ្ងរការបញ្ជូនអ្នកជម្ងឺដោយមធ្យោបាយខ្លួនឯងផ្ទាល់មកកាន់មណ្ឌលសុខភាពព្រោះមណ្ឌលសុខភាពស្ថិតនៅជិតពួកគាត់ឯការបញ្ជូនទៅមន្ទីរពេទ្យបង្អែកដោយមធ្យោបាយផ្ទាល់ខ្លួននិងរថយន្តសង្គ្រោះរបស់ពេទ្យបង្អែកទាំងការចំណាយវាយផ្សេងៗជាបន្ទុករបស់អ្នកជម្ងឺ ក្នុងករណីអ្នកជម្ងឺមិនមានប័ណ្ណក្រីក្រ ។

តារាង 13៖ សុខភាពមាតានិងទារក

| ល.រ | សុខភាពមាតានិងទារក | ឆ្នាំ២០១៧ |
|---|---|---|
| ១ | ចំនួនបុគ្គលិកពេទ្យនៅមណ្ឌលសុខភាព | ៥ |
| ២ | ចំនួនពេទ្យឆ្មបនៅមណ្ឌលសុខភាព | ៤ |
| ៣ | ចំនួនឆ្មបបុរាណនៅមណ្ឌលសុខភាព | ០ |
| ៤ | ចំនួនបន្ទប់នៅមណ្ឌលសុខភាព | ៧ |
| ៥ | ចំនួនគ្រែនៅមណ្ឌលសុខភាព | ៣ |
| ៦ | ចំនួនឆ្មបដែលបានបណ្តុះបណ្តាលមានក្នុងភូមិ | ១ |
| ៧ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបបុរាណក្នុង១ឆ្នាំកន្លងទៅ | ១២ |
| ៨ | ចំនួនស្ត្រីដែលសម្រាលកូនដោយឆ្មបមានការបណ្តុះបណ្តាលក្នុង ១ឆ្នាំកន្លងទៅ | ២២៥ |
| ៩ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបបុរាណ | ១២ |
| ១០ | ចំនួនទារកដែលបានកើតរស់ដោយឆ្មបពេទ្យ | ២២៥ |
| ១១ | ចំនួនមរណៈភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែដោយឆ្មបបុរាណ | ០ |
| ១២ | ចំនួនមរណៈភាពមាតាបន្ទាប់ពីសម្រាលកូនក្នុងចន្លោះ ០-១ខែដោយឆ្មបពេទ្យ | ០ |
| ១៣ | ចំនួនមរណៈភាពទារកក្នុងចន្លោះអាយុ ០-១ខែដោយឆ្មបបុរាណ | ០ |
| ១៤ | ចំនួនមរណៈភាពទារកក្នុងចន្លោះអាយុ ០-១ខែដោយឆ្មបពេទ្យ | ១ |
| ១៥ | ចំនួនទារកដែលបានចុះសំបុត្រកំណើត | ១៤៩ |
| ១៦ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ | ១០៦ |
| ១៧ | ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | ៨១ |

ប្រភពទិន្នន័យ៖ *ក្រុមប្រឹក្សាឃុំ ចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 2៖ មណ្ឌលសុខភាពឃុំចំណាក្រោម




យោងតាមពីទិន្នន័យមន្ទីរផែនការខេត្ត ឆ្នាំ២០១៧ បានឱ្យដឹងថា ចម្ងាយពីភូមិនីមួយៗទៅកាន់មណ្ឌលសុខភាព មិនឆ្ងាយណាស់ណានោះទេ គឺឆ្ងាយបំផុតត្រឹមពី ១ទៅ ៧គីឡូម៉ែត្រ ប៉ុណ្ណោះដូចមានក្នុងតារាងសង្ខេបខាងក្រោម។ ចំណែកស្ថានភាពផ្លូវទៅកាន់មណ្ឌលសុខភាពក៏មិនពិបាកក្នុងការធ្វើដំណើរដែរ ដែលអំណោយផលដល់ការបញ្ជូនអ្នកជម្ងឺទៅកាន់មណ្ឌលសុខភាពបានទាន់ពេលវេលា ។

តារាង 14៖ ចម្ងាយផ្លូវជាមធ្យម ពីភូមិទៅកាន់មណ្ឌលសុខភាព

| ល.រ | ឈ្មោះភូមិ | ចម្ងាយជាមធ្យម ពីភូមិទៅមណ្ឌលសុខភាព | ផ្សេងៗ |
|---|---|---|---|
| ១ | ព្រះនង្គ័ល | ៣ គីឡូម៉ែ | |
| ២ | សំព័រ | ២គីឡូម៉ែត | |
| ៣ | ស្រើរងឹត | ៦គីឡូម៉ែត | |
| ៤ | ស្វាយអៀ | ១,៧ គីឡូម៉ែត | |
| ៥ | នាងនយ | ១,៤ គីឡូម៉ែត | |
| ៦ | សណ្តាន់ | ១ គីឡូម៉ែត | |
| ៧ | ស្ពានគ្រង | ៣ គីឡូម៉ែត | |
| ៨ | ដីអាប់ | ៥ គីឡូម៉ែត | |
| ៩ | ចំណាក់ | ៥ គីឡូម៉ែត | |
| ១០ | លៀប | ៧ គីឡូម៉ែត | |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

ដ្យាក្រាម 2៖ ចម្ងាយផ្លូវជាមធ្យមគិតជាគីឡូម៉ែត្រ ពីភូមិទៅកាន់មណ្ឌលសុខភាព




ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

### ១.១.៦. ស្ថានភាពយេនឌ័រ

តាមផែនការអភិវឌ្ឍន៍ឃុំរយៈពេល០៥ឆ្នាំ (២០១៨-២០២០) បានឱ្យដឹងថាសមភាពការងាររបស់ស្ត្រីនិងបុរសក្នុងឃុំនាពេលបច្ចុប្បន្នគ្មានការរើសអើងឬគាបសង្កត់ទៅលើស្ត្រីនោះទេ។ ផ្ទុយទៅវិញការងារយេនឌ័រកំពុងមានការគាំទ្រយ៉ាងពេញទំហឹង ជាក់ស្តែងក្នុងការងារមានថ្នាក់ដឹកនាំជាស្ត្រីនៅថ្នាក់ភូមិ និងថ្នាក់ឃុំកំពុងត្រូវបានលើកកម្ពស់ និងលើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមយ៉ាងសកម្មនៅក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ ក៏ដូចជាផែនការវិនិយោគផងដែរ ។ ទោះជាបីយ៉ាងនេះក្តីបញ្ហាប្រឈមនៅតែកើតមានឡើងទៅលើសមត្ថភាពស្ត្រី ដោយមានមួយចំនួននៅតែមានកម្រិតជីវភាពក្រីក្រ ខ្លះបោះបង់ការសិក្សា ដើម្បីរកចំណូលមកទ្រទ្រង់ជីវភាពក្នុងគ្រួសារ អ្នកខ្លះចំណាកស្រុកទៅកាន់ភ្នំពេញដើម្បីធ្វើជាកម្មកររោងចក្រ។ដើម្បីដោះស្រាយបញ្ហានេះក្រុមប្រឹក្សាឃុំបានសហការជាមួយមន្ទីរការិយាល័យជំនាញ និងដៃគូរអភិវឌ្ឍន៍នានាជំរុញលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាលបច្ចេកទេសនានា និងជំនាញវិជ្ជាជីវៈបង្កើនមុខរបរថ្មីៗ ដើម្បីបង្កើនប្រាក់ចំណូលនិងកាត់បន្ថយការចំណាកស្រុក។ ប៉ុន្តែបើតាមរបាយការណ៍នៃការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំឆ្នាំ២០១៧ បានឱ្យដឹងអំពីតួនាទីយេនឌ័រក្នុងការចូលរួមសកម្មភាពការងារផលិតកម្មកសិកម្ម និងការងារទូទៅក្នុងជីវភាពគ្រួសាររបស់កសិករ ក្នុងឃុំមានលម្អិតក្នុងតារាងខាងក្រោម ។

តារាង 15៖ ការវិភាគលើតួនាទីយេនឌ័រ ឃុំចំណាក្រោម

| **សកម្មភាព** | **បុរស** | **ស្ត្រី** | **យោបល់បន្ថែម** |
|---|---|---|---|
| ***ស្រូវវស្សា*** | | | |
| ការរៀបចំដីលើកទី១ | ៧០% | ៣០% | ការប្រើប្រាស់កម្លាំងធ្ងន់ |
| ការរៀបចំដីលើកទី២ | ៧០% | ៣០% | ស្ត្រីជួយរៀបចំម្ហូបអាហារ |
| ដឹកគ្រាប់ពូជ | ៧០% | ៣០% | លើកដាក់ធ្ងន់ |
| ព្រួសគ្រាប់ | ៧០% | ៣០% | ការងារនៅទីវាល |
| ការដាក់ជីបំប៉នលើកទី១ | ៧៥% | ២៥% | ស្ត្រីជាអ្នកជួយរៀបចំ |
| ការដាក់ជីបំប៉នលើកទី២ | ៧៥% | ២៥% | ស្ត្រីជាអ្នកជួយរៀបចំ |
| គ្រប់គ្រងទឹកស្រែ | ៨០% | ២០% | ការងារនៅទីវាល |

| | | | |
|---|---|---|---|
| ការគ្រប់គ្រងភ្លឺស្រែ | ៨០% | ២០% | ស្ត្រីធ្វើការងារផ្ទះ |
| ការបាញ់ថ្នាំកសិកម្ម | ១០០% | | ការប្រើប្រាស់កម្លាំងធ្ងន់ |
| ការបាញ់ថ្នាំបំប៉ន | ៨៥% | ១៥% | ការងារនៅទីវាល ស្ត្រីរវល់ការងារផ្ទះ |
| ការច្រូតកាត់ | ៥០% | ៥០% | ជួយការងារគ្នា |
| ការដឹកជញ្ជូន | ៥០% | ៥០% | ជួយការងារគ្នា |
| ហាលសំងួតសំងួត | ៣០% | ៧០% | ស្ត្រីធ្វើការងារនៅផ្ទះ |
| ទុកដាក់ស្រូវ | ៥០% | ៥០% | ស្ត្រីរៀបចំទុកដាក់ |
| លក់ស្រូវ | ៤០% | ៦០% | សម្រេចចិត្តស្មើគ្នាស្ត្រីមានទំនាក់ទំនងល្អជាង |
| **សកម្មភាពមុខរបរចិញ្ចឹមជីវិតសំខាន់ផ្សេងទៀត** | | | |
| សួនបន្លែ | ៣០% | ៧០% | ជួយការងារគ្នា |
| ចិញ្ចឹមជ្រូក | ៥០% | ៥០% | ជួយការងារគ្នា |
| ចិញ្ចឹមគោ ក្របី | ៧០% | ៣០% | ការងារនៅទីវាល |
| ចិញ្ចឹមមាន់ ទា | ៣០% | ៧០% | ការងារនៅផ្ទះ |
| ការប្រមូលអនុផលព្រៃឈើ | ៦០% | ៤០% | ស្ត្រីជួយបានពេលខ្លះនិងរៀបចំម្ហូបអាហារ |
| រកត្រី ខ្យង ក្តាម ខ្ទៅ | ៧០% | ៣០% | ទៅរកទីតាំងឆ្ងាយៗ |
| ការរកឧស | ៧៥% | ២៥% | ការនៅទីវាល |
| សិប្បកម្មផ្សារដែក | ១០០% | | ការប្រើកម្លាំង |
| ដំណាំរួមផ្សំ | ៣០% | ៧០% | ការងារនៅផ្ទះ |
| ផលិតកម្មដំណាំឈើហូបផ្លែ | ៦៥% | ២៥% | ការងារនៅចម្ការ |
| ជំនួញទូទៅ | ៣០% | ៧០% | ការងារនៅឆ្ងាយផ្ទះ |
| ការថែទាំប្រព័ន្ធធារាសាស្ត្រ | ៦៥% | ៣៥% | ការងារនៅទីវាល |

ប្រភពទិន្នន័យ៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន*

យោងតាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំចំណាក្រោម ឆ្នាំ២០១៧ បានរកឃើញពីការវិភាគតួនាទីយេនឌ័រក្នុងឃុំកំពង់ស្វាយដូចខាងក្រោម៖

១. ស្ត្រីភាគច្រើនជាអ្នកផលិតកសិកម្ម

២. បុរសទៅរកចំណូលនៅឆ្ងាយៗផ្ទះ

៣. ស្ត្រីមើលថែការងារនៅផ្ទះជាប្រចាំ

៤. សកម្មភាពការងារមានការចូលរួមធ្វើទាំងអស់គ្នា

៥. ការងារធ្ងន់ៗជាបន្ទុករបស់បុរស

យេនឌ័រ គឺជាប្រធានបទដ៏ស្មុគស្មាញមួយ ដែលគួរតែត្រូវបានដាក់បញ្ចូលទៅគ្រប់មាតិកា និងដំណើរការទាំងអស់នៃកម្មវិធីបំណិនជីវិតក្នុងតំបន់។ ក្នុងពេលជាមួយគ្នានេះការលើកទឹកចិត្តសិស្សឱ្យផ្តោតការយកចិត្តទុកដាក់ទៅលើក្តីបារម្ភ អំពីយេនឌ័រជាក់លាក់មួយ នៅក្នុងកម្រិតមូលដ្ឋានគួរតែជាផ្នែកមួយដ៏សំខាន់នៅក្នុងបទពិសោធន៍នៃការសិក្សា។ តាមប្រភពពត៌មានដែលទទួលបាន ដូចមានរៀបរាប់ខាងលើពាក់ព័ន្ធការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីនៅក្នុងឃុំចំណាក្រោម យើងសង្កេតឃើញថា បុរស និងស្ត្រីមិនមានការរើសអើង ជាពិសេស

ការងាររៀបចំដីស្រែគ្មាធ្ងន់ធ្ងរនោះទេ គឺមានភាពលំអៀងតិចតួចប៉ុណ្ណោះ ដូចជា ការងារធ្វើស្រែឃើញបុរសមានការចូលរួមច្រើនជាងស្ត្រី ការងារនេះបុរសទទួលរ៉ាប់រងទាំងស្រុងដែលស្ត្រីមានកម្លាំងទន់ខ្សោយជាង ជាអ្នកចម្អិនអាហារនៅផ្ទះ ហើយក៏ឃើញការងារដឹកជញ្ជូនគ្រាប់ស្រូវ បាញ់ថ្នាំសម្លាប់សត្វល្អិតនិងដាក់ជី ច្រូតកាត់ និងការងារទុកដាក់ស្រូវជាដើម គឺបុរសបានចូលរួមច្រើនជាងស្ត្រី ប៉ុន្តែការងារក្នុងផ្ទះនិងនៅជិតផ្ទះឃើញស្ត្រីបានចូលរួមច្រើនជាងបុរស តែក្នុងនោះក៏បានរកឃើញថា ការសម្រេចចិត្តក្នុងគ្រួសារបុរសនៅមានសិទ្ធិច្រើនជាងស្ត្រី និងមានស្ត្រីមួយចំនួននៅទទួលរងអំពើហឹង្សាក្នុងគ្រួសារនៅឡើយ ។ ប៉ុន្តែទោះបីមានបញ្ហាប្រឈមខ្លះក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្ត្រីក៏ដោយក៏យើងឃើញកិច្ចការនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលទៅថ្ងៃអនាគតនឹងឈានទៅកាន់តែប្រសើរឡើង ។

## ១.២. ស្ថានភាពភូមិសាស្ត្រ

### ១.២.១. ទីតាំងភូមិសាស្ត្រ

ឃុំចំណាក្រោម ជាឃុំមួយនៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ ដែលស្ថិតនៅលិចទីរួមខេត្ត និងមានចម្ងាយផ្លូវប្រហែល៦៦គីឡូម៉ែត្រ មានទីតាំងផ្អែកលើនិយាមកាផែនទី (អាប់ស៊ីស) ៤៥៧ ៩៧៧,៩៤ និង(អ័រដោនេ) ១ ៤២៤ ១៩១,៥៣ ។ យោងទៅតាមរបាយការណ៍ក្សេត្រ-បរិស្ថានឃុំនេះ មានសណ្ឋានដីមិនរាបស្មើ មានទាប មានខ្ពស់ដោយបានបែងចែកជា៣តំបន់ដូចខាងក្រោមនេះ៖

**តំបន់ I**៖ ជាតំបន់ជម្រាលទាបមធ្យមមានដំណាំស្រូវវស្សា ដំណាំចម្រុះ លំនៅឋាន និងស្រូវប្រាំងតិចតួច ជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌ខ្មៅ ពឹងផ្អែកលើទឹកភ្លៀង ទឹកស្រះ និងទឹកអណ្តូង។

**តំបន់ទី II** ៖ ជាតំបន់ជម្រាលទាប ជាប្រភេទដីកណ្តេង ពណ៌ខ្មៅ ប្រផេះ និងពឹងផ្អែកលើ ទឹកភ្លៀង ទឹកទន្លេសាប អាងស្តុកទឹក ត្រូវបានប្រើប្រាស់សម្រាប់ដំណាំស្រូវវស្សា និងស្រូវប្រាំង។

**តំបន់ទី III**៖ ជាតំបន់ជម្រាលទាបដំណាំស្រូវប្រាំងនិងដីព្រៃលិចទឹករយៈពេលវែង ដីមានជីជាតិជាប្រភេទដីកណ្តេងល្បាប់ពណ៌ខ្មៅ ពឹងផ្អែកលើ ទឹកភ្លៀង ត្រពាំង បឹង ទឹកទន្លេសាប និងអាងស្តុកទឹក ត្រូវបានប្រើប្រាស់ជាដីព្រៃលិចទឹក និងស្រូវប្រាំងតិចតួច។

ផែនទី 3៖ ផែនទីសណ្ឋានដីឃុំចំណាក្រោម



ផែនទី 4៖ ផែនទីបង្ហាញប្រព័ន្ធកេស្រ្ត-បរិស្ថានឃុំចំណាក្រោម




តារាង 16៖ ដ្យាក្រាមពំនុះកាត់ទទឹងឃុំចំណាក្រោម ស្រុកស្វាង

| រូបថត ចំណាក្រោម |  |  |  |
|---|---|---|---|
| **ឈ្មោះតំបន់** | **តំបន់ទី I**<br>**តំបន់វាលទំនាបមធ្យមដំណាំចម្រុះ និងលំនៅឋាន** | **តំបន់ទី II**<br>**តំបន់វាលទំនាបទាបដំណាំស្រូវវស្សា និងប្រាំងដីលិចទឹករយៈពេលខ្លី** | **តំបន់ទី III**<br>**តំបន់វាលទំនាបទាបដំណាំស្រូវប្រាំងនិងដីព្រៃលិចទឹករយៈពេលវែង** |
| **រៀបរាប់ដោយសង្ខេប** | ជម្រាលទាបមធ្យមមានដំណាំស្រូវវស្សាដំណាំចម្រុះនិងដីលំនៅឋានមានស្រូវ ប្រាំងតិច ហើយមានដីជាល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តៀងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌ខ្មៅប្រើប្រាស់ទឹកប្រឡាយ,ទឹកភ្លៀង,ទឹកស្រះ និងទឹកអណ្តូង | ជម្រាលទាបមានដំណាំស្រូវវស្សា និងមានស្រូវប្រាំងលិចទឹករយៈពេលខ្លីដីកណ្តៀងពណ៌ខ្មៅប្រផេះ ប្រើប្រាស់ទឹកប្រឡាយ,ទឹកភ្លៀង,ទឹកទន្លេសាប,អាងស្តុកទឹកដំណាំស្រូវវស្សា និងស្រូវប្រាំង និង ហេដ្ឋារចនាសម្ព័ន្ធ,ប្រើពូជវស្សាចម្រុះ និងប្រាំងប្រើពូជពូជស្រូវ ៨៥,៥០៤, ៥១៥៤ព្រមទាំងការប្រើ | -ជម្រាលទាបដំណាំស្រូវប្រាំង និង ដីព្រៃលិចទឹករយៈពេលវែងដីមានដីជាតិមានដីកណ្តៀងល្បាប់ពណ៌ខ្មៅប្រើប្រាស់ប្រឡាយក្រុងចាង,ទឹកភ្លៀង,ត្រពាំង,បឹង,ទឹកទន្លេសាប,មានអាងស្តុកទឹកដីភាគច្រើនព្រៃលិចទឹកនិង ស្រូវប្រាំង, |

| | | | |
|---|---|---|---|
| | លំនៅឋាន,ដំណាំចម្រុះ,ដំណាំស្រូវវស្សា និង ស្រូវប្រាំង,ដំណាំឈើហូបផ្លែ ហេដ្ឋារចនាសម្ព័ន្ធ ប្រើពូជស្រូវចម្រុះ | ប្រាស់ជីគីមីនិងថ្នាំពុលកសិកម្មផងដែរ | តិចតួចភាគច្រើនព្រៃលិចទឹកនិងស្រូវប្រាំង,ប្រើប្រាស់ពូជស្រូវ ៨៥, ៥០៤, ៥១៥៤ |
| **ឋានលេខា** | ជម្រាលទាបមធ្យមមានដំណាំស្រូវវស្សាដំណាំចម្រុះនិងដីលំនៅឋានមានស្រូវ ប្រាំងតិច | ជម្រាលទាបមានដំណាំស្រូវវស្សា និងមានស្រូវប្រាំងលិចទឹករយៈពេលខ្លី | ជម្រាលទាបដំណាំស្រូវប្រាំងនិងដីព្រៃលិចទឹករយៈពេលវែង |
| **ប្រភេទដី** | ដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗដីកណ្ដោងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌ខ្មៅ | ដីកណ្ដោងពណ៌ខ្មៅ ប្រផេះ | ដីកណ្ដោងល្បាប់ពណ៌ខ្មៅ |
| **ជលសាស្ត្រ** | ប្រឡាយ,ទឹកភ្លៀង | ទឹកប្រឡាយ,ទឹកភ្លៀង,ទឹកទន្លេសាប អាងស្តុកទឹក | ទឹកភ្លៀង,ទន្លេសាប |
| **ធនធានទឹក** | ទឹកប្រឡាយ,ទឹកអណ្ដូង,ទឹកភ្លៀង, ទឹកស្រះ | ទឹកប្រឡាយ,ទឹកភ្លៀង,ទឹកទន្លេសាប អាងស្តុកទឹក | ប្រឡាយក្រងចាង,ទឹកភ្លៀង, ត្រពាំង,បឹង,ទឹកទន្លេសាប, អាងស្តុកទឹក |
| **គម្របដីនិងការប្រើប្រាស់ដី** | លំនៅឋាន,ដំណាំចម្រុះ,ដំណាំស្រូវវស្សា និងស្រូវប្រាំង,ដំណាំឈើហូបផ្លែហេដ្ឋារចនាសម្ព័ន្ធ | ដំណាំស្រូវវស្សា និងស្រូវប្រាំង និង ហេដ្ឋា រចនាសម្ព័ន្ធ,អាងស្តុក ទឹក | ភាគច្រើនព្រៃលិចទឹកនិង ស្រូវប្រាំង,អាងស្តុកទឹក,បឹង, ត្រពាំង |
| **ដំណាំសំខាន់ៗ** | ដំណាំស្រូវវស្សា១ដងបន្លែរួមផ្សំ | ដំណាំស្រូវប្រាំងដំណាំឪឡឹក | ដំណាំស្រូវប្រាំង និង ដំណាំឈូក |
| **ពូជស្រូវ** | រំដួល,ម្លិ,ផ្កាម្លិះ,នាងគង់ខ្សាច់, ស្រូវណ្ឌាយ,រាំងជ័យ,ម្រុំ,ដំណើបស្បៃមង្គលដំណើបនាងនុ, ដំណើបក្អោក, ពូជផ្ការមៀត | ពូជស្រូវ ៨៥, ៥០៤, ៥១៥៤ | ពូជស្រូវ ៨៥, ៥០៤, ៥១៥៤ |
| **ការប្រើប្រាស់ជី** | ជីលាមកសត្វ<br>អ៊ុយរេ ១ បាវ/ហិកតា<br>ដេ.អា.ប៉េ ១ បាវ/ហិកតា | ជីលាមកសត្វ<br>អ៊ុយរេ ៤ បាវ/ហិកតា<br>ដេ.អា.ប៉េ ៣ បាវ/ហិកតា<br>ជីចម្រុះ ៧ បាវ/ហិកតា | ជីលាមកសត្វ<br>អ៊ុយរេ ៤ បាវ/ហិកតា<br>ដេ.អា.ប៉េ ៣ បាវ/ហិកតា<br>ជីចម្រុះ ៧ បាវ/ហិកតា |
| **ការចិញ្ចឹមសត្វ** | គោ,ក្របី,ជ្រូក,មាន់,ទា | វាលស្មៅគោ,ក្របី, | វាលស្មៅគោ,ក្របី, |
| **ដីរបស់រដ្ឋនិងសហគមន៍** | សាលាឃុំ,សាលារៀន,ដីចំណីផ្លូវ,មណ្ឌលសុខភាព,ផ្លូវ,វត្ត, ចំណាក្រោម,ដីអ្នកតា | ចំណាក្រោម,ដីត្រពាំង, ដីអាងស្តុកទឹកសហគមន៍ | ដីព្រៃលិកទឹក,បឹង,ដីអាងស្តុកទឹកសហគមន៍១០ដីបឹងអភិរក្សសហគមន៍នេសាទ(ស្ថានគ្រងអភិវឌ្ឍន៍) |
| **បញ្ហាផ្សេងៗ** | . ទឹកជំនន់(ភ្លៀងខ្លាំង)<br>-ខ្វះប្រព័ន្ធស្រោចស្រព | -ស្មៅច្រើនជាន់ស្រូវ<br>.-លិចដោយសារការបើកទ្វាទឹក | -ការកាប់បំផ្លាញព្រៃលិចទឹកបានយកដីធ្វើស្រែប្រាំង |

| | | | |
|---|---|---|---|
| | -ក្ដាមកាត់ស្រូវ<br>-ស្មៅច្រើនជាន់ស្រូវ<br>-សត្វល្អិតបំផ្លាញដំណាំស្រូវ<br>-ជំងឺលើដំណាំស្រូវ<br>-មានការពុលជាតិដែក (ស្លឹកលឿង)<br>.លិចដោយសារការបើកទ្វាទឹក<br>. ខ្វះទឹកនៅពេលបិទទ្វាទឹក<br>.សត្វល្អិតបំផ្លាញដំណាំបន្លែនិងស្រូវ (ដង្កូវ,កណ្ដូប,ខ្យងក្រហម)<br>. ផ្លូវខូចលំបាកធ្វើដំណើរ<br>.ខ្វះប្រព័ន្ធស្រោចស្រពនៅរដូវប្រាំង<br>.ខ្វះពូជស្រូវទំនើបធន់នឹងអាកាសធាតុ<br>.គ្រោះធម្មជាតិខ្យល់ព្យុះរលំផ្ទះ<br>-គោក្របីកើតជម្ងឺអុតក្ដាម,សារទឹក)<br>-ខ្វះពូជសត្វល្អ<br>-ខ្វះបង្គន់អនាម័យ<br>-ខ្វះទឹកស្អាតប្រើប្រាស់<br>-ខ្វះបច្ចេកទេសចិញ្ចឹមសត្វ<br>-ខ្វះបច្ចេកទេសដាំដុះដំណាំស្រូវ<br>-ខ្វះបច្ចេកទេសដាំដំណាំបន្លែ<br>-ខ្វះបច្ចេកទេសដាំដំណាំឈើហូបផ្លែ<br>-ដីស្រែមិនរាបស្មើ<br>-ប្រព័ន្ធស្រោចស្រពមិនទាន់មានទ្វាទឹក<br>-ប្រឡាយជើងក្អែបនាំទឹកទៅស្រែដែលប្រឡាយមេនៅឆ្ងាយ<br>-ថ្នាំកសិកម្មមានតម្លៃខ្ពស់<br>-ប្រជាជនមួយចំនួនចង់បានដីប្រឡាយចាស់ធ្វើជាដីកម្ម សិទ្ធិ<br>-ការខ្ចីឥណទានធនាគារប្រើប្រាស់មិនចំគោលដៅ | -ខ្វះទឹកនៅពេលបិទទ្វាទឹក<br>-សត្វល្អិតបំផ្លាញដំណាំស្រូវ<br>-ជំងឺលើដំណាំស្រូវ<br>.សត្វល្អិតបំផ្លាញដំណាំបន្លែនិងស្រូវ (ដង្កូវ,កណ្ដូប,ខ្យងក្រហម)<br>. ផ្លូវខូចលំបាកធ្វើដំណើរ<br>. ខ្វះប្រព័ន្ធស្រោចស្រពនៅរដូវប្រាំង<br>.ខ្វះពូជស្រូវទំនើបធន់នឹងអាកាសធាតុ<br>. គ្រោះធម្មជាតិខ្យល់ព្យុះរលំផ្ទះ<br>.គោក្របីកើតជម្ងឺ(អុតក្ដាម,សាទឹក)<br>. ខ្វះពូជសត្វល្អ<br>. ខ្វះបង្គន់អនាម័យ<br>. ខ្វះទឹកស្អាតប្រើប្រាស់<br>-ដីស្រែមិនរាបស្មើ<br>-ស្រែគ្មានភ្លឺ<br>-ការប្រើប្រាស់ជីគីមីថ្នាំគីមីមិនត្រឹមត្រូវតាមតាមបទដ្ឋានបច្ចេកទេស<br>. ខ្វះបច្ចេកទេសចិញ្ចឹមសត្វ<br>. ខ្វះបច្ចេកទេសដាំដុះដំណាំស្រូវ<br>. ខ្វះបច្ចេកទេសដាំដំណាំបន្លែ<br>-ជួលដីធ្វើស្រែប្រាំងមានតម្លៃថ្លៃ<br>-តម្លៃច្រូតស្រូវដោយម៉ាស៊ីនថ្លៃ | -ខ្វះប្រភពទឹកនៅរដូវប្រាំង<br>-មានការបំផ្លាញសត្វព្រៃ<br>-ស្មៅច្រើនជាន់ស្រូវ<br>-សត្វល្អិតបំផ្លាញដំណាំស្រូវ<br>-ជំងឺលើដំណាំស្រូវ<br>. ផ្លូវខូចលំបាកធ្វើដំណើរ<br>.ខ្វះប្រព័ន្ធស្រោចស្រពនៅរដូវប្រាំង<br>.ខ្វះពូជស្រូវទំនើបធន់នឹងអាកាសធាតុ<br>. គ្រោះធម្មជាតិខ្យល់ព្យុះ<br>.គោក្របីកើតជម្ងឺ(អុតក្ដាម, សាទឹក)<br>-ការប្រើប្រាស់ជីគីមីថ្នាំគីមីមិនត្រឹមត្រូវតាមតាមបទដ្ឋានបច្ចេកទេស<br>. ខ្វះបច្ចេកទេសដាំដុះដំណាំស្រូវ<br>-ជួលដីធ្វើស្រែប្រាំងមានតម្លៃថ្លៃ<br>-តម្លៃសម្ភារកសិកម្មថ្លៃ<br>-ការនេសាទត្រីប្រើប្រាស់ឧបករណ៍ខុសច្បាប់<br>-តម្លៃច្រូតស្រូវដោយម៉ាស៊ីនថ្លៃ<br>-គោក្របីមានជំងឺ |
| **កាលានុវត្តភាព**/ | -មានប្រព័ន្ធស្រោចស្រពនាំទឹកពី | -បើមានប្រភពទឹកអាចធ្វើស្រែ២ដង | -អាចធ្វើស្រែប្រាំ |

| | | | |
|---|---|---|---|
| **ឱកាស** | ប្រភពទឹកអាចធ្វើស្រែបាន២ដង<br>-អាចធ្វើស្រែបង្កើនរដូវ<br>-អាចពង្រីកការដាំដុះដំណាំបន្លែ<br>-អាចពង្រីកការចិញ្ចឹមសត្វ(គោ.ក្របី.ជ្រូក.មាន់.ទា..)<br>-បង្កើនការបណ្តុះបណ្តាលបច្ចេកទេស ផលិតកម្មកសិកម្ម<br>-បង្កើនការចិញ្ចឹមត្រីបាន<br>-ប្រជាកសិករអាចចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗបាន<br>-អាចផលិតពូជស្រូវបាន<br>-អាចផលិតពូជត្រីបាន<br>-ស្តាប្រឡាយចាស់<br>-មានដីសាងសង់ចំណាក្រោមជើងភ្នែបបាន<br>-ពង្រឹងផ្សព្វផ្សាយលិខិតបទដ្ឋានអាជ្ញាធរទន្លេសាប<br>-ផ្សព្វផ្សាយច្បាប់បរិស្ថាន | -មានអាងស្តុកទឹកធ្វើស្រែប្រាំង<br>-ពង្រឹងផ្សព្វផ្សាយលិខិតបទដ្ឋានអាជ្ញាធរទន្លេសាប<br>-ផ្សព្វផ្សាយច្បាប់បរិស្ថាន | -អភិរក្សបឹងជម្រកត្រី<br>-រក្សាព្រៃលិចទឹក<br>-ទប់ស្កាត់ការនេសាទខុសច្បាប់<br>-ផ្សព្វផ្សាយពីការការអភិរក្សធនធានធម្មជាតិ<br>-ពង្រឹងផ្សព្វផ្សាយលិខិតបទដ្ឋានអាជ្ញាធរទន្លេសាប<br>-ផ្សព្វផ្សាយច្បាប់បរិស្ថាន |

ប្រភពទិន្នន័យ៖ *របាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំចំណាក្រោម*

យោងទៅតាមទិន្នន័យក្រុមការងារ និងរបាយការណ៍ក្សេត្រ-បរិស្ថាន និងក្រុមប្រឹក្សាឃុំចំណាក្រោម បានបង្ហាញឲ្យឃើញថា នៅក្នុងឃុំមានប្រភពទឹកសំខាន់ៗដូចជា ទឹកភ្លៀង បឹងទន្លេសាប អាងស្តុកទឹក បឹង ត្រពាំង និងមានប្រឡាយចំនួន ៣១ខ្សែ។ នាបច្ចុប្បន្ននេះនៅក្នុងឃុំចំណាក្រោម មានប្រឡាយសរុបចំនួន ៣១ខ្សែ ប្រវែង ៦៧ ៧៦៩,៨៣ម៉ែត្រ នៅក្នុងនោះប្រឡាយមេ ០៣ខ្សែ ប្រវែង ៦ ២២១,៣៧ម៉ែត្រ ប្រឡាយរង ០៧ខ្សែ ប្រវែង ១៦ ៥៤៩,៨៦ម៉ែត្រ ប្រឡាយតូច ២១ខ្សែ ប្រវែង ៤៤ ៩៩៨,៦០ម៉ែត្រ និង ទ្វារស្ទាក់ទឹក ០៦កន្លែង ចំណែកផ្ទៃដីស្រែដែលទទួលបានទឹកពីប្រព័ន្ធស្រោចស្រពមានចំនួន ៥ ២២៨ហិកតា ដែលក្នុងនោះដីស្រែវស្សាទទួលបានពីប្រព័ន្ធស្រោចស្រពមាន ១៩០ ហិកតា និងដីស្រែប្រាំងទទួលបានពីប្រព័ន្ធស្រោចស្រពមាន ៥ ០៣៨ ហិកតា ក្រៅពីនេះប្រជាពលរដ្ឋប្រើប្រាស់ទឹកស្រះ និងទឹកអណ្តូងជាប្រភពទឹកបន្ទាប់បន្សំតែប៉ុណ្ណោះ ។

តារាង 17៖ ប្រព័ន្ធធារាសាស្ត្រ

| **ល.រ** | **ប្រភេទប្រឡាយ** | **ប្រវែង(ម)** | **ការពិពណ៌នាប្រព័ន្ធធារាសាស្ត្រ សំខាន់ៗក្នុងឃុំ** |
|---|---|---|---|
| ១ | ប្រឡាយមេ | ៣ ០៩២,៤៦ | ចេញពីភូមិព្រះនង្គ័ល កាត់ផ្លូវជាតិលេខ៦ មកទល់ភូមិស្រីរងិត |
| ២ | ប្រឡាយមេ | ២ ២៩០,១៨ | ពីស្រះអ្នកតាស្ពានក្នុង ធ្លាក់មកទល់នឹងប្រឡាយខ្សែទី៥ |
| ៣ | ប្រឡាយមេ | ៨៣៨,៧៣ | ពីស្រះទឹក ភូមិសំព័រ (ភ្ជាប់ពីប្រឡាយទី២២) ទៅប្រសព្វផ្លូវទី៣៩ |
| ៤ | ប្រឡាយរង | ៤ ២១២,៩៥ | ប្រឡាយបេតុងមេ ៣០កញ្ញា ធ្លាក់មកនិងផ្លូវជាតិលេខ៦ អា និងចេញមកទល់ភូមិនាងនយ |

| | | | |
|---|---|---|---|
| ៥ | ប្រឡាយរង | ១ ៩១២,៦៨ | ពីផ្លូវជាតិលេខ ៦ភូមិស្ពានគ្រងធ្លាក់ដល់ប្រឡាយទី៨ភូមិចំណាក់ |
| ៦ | ប្រឡាយរង | ១ ០៤៩,០២ | ប្រឡាយតូចជីក (ប្រឡាយចាស់) ចេញពីប្រឡាយខ្សែទី៩ ធ្លាក់ដល់ប្រឡាយទី៨ |
| ៧ | ប្រឡាយរង | ៣ ៦៧៧,៦៨ | ពីព្រំប្រទល់ចំណាលើ ធ្លាក់កាត់ប្រឡាយទី១៤ និងកាត់ផ្លូវជាតិលេខ ៦អា និងដល់ប្រឡាយទី៨ |
| ៨ | ប្រឡាយរង | ២ ៦៦១,៨៧ | ភ្ជាប់ពីប្រឡាយឃុំបន្ទាយស្ទោង កាត់ភូមិលៀបភូមិព្រះនង្គ័ល ទល់ផ្លូវជាតិ |
| ៩ | ប្រឡាយរង | ១ ៩៩៦,១៧ | ពីប្រឡាយបេតុងភូមិសណ្ដាន់ ទៅត្បូងអមតាមផ្លូវក្នុងភូមិនាងនយ |
| ១០ | ប្រឡាយរង | ១ ០៣៩,៤៨ | ពីឃុំចំណាលើ ទៅទល់ទួល និងត្រពាំងអំពែទុំ រហូតប្រឡាយទី៦ |
| ១១ | ប្រឡាយតូច | ៣ ១៤៤,៦៨ | ពីប្រឡាយស្ពានច្រឡុះ ធ្លាក់មកក្បែទួលទ័ពស្លាប់ |
| ១២ | ប្រឡាយតូច | ១ ៤៧៩,១៣ | បំបែកចេញពីប្រឡាយខ្សែទី៣ ទល់នឹងប្រឡាយខ្សែទី១ (ភូមិនាងនយ) |
| ១៣ | ប្រឡាយតូច | ៣ ២០៥,០២ | ពីប្រឡាយទី៣ ទល់ប្រឡាយទី៦ ភូមិស្រីរងិត ទៅភូមិស្វាយអៀ |
| ១៤ | ប្រឡាយតូច | ១ ៤៣៦,១១ | ពីភូមិសណ្ដាន់ ឆ្ពោះមកត្បូងទល់ស្រះអ្នកតាស្ពានក្នុង |
| ១៥ | ប្រឡាយតូច | ៩០៤,៩៤ | ចេញពីប្រឡាយខ្សែទី៥ ទល់ត្រពាំងតាឡុក (ភូមិស្វាយអៀ) |
| ១៦ | ប្រឡាយតូច | ៥ ៦៦៩,១៦ | បំបែកចេញពីប្រឡាយខ្សែទី២ ដល់ក្រោយដីស្រែ ភូមិជីអាប់ |
| ១៧ | ប្រឡាយតូច | ១ ១២៨,៥៥ | បំបែកចេញពីប្រឡាយខ្សែទី២ ដល់ក្រោយដីស្រែ ភូមិជីអាប់ |
| ១៨ | ប្រឡាយតូច | ១ ៤៥៤,៩៩ | ពីប្រឡាយខ្សែទី៩ ឆ្ពោះទៅនឹងប្រឡាយទី១៣ ស្ពានគ្រង |
| ១៩ | ប្រឡាយតូច | ៣ ២៥៤,១៣ | ពីផ្លូវជាតិលេខ៦ ភូមិស្ពានគ្រងប្រសព្វប្រឡាយទី១០ ធ្លាក់ដល់ភូមិចំណាក់ |
| ២០ | ប្រឡាយតូច | ៣ ១៤០,៤៩ | ពីផ្លូវជាតិលេខ៦ភូមិស្ពានគ្រង ទៅប្រឡាយខ្សែទី៨ ភូមិចំណាក់ |
| ២១ | ប្រឡាយតូច | ១ ៩៧៥,១៧ | ពីប្រឡាយទី១៤ ធ្លាក់កាត់ផ្លូវជាតិលេខ៦អា បត់មកជប់ប្រឡាយទី១២ ភូមិចំណាក់ |
| ២២ | ប្រឡាយតូច | ២ ៤៩៧,៧៧ | ពីដីភូមិស្ពានគ្រង ខាងជើងផ្លូវជាតិ៦អា ពីព្រំប្រទល់ឃុំសាន់គ ទល់នឹងប្រឡាយទី១៣ |
| ២៣ | ប្រឡាយតូច | ៧០០,៤៧ | ពីប្រឡាយទី១២ ធ្លាក់មកស្រះទឹកភូមិចំណាក់ |
| ២៤ | ប្រឡាយតូច | ១ ៤៩៧,០៣ | ពីភូមិចំណាក់ ឆ្ពោះទៅទិសខាងលិច កាត់ប្រឡាយទី១២ |
| ២៥ | ប្រឡាយតូច | ៧៩៦,៤១ | ពីស្រះទឹកភូមិចំណាក់ ធ្លាក់ទៅដីស្រែក្រោមភូមិចំណាក់ |
| ២៦ | ប្រឡាយតូច | ២ ៦៩៤,២០ | ពីប្រឡាយទី២៩ ប្រឡាយតូចក្រោយពីភូមិជីអាប់ធ្លាក់ដល់ប្រឡាយទី៨ |
| ២៧ | ប្រឡាយតូច | ៣ ១៤៦,៥៤ | ពីផ្លូវជាតិលេខ ៦អា (ភូមិជីអាប់) ឆ្ពោះទៅប្រឡាយខ្សែទី៨ ដីស្រែក្រោម |
| ២៨ | ប្រឡាយតូច | ១ ១០៩,០២ | ពីប្រឡាយទឹកទី២០ ទៅទល់នឹងព្រំប្រទល់ឃុំសាន់គ |
| ២៩ | ប្រឡាយតូច | ១ ៩១៥,៤២ | ពីប្រឡាយទី២៦ ភូមិនាងនយ ទៅកើត មកទល់ប្រឡាយទី៩ ភូមិចំណាក់ |
| ៣០ | ប្រឡាយតូច | ២ ០៤៣,៤៨ | ពីប្រឡាយបេតុងទី៩ ទៅកើតទល់ប្រឡាយទី២០ ភូមិជីអាប់ |
| ៣១ | ប្រឡាយតូច | ១ ៨០៥,៨៩ | ពីប្រឡាយទី១៤ កាត់ប-សិក្សាចំណារ ឆ្ពោះទៅត្បូង ប្លុកដីស្រែក្រោម |

រូបភាព 3៖ ប្រព័ន្ធធារាសាស្ត្រ

|  |  |
|---|---|
| ប្រឡាយរង | ប្រឡាយតូច |

ផែនទី 5៖ ផែនទីប្រព័ន្ធធារាសាស្ត្រនៅក្នុងឃុំចំណាក្រោម



### ១.២.២.អាកាសធាតុ (ពិពណ៌នាតាមរដូវកាល)

នៅក្នុងឃុំចំណាក្រោម ក៏ដូចជានៅទូទាំងខេត្ត គឺទទួលនូវខ្យល់មកពីតំបន់ត្រូពិច ដែលមានអាកាសធាតុក្តៅ ហើយសើម ។ របបខ្យល់មូសុង គឺបានពាំនាំមកនូវចំនួនទឹកភ្លៀងយ៉ាងច្រើនមកជាមួយ ដែលអំណោយផលទៅដល់ការធ្វើកសិកម្មនានា និងដាំដំណាំផ្សេងៗទៀត ។

បើយោងទៅតាមប្រភពទិន្នន័យពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ធំ ប្រចាំស្រុកស្ទោងក្នុងឆ្នាំ២០១៧ បានបង្ហាញឲ្យឃើញថា នៅក្នុងស្រុកស្ទោងទាំងមូលមានភ្លៀងធ្លាក់ចំនួន៨៩ដង និងមានបរិមាណទឹកភ្លៀងប្រចាំឆ្នាំចំនួន១៤២០ម.ម ។

**អំពីអាកាសធាតុ៖**

- រដូវរងារ៖ ខែ វិច្ឆិកា ដល់ ខែ មីនា (២០ ទៅ ២៨អង្សា)
- រដូវក្តៅ៖ ខែ មីនា ដល់ ខែ ឧសភា (៣០ ទៅ ៣៥អង្សា)
- រដូវភ្លៀង៖ ខែ ឧសភា ដល់ ខែ តុលា (២៣ ទៅ ៣០អង្សា ជាមួយនិងការឡើងសំណើមទៅដល់ ៩០ភាគរយ)នៅរដូវនេះជារៀងរាល់ឆ្នាំ គឺមានភ្លៀងធ្លាក់ខ្លាំង នៅពេលរសៀល និងល្ងាច។
-សំណើម៖ ឃុំចំណាក្រោមមានសំណើមជាមធ្យម៥៥ភាគរយ និងមានល្បឿនខ្យល់៣គីឡូម៉ែត្រ/ម៉ោង ។

តារាង 18៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ

| ខែ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| បរិមាណទឹកភ្លៀង | 0 | 0 | ១៨,៧ | ១១៦ | ២៩៥ | ១៥៣,៣ | ៩៩ | ២៣៤ | ៧៩,៥ | ២១៨ | ៩៩,៩ | ១៧ |
| ចថ្ងៃមានភ្លៀងធ្លាក់ | 0 | 0 | ២ | ៦ | ១៣ | ៨ | ៩ | ៩ | ៣ | ៩ | ១២ | ២ |

ប្រភពទិន្នន័យ៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

ដ្យាក្រាម 3៖ បរិមាណទឹកភ្លៀងប្រចាំឆ្នាំ




ប្រភពទិន្នន័យ៖ *មន្ទីរធនធានទឹក និងឧតុនិយម ខេត្តកំពង់ធំ ឆ្នាំ២០១៧*

## ១.២.៣.ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍រួមមាន ផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាស ។ បច្ចុប្បន្នឃុំចំណាក្រោមមានតែប្រព័ន្ធគមនាគមន៍ផ្លូវគោកប៉ុណ្ណោះ ហើយបានដើរតួយ៉ាងសំខាន់ក្នុងការសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដែលមានផ្លូវសរុបចំនួន៥០ខ្សែ ប្រវែងមាន ១៩០ ៧៩៣,២៨ម៉ែត្រ ក្នុងនោះផ្លូវកៅស៊ូមានមាន២ខ្សែប្រវែង ១០ ៨៩៩,៧៧ម៉ែត្រ ផ្លូវក្រាលគ្រួសក្រហម ១៩ខ្សែប្រវែង ១៧ ៦០៨,១១ម៉ែត្រ ផ្លូវលំដីសមាន២៩ខ្សែប្រវែង ១៦២ ២៨៥,៤ម៉ែត្រ ស្ពានចំនួន៥កន្លែង និងលូកាត់ផ្លូវ៥៣កន្លែង ។ ឃុំមានការរីកចម្រើនផ្នែកប្រព័ន្ធដឹកជញ្ជូនគួរឲ្យកត់សម្គាល់ដែលមានផ្លូវជាតិលេខ៦តភ្ជាប់ទៅខេត្តសៀមរាប ដោយឆ្លងកាត់ឃុំទ្រា ស្រុកស្ទោង និងទៅភ្នំពេញដោយឆ្លងកាត់ស្រុកកំពង់ស្វាយ ដល់ចំណុចផ្លូវថ្នល់បំបែក និងបន្តដំណើរតាមផ្លូវវាងក្រុងក៏បាន ឬចូលតាមផ្លូវក្នុងខេត្តក៏បាន នៃខេត្តកំពង់ធំ ផ្លូវជាតិនេះមិនទាន់មានការខូចខាតអ្វីនៅឡើយទេ ប៉ុន្តែក្រៅពីផ្លូវជាតិនេះឃើញថាចាប់ផ្តើមខូចខាតទៅវិញជាបណ្តើៗ ដោយសារតែមានការដឹកជញ្ជូនលើសទម្ងន់ គ្រោះធម្មជាតិនិងសកម្មភាពរបស់មនុស្សប្រចាំថ្ងៃ ។

តារាង 19៖ ប្រព័ន្ធផ្លូវដឹកជញ្ជូន

| ល.រ | ប្រភេទផ្លូវ | ចំនួនខ្សែផ្លូវ | ប្រវែង (ម) |
|---|---|---|---|
| ១ | ផ្លូវគ្រួសក្រហម ឬក្រាលថ្ម | ១៩ | ១៧ ៦០៨,១១ |
| ២ | ផ្លូវចាក់កៅស៊ូ | ២ | ១០ ៨៩៩,៧៧ |
| ៣ | ផ្លូវដីស ឬផ្លូវរទេះ | ២៩ | ១៦២ ២៨៥,៤ |
| | **សរុប** | **៥០** | **១៩០ ៧៩៣,២៨** |

រូបភាព 4៖ ប្រព័ន្ធគមនាគមន៍

|  |  |  |
|---|---|---|
| **ផ្លូវកៅស៊ូ** | **ផ្លូវគ្រួសក្រហម** | **ផ្លូវលំដីស** |

ផែនទី ៦៖ ផែនទីហេដ្ឋារចនាសម្ព័ន្ធឃុំចំណាក្រោម



### ១.២.៤. បរិក្ខាសាធារណៈ

#### ក. គ្រួសារដែលប្រើប្រាស់ថាមពលអគ្គិសនី

បេសកកម្មរបស់មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ គឺដឹកនាំជំរុញការគ្រប់គ្រង និងសមាហរណកម្មលើវិស័យរ៉ែ និងថាមពលរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនី នៅក្នុងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម នៅមូលដ្ឋាន និងក្នុងខេត្តកំពង់ធំ ក្នុងនាមជាសេនាធិការឲ្យក្រសួងរ៉ែ និងថាមពល ។

យោងទៅតាមទិន្នន័យមន្ទីរផែនការឆ្នាំ២០១៧ បានបង្ហាញឲ្យឃើញថា នៅក្នុងឃុំចំណាក្រោម ប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួន៤៤៩ខ្នងផ្ទះ ស្មើនឹង១៧ភាគរយ ផ្ទះបំភ្លឺដោយអាគុយមានចំនួន ១៦៥៣ខ្នងផ្ទះ ស្មើនឹង៦២,៧ភាគរយ ផ្ទះប្រើប្រាស់បន្ទះសូឡាមានចំនួន ១៤៣ខ្នងផ្ទះ ស្មើនឹង៥,៤ភាគរយ ផ្ទះបំភ្លឺដោយឡជីវឧស្ម័នមាន០២ខ្នងផ្ទះ ហើយផ្ទះមានទូរទស្សន៍ប្រើប្រាស់មានចំនួន ១៧១២ខ្នងផ្ទះ ស្មើនឹង៦៤,៩ភាគរយ ។ ដូច្នេះប្រជាពលរដ្ឋប្រើប្រាស់អាគុយមានចំនួនច្រើនជាងគេ និងផ្ទះបំភ្លឺដោយឡជីវឧស្ម័នមានចំនួនតិចជាងគេ ។

តារាង 20៖ ស្ថិតិអ្នកប្រើប្រាស់អគ្គិសនី

| បរិយាយ | ២០១៦(%) | ២០១៧ | |
|---|---|---|---|
| | | ភាគរយ(%) | ចំនួនផ្ទះ |
| ផ្ទះបំភ្លឺដោយបណ្តាញអគ្គិសនី | ៩,០ | ១៧,០ | ៤៤៩ |
| ផ្ទះបំភ្លឺដោយអាគុយ | ៧៤,០ | ៦២,៧ | ១ ៦៥៣ |
| ផ្ទះបំភ្លឺដោយបន្ទះសូឡា | ៤,៣ | ៥,៤ | ១៤៣ |
| ផ្ទះបំភ្លឺដោយឡជីវឧស្ម័ន | ០,០ | ០,១ | ២ |
| ផ្ទះមានទូរទស្សន៍ប្រើប្រាស់ | ៦៣,៥ | ៦៤,៩ | ១ ៧១២ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

#### ខ. ប្រព័ន្ធទឹកស្អាត

អាជ្ញាធរខេត្តកំពង់ធំ បានអំពាវនាវឲ្យប្រជាពលរដ្ឋ ដែលធ្លាប់ប្រើប្រាស់ទឹកស្ទឹង ត្រពាំង ឬអណ្តូងដៃងាកមកបរិភោគទឹកស្អាតវិញ ដើម្បីជួយលើកកម្ពស់សុខភាព និងលើកស្ទួយអនាម័យនៅជនបទ ។ នៅក្នុងឃុំចំណាក្រោម បានចំណាយថវិកាមូលនិធិឃុំ ឬក៏បានកៀងគរធនធានពីខាងក្រៅក្នុងការសាងសង់ដូចជា៖ អណ្តូងស្នប់ ឬអណ្តូងចម្រុះមានចំនួន ១៤៥អណ្តូង អណ្តូងជីកមានការពារមានចំនួន ២២៩អណ្តូង និងចំនួនអណ្តូងជីកគ្មានការពារមានចំនួន១៣៣ ស្រះទឹកដែលប្រើប្រាស់មានចំនួន៧៣ស្រះ ហើយនៅក្នុងនោះចំនួនអណ្តូងជីកមានការពារ មានប្រជាពលរដ្ឋប្រើប្រាស់ច្រើនជាងគេ និងស្រះទឹកមានចំនួនតិចជាងគេ ។

តារាង 21៖ ស្ថិតិប្រភពទឹកប្រើប្រាស់

| ល.រ | បរិយាយ | ២០១៦ | ២០១៧ |
|---|---|---|---|
| ១ | ចំនួនអណ្តូងស្នប់ឬអណ្តូងចម្រុះ | ១៤០ | ១៤៥ |
| ២ | ចំនួនអណ្តូងជីកមានការពារ | ៤១៩ | ២២៩ |
| ៣ | ចំនួនអណ្តូងជីកគ្មានការពារ | ១២០ | ១៣៣ |
| ៤ | ចំនួនស្រះទឹកដែលប្រើប្រាស់ | ៣៥ | ៧៣ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

# ១.៣. ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

## ១.៣.១. ស្ថានភាពការកាន់កាប់ និងគ្រប់គ្រងដី

ផែនទី 7៖ ផែនទីប្រើប្រាស់ដីសាមញ្ញក្នុងឃុំចំណាក្រោម



ផែនទី ៩៖ ផែនទីប្រើប្រាស់ដីលម្អិតក្នុងឃុំចំណារក្រោម



តារាង 22៖ តារាងរាយលម្អិតតាមប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន ឃុំចំណាក្រោម

| ប្រភេទការប្រើប្រាស់ដី | បរិយាយ | ផ្ទៃដីទំហំ(ហ.ត) | ភាគរយ(%) |
|---|---|---|---|
| **ក.ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ** | | **៣១១,២៧** | **១,៣២%** |
| -ដីលំនៅដ្ឋាន ភូមិក្រៅតំបន់បឹងទន្លេសាប | កន្លែងសង់លំនៅឋាន | ៥៤,៩៧ | ០,២៣% |
| -ដីលំនៅដ្ឋាន ភូមិតំបន់១ជុំវិញបឹងទន្លេសាប | កន្លែងសង់លំនៅឋាន | ២៥៦,៣ | ១,០៩% |
| **ខ.ដីកសិកម្ម** | | **១៤ ៩៥២,៥** | **៦៣,២៥%** |
| **ខ.១. ដីស្រែវស្សា** | | **៥ ០៩៦,៩៦** | **២១,៥៦%** |
| -ដីស្រែវស្សាក្រៅតំបន់ជុំវិញបឹងទន្លេសាប | កន្លែងធ្វើស្រែវស្សា | ១ ០៩៤,៧៧ | ៤,៦% |
| -ដីស្រែវស្សាតំបន់១ជុំវិញបឹងទន្លេសាប | កន្លែងធ្វើស្រែវស្សា | ៣ ៩០២,៣២ | ១៦,៥៣% |
| -ដីស្រែវស្សាតំបន់២ជុំវិញបឹងទន្លេសាប | កន្លែងធ្វើស្រែវស្សា | ៩៩,៨៧ | ០,៤២% |
| **ខ.២. ដីស្រែប្រាំង** | | **៨ ២៦៧,៣** | **៣៤,៩៧%** |
| -ដីស្រែប្រាំងតំបន់១ជុំវិញបឹងទន្លេសាប | កន្លែងធ្វើស្រែប្រាំង | ៦៦១,១ | ២,៧៩% |
| -ដីស្រែប្រាំងតំបន់២ជុំវិញបឹងទន្លេសាប | កន្លែងធ្វើស្រែប្រាំង | ៤ ៨៩៣,៨៨ | ២០,៧៣% |
| -ដីស្រែប្រាំងតំបន់៣ជុំវិញបឹងទន្លេសាប | កន្លែងធ្វើស្រែប្រាំង | ២ ៧១២,២៩ | ១១,៤៧% |
| **ខ.៣. ដីស្រែប្រាំងនិងស្រែវស្សា** | | **១ ៥៨៨,២២** | **៦,៧១%** |
| -ដីស្រែប្រាំង និងស្រែវស្សាតំបន់៣ជុំវិញបឹងទន្លេសាប | កន្លែងធ្វើស្រែប្រាំងនិងវស្សា | ១ ៥៨៨,២២ | ៦,៧១% |
| **គ.ដីព្រៃ/គម្របព្រៃ** | | **៤ ៥៤២,២៣** | **១៩,២១%** |
| -ព្រៃគុម្ពោត | ព្រៃគុម្ពោតដុះរាយប៉ាយ | ៣៥,២៧ | ០,១៥% |
| -ព្រៃល្បោះ | តំបន់ទេសចរណ៍ធម្មជាតិ | ២៨,៣៨ | ០,១២% |
| -ព្រៃលិចទឹក | ព្រៃលិចទឹក | ៤ ៤៦៥,១៥ | ១៨,៩៤% |
| **ឃ.ផ្ទៃទឹកនិងខ្សែទឹក** | | **៣ ៨៣៥,៥២** | **១៦,២៣%** |
| -ស្រះ | ផ្គត់ផ្គង់ទឹកប្រើប្រាស់ | ៣២,៨៦ | ០,១៤% |
| -បឹង | ផ្គត់ផ្គង់ទឹកប្រើប្រាស់ | ២៧១,២១ | ១,១៥% |
| -អាងស្តុកទឹក | អាងស្តុកទឹក | ៣ ៥៣១,៤៥ | ១៤,៩៣% |
| **ផ្ទៃដីឃុំសរុប** | | **២៣ ៦២៨** | **១00%** |

### ក. ដីលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

**-ដីលំនៅឋាន ភូមិ៖**

ដីលំនៅឋាន ភូមិ គឺជាដីដែលត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែនៅជុំវិញ ។ នៅក្នុងឃុំចំណាក្រោមដីលំនៅឋានភូមិ មានផ្ទៃដីសរុបទំហំ ៣១១,២៧ហិកតា ដែលក្នុងនោះមានផ្ទៃដីទំហំ ៥៤,៩៧ ហិកតា ស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប និងផ្ទៃដីទំហំ ២៥៦,៣ហិកតា ស្ថិតក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីលំនៅឋាន ភូមិ នៅឃុំចំណាក្រោមភាគច្រើនស្ថិតនៅសងខាងតាមបណ្តោយផ្លូវ

ជាតិលេខ៦ ក្នុងនោះមួយផ្នែកតូចនៅខាងជើងផ្លូវជាតិលេខ៦ ជាដីលំនៅឋាន ភូមិ ស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប មានចំនួន ០៣ភូមិ គឺភូមិសណ្តាន់ ភូមិព្រះនង្គ័ល និងភូមិលៀប ព្រមទាំងមួយផ្នែកទៀតនៅតាមបណ្តោយសងខាងផ្លូវជាតិលេខ៦ដែលមានចំនួន ៧ភូមិ គឺភូមិជីអាប ភូមិស្ពានគ្រង ភូមិចំណាក់ ភូមិនាងនយ ភូមិស្វាយអៀភូមិសំព័រ និងភូមិស្រីរងិត ដែលក្នុងនោះផ្នែកខាងជើងផ្លូវជាតិលេខ៦ស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប និងផ្នែកខាងត្បូងផ្លូវជាតិលេខ៦ ស្ថិតក្នុងដីតំបន់១ជុំវិញបឹងទន្លេសាប ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចំណាក្រោមនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីលំនៅឋាន ភូមិទាំងអស់ ជាតំបន់ទំនាបខ្ពស់រាបស្មើដូចទឹករលក មានប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ និងដីល្បាយខ្សាច់ពណ៌ខ្មៅ ។ ដីលំនៅឋាន ភូមិត្រូវបានប្រើប្រាស់ជាដីដែលកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) មិនត្រូវបានធ្វើការចុះបញ្ជីជាលក្ខណៈប្រព័ន្ធរួចរាល់នៅឡើយទេ ។

រូបភាព 5៖ លំនៅឋាន ភូមិ

| | |
|---|---|
|  |  |
| ដីលំនៅឋាន ភូមិក្រៅតំបន់ | ដីលំនៅឋាន ភូមិក្នុងតំបន់១ |

## ខ. ដីកសិកម្ម

### ខ.១.ដីស្រែវស្សា៖

នៅក្នុងឃុំចំណាក្រោម ដីស្រែវស្សាភាគច្រើននៅសងខាងផ្លូវជាតិលេខ៦ ក្នុងនោះមានមួយផ្នែកនៅខាងជើងផ្លូវជាតិលេខ៦ ជាដីស្រែវស្សាស្ថិតនៅក្រៅតំបន់ការពារជុំវិញបឹងទន្លេសាបមានផ្ទៃដីទំហំ១០៩៤,៧៧ហិកតា និងមួយផ្នែកនៅខាងត្បូងផ្លូវជាតិលេខ៦ឆៀងខាងលិច ជាដីស្រែវស្សាស្ថិតនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានផ្ទៃដីទំហំ ៣ ៩០២,៣២ហិកតា។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំបចំណាក្រោមនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែវស្សាទាំងអស់ ជាតំបន់ជម្រាលតិច មានប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ និងដីល្បាយខ្សាច់ពណ៌ខ្មៅ ។ ដីស្រែវស្សា ដែលស្ថិតនៅក្រៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ ។ ដីស្រែវស្សាទាំងនេះមានមួយផ្នែកនៅក្បែរៗជាប់នឹងដីលំនៅឋាន ភូមិ ក្រោយពីច្រូតកាត់ស្រូវរួច ប្រជាពលរដ្ឋនៅក្នុងឃុំតែងនាំគ្នាដាំដំណាំរួមផ្សំថែមទៀតរួមមានដូចជា ពោត សណ្តែក ឪឡឹក និងបន្លែគ្រប់មុខជាដើម។ល។ ហើយដីទាំងនេះមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង និងអាងស្តុកទឹក៣០កញ្ញា ដែលមានទំនប់បង្ហៀរស្នាក់ទឹកស្ទឹងស្ទោងនៅក្នុង

ស្រុកស្ទោង ដែលនាំទឹកមកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេ ០១ខ្សែ គឺ ប្រឡាយ៣០កញ្ញា ព្រមទាំងអាងទឹកដែលមានក្នុងឃុំ បឹងធម្មជាតិ និងស្រះ ។

**-ដីស្រែវស្សាក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងត្បូងនៃឃុំ មានផ្ទៃដីទំហំ ៩៩,៨៧ ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំបចំណាក្រោមនៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ដីស្រែវស្សានេះ ជាតំបន់ជម្រាលតិច និងជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗដីកណ្តេងពណ៌ខ្មៅ និងដីល្បាយខ្សាច់ពណ៌ខ្មៅ ដីស្រែវស្សាស្ថិតក្នុងតំបន់២ជុំវិញបឹងទន្លេសាប គឺជាដីសាធារណៈរបស់រដ្ឋ ដោយប្រជាពលរដ្ឋមានសិទ្ធិត្រឹមអាស្រ័យផលតែប៉ុណ្ណោះ ដោយមិនមានសិទ្ធិក្នុងការចាត់ចែងនោះឡើយ ។ ដីស្រែវស្សានៅក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង អាងស្តុកទឹក៣០កញ្ញាដែលមានទំនប់បង្វៀរស្ទាក់ទឹកស្ទឹងស្ទោង នៅក្នុងស្រុកស្ទោង ដែលនាំទឹកមកពីភាគខាងជើងមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែគឺ ប្រឡាយ៣០កញ្ញា ព្រមទាំងអាងទឹកដែលមានក្នុងឃុំ បឹងធម្មជាតិ និងស្រះ ។

រូបភាព 6៖ ដីស្រែវស្សា

|  |  |
|---|---|
| ដីស្រែវស្សាក្រៅតំបន់ | ដីស្រែវស្សាតំបន់១ |

## ខ.២.ដីស្រែប្រាំង

**-ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦ ដែលមានទំហំផ្ទៃដីចំនួន ៦៦១,១ហិកតា។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចំណាក្រោមនៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ដីស្រែប្រាំងទាំងអស់ជាតំបន់ជម្រាលតិច និងជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ និងដីល្បាយខ្សាច់ពណ៌ខ្មៅ ដែលត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ(ដីកម្មសិទ្ធិឯកជន) ហើយមិនទាន់ត្រូវបានដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធនៅឡើយទេ ។ ដីស្រែប្រាំងនៅក្នុងតំបន់១ជុំវិញបឹងទន្លេសាបនេះ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ទន្លេសាប និងអាងស្តុកទឹក ៣០កញ្ញា ដែលមានទំនប់បង្វៀរស្ទាក់ទឹកស្ទឹងស្ទោង នៅក្នុងស្រុកស្ទោង ដែលនាំទឹកពីភាគខាងជើងឆៀងខាងកើតមកស្រោចស្រពតាមរយៈប្រឡាយមេមួយខ្សែគឺ ប្រឡាយ៣០កញ្ញា ព្រមទាំងអាងទឹកដែលមានក្នុងឃុំ បឹងធម្មជាតិនិងស្រះ ។

**-ដីស្រែប្រាំងក្នុងតំបន់២ ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦ ដែលមានទំហំផ្ទៃដីសរុប ៤ ៨៩៣,៨៨ ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចំណាក្រោមនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងទាំងអស់ ជាតំបន់ជម្រាលតិច និងជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ និងដីល្បាយខ្សាច់ពណ៌ខ្មៅ គឺជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាបនេះ មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ទន្លេសាប និងអាងស្តុកទឹក៣០កញ្ញា ដែលមានទំនប់បង្ហៀរស្ទាក់ទឹកស្ទឹងស្ទោងនៅក្នុងស្រុកស្ទោង ដែលនាំទឹកពីភាគខាងជើងឆៀងខាងកើត មកស្រោចស្រពតាមរយៈប្រឡាយមេមួយ ខ្សែគឺ ប្រឡាយ៣០កញ្ញា ព្រមទាំងអាងទឹកដែលមានក្នុងឃុំ បឹងធម្មជាតិនិងស្រះ ។

**-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងតំបន់ការពារព្រៃលិចទឹកនៅភាគខាងត្បូងឃុំ មានផ្ទៃដីសរុបចំនួន ២៧១២,២៩ហិកតា ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចំណាក្រោមនៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីស្រែប្រាំងទាំងអស់ជាតំបន់ជម្រាលតិចបន្តុហូតដល់បឹងទន្លេសាប និងជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ និងដីល្បាយខ្សាច់ពណ៌ខ្មៅជាដីសាធារណៈរបស់រដ្ឋ ស្ថិតក្នុងតំបន់ដែនព្រៃលិចទឹកដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទបន្ថែមទៀត ។ ករណីដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ ជាដីអាស្រ័យផលពិតប្រាកដរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងឃុំមែន ត្រូវស្នើសុំធ្វើការដោះស្រាយក្នុងការផ្តល់ដីស្រែនៅក្នុងតំបន់នេះ ពីរាជរដ្ឋាភិបាល ដោយឈរលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល ហើយប្រសិនបើមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យឃ្មៀលដីនេះជូនមែន ក៏ដីទាំងនេះមិនមែនជាកម្មសិទ្ធិរបស់ប្រជាជនដែរ ប្រជាជនគ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលតែប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ដីស្រែប្រាំងនៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានប្រភពទឹកស្រោចស្រពពីទឹកភ្លៀង ទឹកទន្លេសាប អាងទឹក បឹងនិងស្រះ ។

រូបភាព 7៖ ដីស្រែប្រាំង

| | |
|---|---|
|  |  |
| ទិដ្ឋភាពដីស្រែប្រាំងតំបន់១ | ទិដ្ឋភាពដីស្រែប្រាំងតំបន់២ |

### ខ.៣.ដីស្រែប្រាំង និងស្រែវស្សា

នៅក្នុងឃុំចំណាក្រោម ដីស្រែប្រាំង និងស្រែវស្សាមានផ្ទៃដីសរុបទំហំ ១ ៥៨៨,២២ហិកតា ស្ថិតនៅភាគខាងត្បូងនៃឃុំក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ។ បើផ្អែកទៅតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចំណាក្រោមនៃរបាយការណ៍វិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថាន ដីស្រែប្រាំង និងវស្សានេះ ជាតំបន់ជម្រាលតិចពីជើងមកត្បូង និងជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ និងដីល្បាយខ្សាច់ពណ៌ខ្មៅ ។ ដីស្រែប្រាំងនិងវស្សា គឺជាដីសាធារណៈរបស់រដ្ឋ ដែលត្រូវការពារ ក្នុងករណីដីស្រែប្រាំង និងវស្សានៅក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ ជាដីអាស្រ័យផលពិតប្រាកដរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងឃុំចំណាក្រោមពិតមែន ត្រូវស្នើសុំការដោះស្រាយក្នុងការផ្តល់ដីស្រែនៅក្នុងតំបន់នេះ ពីរាជរដ្ឋាភិបាល ដោយឈរលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ញានានារបស់រាជរដ្ឋាភិបាល ហើយប្រសិនបើមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យឃ្មៀលដីនេះជូនមែន ក៏ដីនេះមិនមែនជាកម្មសិទ្ធិរបស់ប្រជាជនដែរ ប្រជាជនគ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងអ្វីនោះឡើយ។ ដីស្រែប្រាំងនិងវស្សានេះ ត្រូវបានប្រើប្រាស់ប្រភពទឹកស្រោចស្រពពីទឹកភ្លៀងនិងទន្លេសាបព្រមទាំងអាងទឹកដែលមានក្នុងឃុំ បឹងនិងស្រះ ។

រូបភាព ៥៖ ដីស្រែប្រាំង និងស្រែវស្សា



### គ. ដីព្រៃ/តម្រូបព្រៃ

**-ព្រៃគុម្ពោត**

នៅក្នុងឃុំចំណាក្រោម ព្រៃគុម្ពោតមានផ្ទៃដីសរុបទំហំ ៣៥,២៧ ហិកតា ដែលក្នុងនោះបានបែងចែកជា២ប្រភេទ គឺប្រភេទដីព្រៃគុម្ពោតក្រៅតំបន់ជុំវិញបឹងទន្លេសាប ស្ថិតនៅភាគខាងជើងចេញពីផ្លូវជាតិលេខ៦ មានផ្ទៃដីទំហំ ៤,៣២ហិកតា និងប្រភេទព្រៃគុម្ពោតស្ថិតក្នុងតំបន់១ជុំវិញបឹងទន្លេសាប នៅភាគខាងត្បូងនៃឃុំមានផ្ទៃដីទំហំ ៣០,៩៥ហិកតា ដែលជាព្រៃនៅលើដីទួលជាច្រើនកន្លែងដាច់ពីគ្នាក្នុងតំបន់វាលស្រែ មានដុះដើមឈើមួយចំនួនដូចជា ក្រសាំង អំពិល កកោះ តាសេក ចម្រៀក និងត្រយឹងជាដើម និងមានដើមល្ពាក់ ញិញ ព្រិច ភ្លូ និងដើមខ្លុងតែ្បងៗលៗ ដីព្រៃគុម្ពោតនេះ ភាគច្រើនជាដីទួលបុរាណស្ថានជាកម្មសិទ្ធិរបស់រដ្ឋ មាន ១០ទីតាំង និងក្រៅពីនេះ ជាដីកម្មសិទ្ធិឯកជនមាន ១០ទីតាំង គ្រប់គ្រងនិងកាន់កាប់ដោយប្រជាពលរដ្ឋ ។ បើផ្អែកតាមដ្យាក្រាម

ពំនុះកាត់ទទឹងឃុំចំណាក្រោម នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីព្រៃគុម្ពោត គឺជាតំបន់ទំនាបមធ្យម ដោយមានប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ និងដីល្បាយខ្សាច់ពណ៌ខ្មៅ ។

រូបភាព ៩៖ ព្រៃគុម្ពោត



**-ព្រៃល្បោះ៖**

នៅក្នុងឃុំចំណាក្រោម ព្រៃល្បោះមានផ្ទៃដីសរុបចំនួន ២៨,៣៨ហិកតា និងមានតែមួយកន្លែងស្ថិតនៅភាគខាងត្បូងនៃឃុំក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ដែលមានដុះប្រភេទឈើខ្លុងត្បែង ត្រាច កកោះ ដង្កៀបក្តាម លៀង ចំបក់ ត្រសេក ផ្ចឿក ធ្លក រកា រាំង កណ្តោល ច្រេស និងស្វាយព្រៃ ដីព្រៃនេះ ជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋដែលត្រូវការពារសម្រាប់ ជាតំបន់ទេសចរណ៍ធម្មជាតិ ។ បើផ្អែកតាមដ្យាក្រាមពំនុះកាត់ទទឹងឃុំចំណាក្រោម នៃរបាយការណ៍វិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ដីព្រៃល្បោះ ជាតំបន់ជម្រាលទាប មានប្រភេទដីកណ្តេងពណ៌ខ្មៅ ។

រូបភាព 10៖ ព្រៃល្បោះ



-ព្រៃលិចទឹកៈ

នៅក្នុងឃុំចំណាក្រោម មានផ្ទៃដីព្រៃលិចទឹកមានមួយកន្លែង ដែលស្ថិតដីតំបន់៣ជុំវិញបឹងទន្លេសាបដែលផ្ទៃដីសរុបទំហំ ៤៤៦៥,១៥ហិកតា នៅខាងភាគត្បូងព្រំប្រទល់នៃឃុំ ដែលមានវិសាលភាពធំធេងក្នុងភូមិសាស្ត្រឃុំនៅជាប់ព្រំប្រទល់ឃុំផាតសណ្តាយ ស្រុកកំពង់ស្វាយ ។ ព្រៃលិចទឹកនេះជាការគ្រប់គ្រងនិងជាកម្មសិទ្ធិរបស់ដែនសមត្ថកិច្ចជលផល ។

រូបភាព 11៖ ព្រៃលិចទឹក



យ. ផ្ទៃទឹក និងខ្សែទឹក

-ស្រះទឹកៈ

នៅក្នុងឃុំចំណាក្រោម មានស្រះទឹកចំនួន៥៦ មានទំហំផ្ទៃដី ៣២,៨៦ហិកតា ដែលអាចប្រើប្រាស់ទឹកសម្រាប់ការស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀត។ ស្រះទឹកទាំងនេះមាននៅក្រៅតំបន់ជុំវិញបឹងទន្លេសាបនិងមានមួយចំនួនស្ថិតនៅក្នុងតំបន់១ និងតំបន់៣ជុំវិញបឹងទន្លេសាបក្នុងភូមិសាស្ត្រស្រែប្រាំងនិងស្រែវស្សា និងក្បែរតំបន់ដីភូមិក្បែរផ្ទះនិងដីចម្ការជាដើម ។ ស្រះដែលនៅក្រៅដីតំបន់ជុំវិញបឹងទន្លេសាបមានទំហំតែ ៣,៨៦ហិកតាសម្រាប់ការប្រើប្រាស់ទឹកស្អាតក្នុងភូមិ និងទឹកគោក្របបីតិចតួច ។ ចំណែកស្រះដែលស្ថិតក្នុងដីតំបន់១ជុំវិញបឹងទន្លេសាបវិញមានទំហំ ២៥,៣៤ហិកតា សម្រាប់ប្រើប្រាស់ការស្រោចស្រពដីស្រែវស្សានិងស្រែប្រាំង ដែលស្ថិតក្បែរស្រែរបស់ពួកគាត់ (កម្មសិទ្ធិឯកជន) ។ ស្រះទឹកដែលបានជីកនៅដីតំបន់៣ជុំវិញបឹងទន្លេសាបនេះ នៅភាគខាងត្បូងនៃឃុំនៅក្បែរស្រែប្រាំង និងមានខ្លះក្នុងដីស្រែប្រាំងដែលម្ចាស់ជីក មានផ្ទៃដីទំហំ ៣,៦៦ហិកតា សម្រាប់ការស្រោចស្រព និងដាក់សម្រាស់យកត្រីពេលទឹកស្រកទៅវិញ ។ ដីស្រះដែលបានជីកនេះ ត្រូវបានប្រើប្រាស់សម្រាប់ជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព 12៖ ស្រះទឹក

|  |  |
| --- | --- |
| ស្រះទឹកក្រៅតំបន់ជុំវិញបឹងទន្លេសាប | ស្រះទឹកក្នុងតំបន់ជុំវិញបឹងទន្លេសាប |

**-បឹង**

នៅក្នុងឃុំចំណាក្រោម មានបឹងសរុបចំនួន ៧៥បឹង ផ្ទៃដីទំហំ ២៧១,២១ហិកតា ដែលមានច្រើនជាងគេនៅតំបន់ស្រែប្រាំងក្នុងដីព្រៃលិចទឹកតំបន់៣ជុំវិញបឹងទន្លេសាប ក្នុងនោះក៏មានដីបឹងអភិរក្សសហគមន៍នេសាទ (ស្ពានគ្រងអភិវឌ្ឍន៍)មួយកន្លែងផងដែរ ។ បឹងធម្មជាតិទាំងអស់នេះ ជាដីសាធារណៈរបស់រដ្ឋ បច្ចុប្បន្នត្រូវបានប្រើប្រាស់ សម្រាប់ការស្រោចស្រពដំណាំកសិកម្ម ជាពិសេសស្រែប្រាំង និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ។

រូបភាព 13៖ បឹង



**-អាងស្តុកទឹក**

នៅក្នុងឃុំចំណាក្រោម មានអាងស្តុកទឹកជារបស់ឯកជន និងអាងស្តុករបស់សហគមន៍ចំនួន ៣៦កន្លែង ដែលមានក្នុងដីតំបន់១ ២ និងតំបន់៣ជុំវិញបឹងទន្លេសាប ដែលមានផ្ទៃដីសរុបចំនួន ៣ ៥៣១,៤៥ហិកតា ដែលស្ទើរតែគ្របដណ្តប់លើផ្ទៃដីស្រែប្រាំងនៅភាគកណ្តាលឃុំ ក្នុងនោះមានដីអាងស្តុកទឹករបស់សហគមន៍ចំនួន១០ សម្រាប់ធ្វើការអភិរក្ស និងការពារពូជត្រី ។ តាមការបង្ហាញពីមន្ត្រីកសិកម្មខេត្តកំពង់ធំ បានឲ្យដឹងថា ដីអាងនេះ

ត្រូវបានការហាមឃាត់ និងលុបបំបាត់តាំងពីឆ្នាំ២០១១មកម្លេះ ដើម្បីទប់ស្កាត់ការកាប់រានដីព្រៃលិចទឹកក្នុងតំបន់នេះ តែក្រោយៗមកការជីកអាងនេះក៏លែងមានឃើញតទៅទៀតដែរ ហើយអាងស្តុកនេះក៏មានជាកន្លែងជម្រកត្រី និងខ្លះទៀតសម្រាប់ប្រើប្រាស់ទឹកសម្រាប់ស្រោចស្រពដល់ស្រែប្រាំង និងជាប្រភពធនធានមច្ឆាផងដែរ ។

រូបភាព 14៖ អាងស្តុកទឹក



ពាក់ព័ន្ធបញ្ហាផ្សេងៗ នៅក្នុងការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម តាមរយៈការសម្ភាសន៍លោកមេឃុំបានឱ្យដឹងថា មានប្រជាពលរដ្ឋចំនួន ៥៥គ្រួសារ មិនមានដីសម្រាប់សង់លំនៅឋាន និង ១៤៨គ្រួសារ មិនមានដីធ្វើរបរកសិកម្មឡើយ។ ក្នុងចំណោមប្រជាពលរដ្ឋទាំងនេះ មានមួយចំនួនរស់នៅលើដីចិញ្ចើមផ្លូវ ដីកម្មសិទ្ធិរបស់គេផ្សេង ព្រមទាំងមួយចំនួនទៀត ពួកគាត់រស់នៅជាមួយឪពុកម្តាយ។ ចំណែកបញ្ហាទំនាស់ នៅក្នុងការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោមវិញ ពុំមានចេញជារូបភាពធំដុំគួរឱ្យកត់សម្គាល់ឡើយ ទោះបីដីក្នុងឃុំទាំងមូល មិនទាន់ដំណើរការចុះបញ្ជីកាន់កាប់ដីជាលក្ខណៈប្រព័ន្ធក៏ដោយ ។

## ១.៣.២. ផលិតកម្មកសិកម្ម

### ក. ផលិតកម្មដំណាំស្បៀង

ផលិតកម្មដំណាំស្បៀងនៅក្នុងឃុំចំណាក្រោម បានផ្តោតជាសំខាន់ទៅលើផលិតកម្មដំណាំស្រូវ ហើយដំណាំនេះបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ឃុំដោយសារផលិតផលស្រូវក្រៅពីប្រជាពលរដ្ឋបានទុកផ្គត់ផ្គង់សម្រាប់ការហូបចុក និងមាននៅសល់បានទុកលក់ សម្រាប់បំពេញតម្រូវការចាយវាយចាំបាច់ក្នុងជីវភាពរស់នៅផងដែរ ។ ចំពោះដំណាំជួយធ្វើឲ្យជីវភាពប្រជាពលរដ្ឋមានសេដ្ឋកិច្ចកើនឡើងជាលំដាប់ក្នុងមូលដ្ឋាន ។ នៅក្នុងឃុំចំណាក្រោមមានផ្ទៃដីធ្វើស្រែសរុបចំនួន ១៤ ៩៥២,៤៨ហិកតា ដែលក្នុងឃុំនេះមានប្រភេទដីជាល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌ខ្មៅ ដីកណ្តេងពណ៌ខ្មៅប្រផេះ និងដីកណ្តេងល្បាប់ពណ៌ខ្មៅហើយប្រជាពលរដ្ឋនិយមដាំដុះដំណាំស្រូវដូចជា៖ ផ្ការំដួល ផ្ការមៀត និងស្រូវ៨៥ ៥០៤ ៥១៥៤ ។ ។ ជាទូទៅនៅក្នុងឃុំចំណាក្រោម ប្រជាពលរដ្ឋទទួលបានទិន្នផលស្រូវវស្សាជាមធ្យម ២តោន/ហ.ត និងស្រូវប្រាំងជាមធ្យម ០៥តោន/ហ.ត ហើយនៅក្នុងឆ្នាំ២០១៧នេះ ឃុំទទួលបានទិន្នផលស្រូវសរុបចំនួន ៥១ ៥៩៣តោន

ដែលក្នុងនោះទិន្នផលស្រូវវស្សាមានចំនួន ១០ ១៩៤ តោន និងស្រូវប្រាំង ៤១ ៣៩៩ តោន ។ ប្រជាពលរដ្ឋបានទុកស្រូវសម្រាប់បរិភោគ ៨៥ភាគរយ ក្នុងចំណោមស្រូវដែលរក្សាទុក ៧០ភាគរយ ស្មើនឹង ៣០ ៦៩៨តោន និងទុកពូជ ១៥ភាគរយ នៃស្រូវរក្សាទុក ៧០ភាគរយ ស្មើនឹង ៥ ៤១៧តោន និងលក់ចេញ ៣០ភាគរយ នៃស្រូវសរុបចំនួន ១៥ ៤៧៨តោនបានធ្វើការលក់ចេញក្នុងតម្លៃជាមធ្យម ១ ០០០រៀល/គ.ក្រ ដែលទទួលបានចំណូលសរុបប្រមាណ ៥១ ៥៩៣ ០០០ រៀល ។

តារាង 23៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| -ការដាំដុះដំណាំកសិកម្មទទួលបានផលល្អតែមានតម្លៃទាប<br>- ការប្រែប្រួលអាកាសធាតុ(រាំងស្ងួត ឬ ទឹកជំនន់)<br>- តម្លៃស្រូវមិនទៀងទាត់<br>- សម្ភារ និងឧបករណ៍កសិកម្មមានតម្លៃខ្ពស់<br>- ការស្រាវជ្រាវផ្នែកកសិកម្មនៅមានកម្រិត<br>- គ្មានសមាគមន៍ផ្នែកអភិវឌ្ឍន៍កសិកម្ម<br>- ទីផ្សារស្រូវផ្អែកខ្លាំងលើពូជស្រូវនាំចូលពីប្រទេសជិតខាង<br>- ខ្វះប្រព័ន្ធស្រោចស្រព និងប្រភពទឹក ប្រើប្រាស់<br>- ការផ្សព្វផ្សាយពូជស្រូវ១០មុខនៅមានកម្រិត<br>- មានឈ្មួញ ឬ អាជីវករ យកជីគីមីទៅលក់បណ្តាក់តាមមូលដ្ឋានដោយគ្មានច្បាប់អនុញ្ញាត<br>- ជីគីមីនិងថ្នាំពុលខ្លះមិនទាន់បកប្រែជាភាសាខ្មែរ<br>- ខ្វះមន្ត្រីផ្សព្វផ្សាយនៅតាមឃុំ | -នឹងមានប្រភពទឹកស្រោចស្រព<br>-ទិន្នផលបានខ្ពស់ និងមានតម្លៃថ្លៃជាងមុន<br>-នឹងមានការជីក ស្តារត្រពាំង ចំណាក្រោមទឹក ប្រើប្រាស់ម៉ាស៊ីនបូមទឹកជាជំនួយ<br>- ធ្វើការជម្រុញឲ្យកសិករលើកប្រព័ន្ធភ្លឺស្រែ<br>- បិទទំនប់ស្ទាក់ទឹកតាមដងអូរ ឬ ស្នាមភ្លោះ<br>-ផ្តល់ជូនពូជស្រូវដែលមានទិន្នផលខ្ពស់ និងតម្លៃនៅលើទីផ្សារ<br>-ប្រជាពលរដ្ឋប្រើប្រាស់សម្ភារទំនើប និងមានតម្លៃថោកជាងមុន |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 15៖ ដំណាំស្រូវ

|  |  |
|---|---|
| ស្រូវកំពុងលូតលាស់ | ស្រូវទុំ |

### ខ. ផលិតកម្មដំណាំរួមផ្សំ

ផលិតកម្មដំណាំរួមផ្សំនៅក្នុងឃុំចំណាក្រោមមានដូចជា៖ បន្លែ ពោត ស្ពៃ ត្រកួន ត្រសក់ សណ្តែក ននោងល្ពៅ ដែលភាគច្រើន ប្រជាពលរដ្ឋធ្វើការដាំដុះលក្ខណៈគ្រួសារនៅជុំវិញដីលំនៅឋាន ជុំវិញត្រពាំងបឹងបួរ និងកន្លែងដែលមានប្រភពទឹក ជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗដីកណ្តេងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌ខ្មៅ តែមិនមានទិន្នន័យអំពីទំហំផ្ទៃដីនោះទេ ដែលទទួលបានការស្រោចស្រពពី ទឹកអណ្តូង ទឹកភ្លៀង ទឹកស្រះ ហើយពួកគាត់ធ្វើការដាំដុះ ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃនិងលក់ដូរបន្តិចបន្តួច។ ចំណែកទិន្នផលដែលទទួលបានអាស្រ័យទៅលើការថែទាំ ហើយសម្រាប់ការដាំដំណាំនេះដែរ ប្រជាពលរដ្ឋក៏ជួបនឹងបញ្ហាមួយចំនួនដូចជា៖ សត្វល្អិត ជម្ងឺ និងមិនទាន់មានបច្ចេកទេសគ្រប់គ្រាន់ក្នុងការដាំដុះដំណាំទាំងនោះទេ ។

តារាង 24៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ការប្រែប្រួលអាកាសធាតុ(រាំងស្ងួត ឬ ទឹកជំនន់)<br>- ខ្វះប្រភពទឹកស្រោចស្រពដំណាំ<br>- តម្លៃកសិផលមិនមានស្ថេរភាព<br>- ប្រើប្រាស់ជីគីមី និងថ្នាំកសិកម្មមិនត្រឹមត្រូវតាមបច្ចេកទេស<br>- មិនទាន់មានបច្ចេកទេសដាំដុះដំណាំស្រូវ<br>- ខ្វះបណ្តាញទីផ្សារលក់ផលិតផល | - ស្តារនិងជួសជួលចំណាក្រោមទឹកដែលមានស្រាប់<br>- ធ្វើកសិកម្មតាមកិច្ចសន្យា<br>- បណ្តុះបណ្តាលវិជ្ជាជីវះ និង បច្ចេកទេសក្នុងការប្រើប្រាស់ថ្នាំកសិកម្ម<br>- ចងក្រងក្រុមផលិតស្រូវ សម្រាប់ទីផ្សារ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

### គ. ផលិតកម្មឧស្សាហកម្ម

នៅឃុំចំណាក្រោម មិនមានប្រជាពលរដ្ឋធ្វើការដាំដុះដំណាំឧស្សាហកម្មនោះទេ ដោយសារនៅក្នុងឃុំនេះជាតំបន់ទំនាបទាបលិចទឹក មិនសមស្រេបទៅនឹងការដាំដុះដំណាំឧស្សាហកម្មនោះទេ ។

## ១.៣.៣. ធនធានធម្មជាតិ

### ក. ធនធានព្រៃឈើ

បច្ចុប្បន្ននៅក្នុងឃុំចំណាក្រោម មានព្រៃឈើមួយចំនួនដូចជា ព្រៃគុម្ពោតទំហំ៣ ៥,៣១ហ.ត ព្រៃល្បោះទំហំ ២៨,៣៨ហ.ត ដែលមានប្រភេទឈើមួយចំនួនដូចជា៖ ត្បែង ត្រាច កកោះ ដង្កៀបក្តាម ល្បៀង ចំបក់ ធ្លកផ្ចឿក ត្រសេក រកា រាំង កណ្តោល ច្រេស និងស្វាយព្រៃជាដើម។ល។ ទោះបីនាបច្ចុប្បន្ននេះ នៅឃុំចំណាក្រោមមានព្រៃឈើតិចតួចមែន តែឃុំមានតំបន់ដីព្រៃលិចទឹកចំនួន ៤ ៤៦៥,១៥ហ.ត ស្មើនឹង ១៨,៩៤ភាគរយ ដែលសំបូរទៅដោយដើមរាំង អញ្ចាញ ត្រោះ ភ្នំភ្លើង បបួយ តាសែង បន្លាស្អិត និងទ្រនំអារអូត ដែលរាជរដ្ឋាភិបាលបានកំណត់ជាដែនការពារដាច់ខាត សម្រាប់ការធានាបាននូវនិរន្តរភាពបរិស្ថាន និងប្រព័ន្ធជីវចម្រុះបឹងទន្លេសាបជាពិសេសធានាជម្រកមច្ឆាជាតិ របបជលសាស្ត្រ ការសាយភាយនៃល្បាប់ជាដើម ។

តារាង 25៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - ការបាត់បង់ព្រៃឈើ<br>- ការបាត់បង់សត្វព្រៃ<br>- ផ្ទៃដីព្រៃឈើទឹកត្រូវបានបំលែងទៅជាដីកសិកម្ម<br>- ភ្លើងឆេះព្រៃ<br>- កាប់ព្រៃធ្វើ ឧសដុត ធ្វើទ្រើងដំណាំផ្សេងៗ | - នឹងចូលរួមគ្រប់គ្រង ការពារ និងអភិរក្សព្រៃឈើ<br>- ដាំដើមឈើឡើងវិញ<br>- ទប់ស្កាត់ការទន្ទានព្រៃឈើ<br>- ផ្សព្វផ្សាយឲ្យបានទូលំទំលាយពីសារប្រយោជន៍ព្រៃឈើ<br>- បង្កើតសហគមន៍ការពារព្រៃឈើ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

**ខ. ធនធានជលផល**

បច្ចុប្បន្ននៅក្នុងឃុំចំណាក្រោម មានបឹងចំនួន ១៤កន្លែង មានផ្ទៃដីសរុបចំនួន ២៧១,២ហិកតា ដែលស្ថិតនៅផ្នែកខាងត្បូងនៃឃុំ អាងស្តុកទឹកចំនួន ២៣កន្លែង មានផ្ទៃដីសរុបចំនួន ៣ ៥៣១,៤៣ហិកតា ដែលស្ថិតនៅផ្នែកកណ្តាលឃុំ និងស្រះចំនួន ៧៣ ដែលមានផ្ទៃដីចំនួន ៣២,៨៧ហិកតា មាននៅរាយប៉ាយក្នុងភូមិសាស្ត្រឃុំ ដែលភាគច្រើនស្ថិតនៅផ្នែកកណ្តាលនៃឃុំ នៅលាយឡំជាមួយនឹងដីលំនៅឋាន និងតំបន់ស្រែវស្សា។ ចំពោះបឹង អាងនិងស្រះទឹក ទាំងអស់ខាងលើនេះសំបូរទៅដោយធនធានជលផលដូចជា ត្រី ក្តាម ខ្យង ពស់ អន្ទង់ សត្វស្លាប ជាដើម ។ ការនេសាទរបស់ប្រជាជន ជាលក្ខណៈគ្រួសារបានទទួលផលគួរសម សម្រាប់តែហូបចុកនិងលក់ដូរតិចតួចប៉ុណ្ណោះ ម៉្យាងទៀតប្រភេទត្រីខ្លះបានជិតផុតពូជទៅហើយ ដោយសារប្រជាពលរដ្ឋនាំគ្នាប្រើប្រាស់ឧបករណ៍ខុសច្បាប់ ដែលច្បាប់បានហាមឃាត់។ នៅក្នុងឃុំ មានអាងសហគមន៍ចំនួនបីកន្លែង គឺអាងសហគមន៍ស្រីរងិត អាងសហគន៍សណ្តាន់ អាងសហគមន៍គ្រងស្ពាន និងសហគមន៍នេសាទពីរកន្លែង គឺ សហគមន៍នេសាទស្ពានគ្រង និងសហគមន៍អភិវឌ្ឍន៍ខ្សែខ្លែងកក់ធំ និងមានតំបន់អភិរក្សមេពូជត្រី ដែលធនធានជលផលទាំងនោះមានដូចជា៖ ក្តាម ខ្យង ត្រីរ៉ស់ ត្រីឆ្តោរ ត្រីផ្ទក់ ត្រីក្រាញ់ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចង្វា។ល។ ដែលបង្កើតឡើងដោយរដ្ឋបាលជលផល សម្រាប់ធ្វើការអភិរក្សពូជត្រី និងប្រើប្រាស់ទឹក ដែលស្ថិតនៅតំបន់ព្រៃលិចទឹក ។

តារាង 26៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស

| ឧបសគ្គ | ឱកាស |
|---|---|
| - បង្ហូរកាកសំណល់ចូលក្នុងបឹង និងព្រែក<br>- ផ្ទៃបឹង ឬព្រែក អូររាក់<br>- ការហូរច្រោះដីចូលបឹង និងព្រែក<br>- បឹងមួយចំនួនក្លាយជាអាង ឬបឹងដាំឈូក<br>- បឹងមួយចំនួនក្លាយជាស្រែប្រាំង<br>-អូរប្រឡាយចាស់ៗមានសភាពរាក់ចាស់ទ្រុឌទ្រោម<br>- ប្រើឧបករណ៍ខុសច្បាប់ឆក់ត្រី<br>- ត្រីមួយចំនួនជិតនឹងផុតពូជ<br>-កំណើននៃការប្រើប្រាស់ថ្នាំពុល សម្រាប់ធ្វើស្រែ | -ផ្សព្វផ្សាយការទុកដាក់កាកសំណល់ និងជៀសវាងបង្ហូរ កាកសំណល់ចូលក្នុងបឹង និងព្រែក<br>- ធ្វើការស្តារបឹងនិងព្រែកឡើងវិញ<br>- អនុវត្តន៍ច្បាប់ក្នុងការការពារព្រែកនិងបឹង<br>- ធ្វើការផ្សព្វផ្សាយពីច្បាប់ជលផល ឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ<br>- បំផុសការចិញ្ចឹមត្រីតាមលក្ខណៈគ្រួសារ<br>- លែងកូនត្រីចូលក្នុងបឹងធម្មជាតិ<br>- ការពារព្រៃលិចទឹក ដែលមានស្រាប់និងដាំបន្ថែម |

| | |
|---|---|
| ប្រាំងដែលបណ្តាលឲ្យប៉ះពាល់ធនធានផលផល | -សិក្សាពីដំណើរការវិវដ្តរបស់ត្រី ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងនិងថែរក្សា<br>- ពង្រឹងការការពារតំបន់ជម្រកត្រីពងកូន<br>- បង្កើតសហគមន៍នេសាទ<br>- កំណត់ប្រភេទឧបករណ៍នេសាទតាមច្បាប់កំណត់ |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

រូបភាព 16៖ ផលនេសាទ





**គ. ធនធានរ៉ែ**

រ៉ែជាធាតុគីមីធម្មជាតិម៉្យាង មាននៅក្នុងដី ឬនៅក្នុងសិលាដែលអាចឲ្យយើងធ្វើអាជីវកម្មរ៉ែបាន។ នៅក្នុងឃុំចំណាក្រោម គឺមានធនធានថ្ម ដែលស្ថិតនៅភ្នំជីមូលមួយកន្លែង ប៉ុន្តែធនធានថ្មនេះ មិនទាន់មាន ក្រុមហ៊ុនណាធ្វើអាជីវកម្មនូវឡើយទេ មកដល់បច្ចុប្បន្ននេះជាដីកម្មសិទ្ធិដែលគ្រប់គ្រងដោយរដ្ឋ ។

## ១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១. ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

នៅក្នុងឃុំចំណាក្រោម ប្រជាពលរដ្ឋលក់ផលិតផលស្រូវឲ្យឈ្មួញនៅតាមភូមិ ឈ្មួញកណ្តាលនៅស្រុកស្ទោង និងរោងម៉ាស៊ីននៅទីរួមខេត្តកំពង់ធំ រោងម៉ាស៊ីននៅស្រុកស្ទោង ឈ្មួញមកពីប្រទេសវៀតណាម ហើយតម្លៃស្រូវមានភាពខុសគ្នាទៅតាមប្រភេទ និងគុណភាពស្រូវនីមួយៗ ដែលប្រជាពលរដ្ឋតែងតែលក់ស្រូវសើម ១០០% នៅក្នុងនោះសម្រាប់ស្រូវពូជ៨៥ (IR៨៥) និងពូជ៥៤៥១ ក្នុងស្រុកតម្លៃ ៨០០រៀលទៅ១១០០រៀលក្នុងមួយគីឡូក្រាម ចំណែកស្រូវផ្ការំដួល និងស្រូវផ្កាម្លិះវិញមានទីផ្សារក្នុងប្រទេស និងទីផ្សារប្រទេសវៀតណាមដូចគ្នា ដោយលក់ជាស្រូវសើម ១០០ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ឃុំ និងមានតម្លៃ ១០០០ ទៅ ១១០០រៀលក្នុងមួយគីឡូក្រាម ព្រមទាំងស្រូវរាំងជ័យ និងស្រូវនាងគង់ មានទីផ្សារនៅប្រទេសវៀតណាម ហើយប្រជាពលរដ្ឋតែងលក់ស្រូវពួកគាត់សើម ១០០ភាគរយ តាមរយៈឈ្មួញមកទទួលទិញដល់ឃុំដែលមានតម្លៃពី ៧០០ទៅ៩០០រៀលក្នុងមួយគីឡូក្រាម ។

តារាង 27៖ ស្ថិតិផលិតផលស្រូវ និងតម្លៃ

| ល.រ | ប្រភេទផលិតផលស្រូវ | ឯកតា | តម្លៃគិតរៀល | តម្លៃជារៀលទីផ្សារ | |
|---|---|---|---|---|---|
| | | | | ក្នុងស្រុក | ក្រៅប្រទេស |
| ១ | រាំងជ័យ, នាងគង់ | ១គ.ក | ៧០០-៩០០ | | វៀតណាម |
| ២ | ស្រូវរំដួល, ម្លិះ | ១គ.ក | ៩០០-១ ១០០ | | វៀតណាម |
| ៣ | ស្រូវ៨៥(IR៨៥), ៥៤៥១ | ១គ.ក | ៨០០-១ ១០០ | | វៀតណាម |

*ប្រភពទិន្នន័យ៖ CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

### ១.៨.២. ខ្សែសង្វាក់ និងចរាចរផលិតផល

តាមរបាយការណ៍ស្តីពីការវិភាគប្រព័ន្ធកៀ្សត្រ-បរិស្ថានឃុំចំណាក្រោមឆ្នាំ២០១៧ បានឱ្យដឹងថា បច្ចុប្បន្ននៅក្នុងឃុំចំណាក្រោម ការផលិតដំណាំស្រូវរហូតដល់បានផលលក់ចេញគឺ ត្រូវដំណើរការតាមខ្សែសង្វាក់ជាបន្តបន្ទាប់ ដូចជាការផលិតដំណាំស្រូវផ្ការំដួល ដោយចាប់ផ្តើមពីការត្រៀមពូជស្រូវដែលភាគច្រើនបានរក្សាទុកដោយខ្លួនឯង៩៥ភាគរយ និងមានការទិញចូល ០៥ភាគរយ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជីនិងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្តរហូតដល់ ៩៥ ភាគរយ និងច្រូតកាត់ដោយដៃតែ ០៥ភាគរយប៉ុណ្ណោះ ។ ផលស្រូវដែលទទួលបានត្រូវហាលសម្ងួតទុកពូជ ១៥ភាគរយនិងទុកផ្គត់ផ្គង់ការហូបចុកប្រមាណ៨៥ភាគរយ ចំណែកស្រូវនៅសើមដែលសល់ប្រមាណ ១០០ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំបានតម្លៃ ១ ០០០ រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តលក់ឱ្យរោងម៉ាស៊ីនកិនស្រូវយកទៅកិនកែច្នៃជាអង្ករនាំទៅទីផ្សារក្នុងប្រទេស និងទីផ្សារក្រៅប្រទេស ។ ចំពោះស្រូវប្រដេញទឹក(ពូជ៥០៤/៥៤៥១)វិញ ពូជត្រូវបានទិញពីគ្នាឯងក្នុងឃុំ ហើយមានការរៀបចំដី រួមទាំងការថែទាំ មានការដាក់ជីនិងបាញ់ថ្នាំសម្លាប់សត្វល្អិត រហូតដល់ច្រូតកាត់ដែលប្រើដោយគ្រឿងយន្តទាំងអស់ ១០០ភាគរយ ចំណែកផលស្រូវដែលទទួលបានត្រូវបានហាលសម្ងួតទុកពូជ១០ភាគរយ និងលក់៩០ភាគរយ ចំណែកផលស្រូវនៅសើមលក់ ១០០ភាគរយ យកទៅលក់ឱ្យឈ្មួញនៅតាមដងផ្លូវក្នុងឃុំ បានតម្លៃត្រឹមតែ ៨០០រៀលក្នុងមួយគីឡូក្រាម ហើយឈ្មួញបន្តយកទៅលក់ឱ្យទីផ្សារ ប្រទេស វៀតណាម ។

រូបភាព 17៖ ផលិតផលកសិកម្ម





ការលក់ផលស្រូវរបស់ប្រជាកសិករ

ដ្យាក្រាម 4៖ គំនូសតាងនៃការលំហូផលិតផលកសិកម្ម នៅក្នុងភូមិ និង ការប្រើប្រាស់






### ១.៤.៣. ឧបសគ្គ និងឱកាស

តារាង 28៖ តារាងអធិប្បាយពីឧបសគ្គ និងឱកាស ទីផ្សារនិងខ្សែសង្វាក់ផលិតផល

| ឧបសគ្គ | ឱកាស |
|---|---|
| - ទីផ្សារមានការប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង<br>- គុណភាពស្រូវមិនទាន់ស្របតាមស្តង់ដាសម្រាប់ធ្វើការនាំចេញ<br>- ទីផ្សារស្រូវក្នុងស្រុកនូវមានកម្រិត<br>- តម្លៃស្រូវមិនទៀងទាត់(អាស្រ័យលើឈ្មួញ)<br>- ប្រើប្រាស់ពូជស្រូវវៀតណាម | - អាចប្រកួតប្រជែងតម្លៃជាមួយប្រទេសជិតខាង<br>- ក្រុមហ៊ុននាំចេញស្រូវរបស់កម្ពុជាមានការកើនឡើង<br>- គុណភាពស្រូវស្របតាមស្តង់ដាសម្រាប់ការនាំចេញ<br>- ទីផ្សារស្រូវមានការកើនឡើង<br>- តម្លៃអង្ករកើនឡើង និងទៀងទាត់<br>- ពូជស្រូវមានទិន្នផលខ្ពស់ និងតម្លៃខ្ពស់<br>- ជម្រុញនិងគាំទ្រដល់ក្រុមហ៊ុនសម្រាប់ការទិញផលិតផលស្រូវ ដើម្បីនាំចេញ<br>- កែច្នៃចេញជាផលិតផលសម្រេច |

ប្រភពទិន្នន័យ៖ *CDB ឆ្នាំ២០១៧ និងក្រុមប្រឹក្សាឃុំចំណាក្រោម ខែមិថុនា ឆ្នាំ២០១៨*

# ជំពូក ២ ៖ ការវិភាគ តម្រូវការ សក្តានុពល និងឧបសគ្គសម្រាប់អនាគត

## ២.១. តម្រូវការសម្រាប់អនាគត

### ២.១.១. ផែនការអភិវឌ្ឍន៍ឃុំ

ក. ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ (២០១៨ ដល់ ២០២២)

ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវប្រើប្រាស់សម្រាប់សម្រាប់កំណត់អំពីបញ្ហា តម្រូវការដែលជាអាទិភាពយ៉ាងពិតប្រាកដរបស់មូលដ្ឋាន និងយុទ្ធសាស្ត្រនានាដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងឃុំយ៉ាងមានប្រសិទ្ធិភាពតាមរយៈការរៀបចំឱ្យមានតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំមួយ មានរយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិក្រុមប្រឹក្សាឃុំ ។ តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំនេះ បានរំលេចនូវចក្ខុវិស័យអភិវឌ្ឍន៍ដែលជាទស្សនៈរបស់ក្រុមប្រឹក្សាចង់បានការប្រែប្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបាន ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ហើយដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ ក៏បានរំលេចឱ្យឃើញអំពីគោលបំណងអភិវឌ្ឍន៍ ដែលជាលទ្ធផលរួមរបស់ក្រុមប្រឹក្សាចង់បាន ព្រមទាំងគោលដៅអភិវឌ្ឍន៍ ដែលជាលទ្ធផលនានារបស់ក្រុមប្រឹក្សាចង់បានទៅតាមវិស័យនីមួយៗ។ ទន្ទឹមនេះ ក៏បានរំលេចឱ្យឃើញយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលជាការកំណត់វិធីសាស្ត្រឬសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍មួយៗខាងលើ ។

ចំណែកឃុំចំណាក្រោមក្រុមប្រឹក្សាឃុំក្នុងអាណត្តិ២០១៨-២០២២ក៏បានរៀបចំឱ្យមានផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំរបស់ខ្លួន ដែលនៅក្នុងនោះបានលើកឡើងពីគម្រោងវិនិយោគរយៈពេលប្រាំឆ្នាំនៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ឃុំ ដូចមានខ្លឹមសារដែលក្រុមការងារបានដកស្រង់បញ្ចូលក្នុងតារាងខាងក្រោម៖

តារាង 29៖ ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងជម្រើសនៃការប្រាស់ដីធ្លីអនាគត

| កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ | | | | | |
|---|---|---|---|---|---|
| តម្រូវការនៃការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ | សកម្មភាពជាអាទិភាព | លេខរៀងនៅលើផែនទី |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១.ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋក្នុងឃុំមានផ្លូវធ្វើដំណើរស្រួលនិងការដឹកឥវ៉ាន់ | -សាងសង់ផ្លូវថ្មីនិងកែលម្អផ្លូវដែលមានស្រាប់<br>-កែលម្អជួសជុលផ្លូវ និងដាក់លូ<br>បង្ហូរទឹក | -កសាងផ្លូវលំដីស<br>-កសាងផ្លូវគ្រួសក្រហម<br>-សាងសង់លូកាត់ផ្លូវ<br>-កសាងស្ពាន(ថ្ម ម៉ាឡេ ឈើ)<br>-កសាងផ្លូវកៅស៊ូ<br>-កសាងផ្លូវបេតុង<br>-ជួសជុលផ្លូវលំដីស<br>-ជួសជុលផ្លូវក្រាលគ្រួសក្រហម<br>-ជួសជុលលូកាត់ផ្លូវ | |

| | | | | | |
|---|---|---|---|---|---|
| | | | | -ជួសជុលស្ពាន<br>-ជួសជុលផ្លូវកៅស៊ូ<br>-ជួសជុលផ្លូវបេតុង<br>-បង្កើតនិងពង្រឹងគណៈកម្មការថែទាំផ្លូវ<br>-ថែទាំជាប្រចាំផ្លូវថ្នល់<br>-សង់រទឹក(របាំងបន្ថយល្បឿនទឹក<br>-រៀបចំកែលម្អច្រាំងទន្លេ/ស្ទឹង/បឹង<br>-រៀបចំការីឡា<br>-ជួសជុលកែម្អសួនច្បារ<br>-រៀបចំភ្លើងបំភ្លឺផ្លូវសាធារណៈ | |
| ២.មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋមានប្រព័ន្ធស្រោចស្រពគ្រាប់គ្រាន់ | -ស្តារនិងជួសជុលប្រព័ន្ធធារាសាស្ត្រចាស់ៗ<br>-សាងសងប្រព័ន្ធធារាសាស្ត្រថ្មីបន្ថែមទៀត | -សាងសង់សំណង់ធារាសាស្ត្រ<br>-ស្តារឡើងប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់<br>-រៀបចំនិងពង្រឹងសហគមន៍ប្រើប្រាស់ទឹក<br>-ជីកប្រឡាយ<br>-ជីកប្រឡាយអមផ្លូវ<br>-ស្តារប្រឡាយ<br>-សាងសង់ទ្វារទឹក<br>-ជួសជុលទ្វារទឹក<br>-ផ្តល់ម៉ាស៊ីនបូមទឹក<br>-ពង្រឹងគណៈកម្មការគ្រប់គ្រងធារាសាស្ត្រ | |
| ៣.កម្រិតអប់រំមានគ្រប់កម្រិតនិងសិស្សបានចូលរៀនគ្រប់គ្នានៅក្នុងឃុំ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ២០១៨-២០២២ | -បង្កើនការចូលរៀនកុមារអាយុ ៣-៤ ឆ្នាំឲ្យបាន ៩០% នៅឆ្នាំ ២០១៨<br>-កុមារអាយុ ៦-១៤ឆ្នាំបានរៀនបញ្ចប់នូវកម្រិតមូលដ្ឋាន ០៩ឆ្នាំ<br>-ចំនួនអនក្ខរក្ខរជននឹងថយនៅត្រឹម២% | -ពង្រឹងនិងពង្រីកផ្នែកមត្តេយ្យសាលាឲ្យបានគ្រប់មូលដ្ឋានភូមិ<br>-ជម្រុញការយល់ដឹងដល់ឪពុកម្តាយកុមារពីតម្លៃសិក្សា<br>-ពង្រឹងកិច្ចសហការជាមួយមន្ទីរជំនាញ និងអង្គការនានាដើម្បីកាត់បន្ថយអនក្ខរកម្មរបស់ប្រជាពលរដ្ឋ | -បង្កើតថ្នាក់មត្តេយ្យ<br>-ជ្រើសរើស/ឧបត្ថម្ភគ្រូមត្តេយ្យ<br>-ផ្គត់ផ្គង់សម្ភារៈដំណើរការមត្តេយ្យ<br>-សាងសង់អគារបឋមសិក្សា<br>-ចាក់ដីទីធ្លាសាលាបឋម<br>-ជួសជុលរបងសាលា<br>-ផ្តល់គ្រឿងសម្ភារៈតាមសាលាបឋម<br>-សាងសង់បណ្ណាល័យសាលាបឋម<br>-សាងសង់អគារទីចាត់ការសាលាបឋម<br>-ជួសជុលអគារទីចាត់ការ | |

| | | | | | |
|---|---|---|---|---|---|
| | | | | -ជួលជុលបណ្ណាល័យ<br>-ផ្តល់គ្រឿងសង្ហារឹមសាលា<br>-ផ្តល់សម្ភារៈកីឡាដល់សាលាបឋម<br>-ផ្តល់សម្ភារៈល្បែងកុមារ<br>-ឧបត្ថម្ភដល់កុមារក្រីក្រ<br>-ផ្តល់សម្ភារៈសិក្សាដល់សិស្សក្រីក្រ<br>-ផ្សព្វផ្សាយឲ្យឪពុកម្តាយនាំកូនចូលរៀន<br>-ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ<br>-អប់រំកុមារឲ្យយល់ដឹងពីតម្លៃនៃការសិក្សា<br>-បើកថ្នាក់អក្ខរកម្មឲ្យគ្រប់ភូមិ | |
| ៤.សុខភាពរបស់ប្រជាជនល្អប្រសើរ | សៀវភៅផែនការអភិវឌ្ឍន៍ឃុំ ២០១៨-២០២២ | -ធ្វើឲ្យប្រសើរឡើងសុខភាព និងអនាម័យរបស់ប្រជាជនបានល្អ | -បង្កើននិងកែលម្អសេវាសុខភាព និងចំណេះដឹងដល់ភ្នាក់ងារសុខភាពភូមិ | -ចាក់វ៉ាកសាំងការពារជម្ងឺ៧មុខ<br>-ផ្តល់ថ្នាំជាតិដែក<br>-សំណើសុំគ្រូពេទ្យនិងថ្នាំ<br>-ជួសជុលអណ្តូងទឹកស្អាត<br>-បណ្តុះបណ្តាលស្ត្រីមេម៉ាយក្រីក្របង្កើតជាសមាគមន៍ក្រុមចេះជួយខ្លួនឯង<br>-សាងសង់បង្គន់អនាម័យ<br>-អប់រំ និងផ្សព្វផ្សាយអំពីជម្ងឺឆ្លងដូចជា៖ របេង ថ្លើម គ្រុនចាញ់ និងគ្រុនឈាមជាដើម<br>-កម្មវិធីពន្យាកំណើត | |
| ៥. គ្រប់គ្រងនិងអភិរក្សធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយចិរភាព | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឲ្យប្រសើរឡើងនូវធនធានធម្មជាតិ | -បង្កើនសេវាលើការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន | -អប់រំចំណេះដឹងបរិស្ថាននិងច្បាប់បរិស្ថាន<br>-អប់រំផ្សព្វផ្សាយច្បាប់ព្រៃឈើ<br>-អប់រំផលប្រយោជន៍ព្រៃឈើ/ព្រៃលិចទឹក<br>-អប់រំច្បាប់ការពារសត្វព្រៃ<br>-អប់រំផ្សព្វផ្សាយអភិរក្សព្រៃឫស្សី<br>-បង្កើត/ពង្រឹងគណៈកម្មការធនធានធម្មជាតិនិងបរិស្ថាន<br>-អប់រំប៉ះពាល់នៃការបំពុលទឹក<br>-យុទ្ធនាការអប់រំបរិស្ថាននិងធនធានធម្មជាតិ<br>-បញ្ជ្រាបយេនឌ័រក្នុងផ្នែកធនធានធម្មជាតិនិងបរិស្ថាន | |

| | | | | | |
|---|---|---|---|---|---|
| | | | | បង្កើតសហគមន៍ការពារធនធានធម្មជាតិនិងបរិស្ថាន | |
| ៦.ឃុំអាចផ្គត់ផ្គង់បាននូវតម្រូវការថាមពល | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ប្រជាពលរដ្ឋនៅក្នុងចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន | -លើកកម្ពស់ការយល់ដឹងផ្នែកធនធាន ធម្មជាតិ និងបរិស្ថាន | -ដាំកូនឈើ<br>-បច្ចេកទេសប្រើចង្រ្កានជីវឧស្ម័ន<br>-បច្ចេកទេសប្រើចង្រ្កានសន្សំឧស<br>-ផ្សព្វផ្សាយច្បាប់ការពារព្រៃឈើ | |
| ៧.ឲ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្តនិងសុវត្ថិភាព | សាលាឃុំ | -ភូមិឃុំមានសន្តិសុខ និងសណ្តាប់ធ្នាប់ និងមានសុវត្ថិភាពល្អ | -ជម្រុញពង្រីកការអនុវត្តន៍គោនយោបាយភូមិឃុំមានសុវត្ថិភាព<br>-ប្រជាពលរដ្ឋចូលរួមនិងបង្កើតក្រុមការពារមេភូមិដើម្បីរក្សាសន្តិសុខសណ្តាប់ធ្នាប់ក្នុង ភូមិ-ឃុំ | -សង់/ជួសជុលសាលាឃុំ<br>-សង់/បង្កើត/ជួសជុលស្នាក់ការភូមិ<br>-បំពាក់ឧបករណ៍វិទ្យុទាក់ទង<br>-ផ្តល់មធ្យោបាយធ្វើដំណើរការសមស្របសម្រាប់បម្រើការងារឃុំ<br>-ផ្តល់ឧបករណ៍បំពងសម្លេងសម្រាប់ការប្រជុំ<br>-ផ្តល់ឧបករណ៍ចាំបាច់គ្រាំដំណើរការរដ្ឋបាលឃុំ<br>-បំពាក់គ្រឿងសង្ហារឹមសាលាឃុំ<br>-ផ្តល់សម្ភារការិយាល័យសម្រាប់ដំណើរការរដ្ឋបាលឃុំ<br>-សង់/ជួសជុលរបងក្លោងទ្វារនិងសំណង់តូចៗរបស់សាលាឃុំ<br>-ផ្គត់ផ្គង់សម្ភារដល់មេភូមិ<br>-ផ្តល់ទូកកាណូតសម្រាប់ជាមធ្យោបាយធ្វើដំណើរ<br>-បង្កើតប្រអប់សំបុត្រភូមិឃុំ<br>-ចាក់ដីបំពេញទីធ្លាសាលាឃុំ<br>-ផ្តល់ម៉ាស៊ីនភ្លើងសម្រាប់សាលាឃុំ<br>-បង្កើនការត្រួតពិនិត្យ/គ្រប់មុខសញ្ញាជនខិលខូច<br>-ជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណដល់ប្រជាជន<br>-អប់រំការយល់ដឹងអំពីច្បាប់ប្រើប្រាស់អាវុធជាតិផ្ទុះ<br>-ប្រមូលអាវុធជាតិផ្ទុះដើម្បីសន្តិសុខមូលដ្ឋាន<br>-អប់រំវិធានការបង្ការនិងពន្លត់អគ្គីភ័យ<br>-ពង្រឹងសមត្ថភាពទប់ស្កាត់ | |

| | | | | | |
|---|---|---|---|---|---|
| | | | | គ្រោះអគ្គីភ័យ<br>-ផ្តល់សម្ភារយាមល្បាត<br>-រៀបចំវិធានការការពារផលដំណាំ/សត្វពាហនៈ<br>-បោសសំអាតមីន<br>-អប់រំការយល់ដឹងអំពីមីននិងគ្រាប់មិនទាន់ផ្ទុះ<br>-បង្កើតប៉ុសស្ទ័យការពារតាមភូមិ<br>-បង្កើតក្រុមប្រជាជនការពារតាមភូមិឃុំ<br>-ផ្សព្វផ្សាយច្បាប់ភូមិបាលនិងច្បាប់ផ្សេងៗទៀត<br>-ចុះបញ្ជីអត្រានុកូលដ្ឋានបានគ្រប់ៗគ្នា<br>-ផ្សព្វផ្សាយច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ<br>-ផ្សព្វផ្សាយអប់រំក្រុមក្មេងទំនើង<br>-អប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន<br>-បង្ក្រាបល្បែងស៊ីសងគ្រប់ប្រភេទ<br>-អប់រំ/ផ្សព្វផ្សាយអំពើហឹស្សាក្នុងគ្រួសារ<br>-អប់រំ/សង្គ្រោះកុមារស្ត្រីរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ<br>-វគ្គអប់រំដើម្បីកាត់បន្ថយការផឹកគ្រឿងស្រវឹង | |
| ៨.លុបបំបាត់កាត់បន្ថយទំនាស់ដីធ្លី | សាលាឃុំ | -មានប័ណ្ណកម្មសិទ្ធិគ្រប់គ្រងដីធ្លីនិងយល់ច្បាស់ពីសិទ្ធិក្នុងការគ្រប់គ្រង | -ជម្រុញឲ្យប្រជាពរដ្ឋបានយល់ដឹងពីច្បាប់ និងមានកម្មសិទ្ធិដីធ្លីដោយស្របច្បាប់<br>-បង្កើនការគ្រប់ គ្រងដីធ្លីឲ្យស្របតាមគោលនយោបាយរបស់រដ្ឋ | -រៀបចំផែនការកំណត់តំបន់ប្រើប្រាស់ដី<br>-កំណត់តំបន់ប្រើប្រាស់ព្រៃសមស្រប<br>-បែងចែកដីសម្បទានសង្គមកិច្ច<br>-កំណត់ព្រំប្រទល់រដ្ឋបាលភូមិឃុំ<br>-បង្កើតភូមិថ្មីនិងគាំទ្រការរៀបចំលំនៅឋាន<br>-រៀបចំសណ្តាប់ធ្នាប់សំណង់លំនៅឋាន<br>-រៀបចំស្លាកលេខផ្ទះ<br>-លុបបំបាត់ការតាំងទីលំនៅអនាធិបតេយ្យ | |

| | | | | | |
|---|---|---|---|---|---|
| | | | | -ទប់ស្កាត់ការរំលោភយកដីសាធារណៈ<br>-ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋ<br>-ផ្សព្វផ្សាយពីច្បាប់ភូមិបាលនិងច្បាប់ផ្សេងៗ<br>-ជម្រុញឲ្យប្រជាពលរដ្ឋធ្វើរបង និងព្រំដីឲ្យបានច្បាស់លាស់<br>-ពង្រឹងគណៈកម្មាធិការដោះស្រាយទំនាស់ដីធ្លី | |
| ៩.ទិន្នផលកសិកម្មកើនឡើង | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធានាស្បៀងហូបគ្រប់គ្រាន់ | -បង្កើនផលិត កសិកម្ម | -លើកទំនប់ និងភ្លឺស្រែ<br>-ជីកប្រឡាយ<br>-លូស្វាក់ទឹក ទ្វារទឹក<br>-ពូជស្រូវល្អ<br>-ធ្វើជីកំប៉ុស្ត<br>-បច្ចេកទេសជីគីមី<br>-ចិញ្ចឹមសត្វ ត្រី<br>-ឈើហូបផ្លែ | |
| ១០.មានទឹកស្អាតសម្រាប់គ្រួសារប្រើប្រាស់ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ការរស់នៅមានអនាម័យតាមរយៈមានទឹកស្អាតប្រើប្រាស់ | -ពង្រីក និងកែលម្អប្រភពផ្គត់ផ្គង់ទឹក | -អប់រំសុខភាពអនាម័យ<br>-ផ្សព្វផ្សាយការប្រើទឹកស្អាត<br>-សង់បង្គន់អនាម័យ<br>-ផ្តល់មធ្យោបាយចម្រោះទឹកស្អាត<br>-ជីកអណ្តូងលូ ស្នប់ ស្រះទឹក<br>-ជួសជុលអណ្តូង<br>-តបណ្តាញទឹកស្អាត | |
| ១១.សមភាព និងសមធម៌ក្នុងការរស់នៅ | សៀវភៅផែនការអភិវឌ្ឍន៍ ឃុំ ២០១៨-២០២២ | -ធ្វើឲ្យប្រសើរឡើងដល់ប្រជាជនគ្រប់រូបរស់នៅប្រកបដោយសមភាពសមធម៌ គោរពទៅវិញទៅមក | -បង្កើនការផ្សព្វផ្សាយច្បាប់ និងលើកកម្ពស់មុខរបរ | -វគ្គបណ្តុះបណ្តាលអំពីយេនឌ័រ/គោលគំនិតយេនឌ័រ<br>-បញ្ជ្រាបយេនឌ័រក្នុងកម្មវិធីវិនយោគឃុំ<br>-ផ្សព្វផ្សាយ/ពង្រឹងតួនាទីស្រ្តីក្នុងការអភិវឌ្ឍន៍<br>-ផ្សព្វផ្សាយបញ្ជ្រាបយេនឌ័រដល់ប្រជាពលរដ្ឋ<br>-ផ្សព្វផ្សាយេនឌ័រនិងសិទ្ធិកុមារ<br>-អាហាររូបករណ៍សម្រាប់សិស្សស្រី<br>-ពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុកស្ត្រីនិងកុមារ<br>-ជ្រើសរើស/ពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុកស្ត្រីនិងកុមារ | |

| | | | | | |
|---|---|---|---|---|---|
| | | | | -វគ្គជំនាញសម្របសម្រួលដល់ជនបង្គោល<br>-ជំរុញសកម្មភាព/ពង្រឹងសមត្ថភាពការងារគ.ក.ន.ក<br>-រៀបចំ/ជំរុញការប្រជុំបណ្ដាញយេនឌ័រជាប្រចាំ<br>-ឧបត្ថម្ភថវិកាគាំទ្រជនបង្គោលស្ត្រីនិងកុមារ<br>-បង្កើនសមត្ថភាពស្ត្រីឲ្យចូលរួមការងារសង្គម<br>-ពង្រឹង/បង្កើនសមត្ថភាពស្ត្រីឲ្យក្លាយជាអ្នកដឹកនាំ<br>ទស្សនកិច្ចពង្រឹងសមត្ថភាពផ្នែកយេនឌ័រ<br>-ផ្សព្វផ្សាយច្បាប់សិទ្ធិមនុស្ស<br>-ផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ<br>-ផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រីនិងកុមារ<br>-ផ្សព្វផ្សាយច្បាប់គេងប្រវ័ញ្ចដល់កម្លាំងពលកម្មស្ត្រីនិងកុមារ<br>-បណ្ដុះបណ្ដាលពីតួនាទីយេនឌ័រ | |
| ១២. គ្រប់គ្រងនិងអភិរក្សធនធានជលផលប្រកបដោយចិរភាព | សាលាឃុំ | -បង្កើនធនធានជលផល | -ជម្រុញការបង្កើតវារីវប្បកម្ម | -ពង្រឹងវិធានការទប់ស្កាត់បទល្មើសនេសាទ<br>-បង្កើត/គាំទ្រសកម្មភាពសហគមន៍នេសាទ<br>-ស្ដារ/អភិរក្សផ្លូវទឹក អាងទឹកធម្មជាតិ/បឹងអូរ ព្រែក<br>-ការពារជម្រកត្រីពង/អភិរក្សពូជត្រី<br>-លើកទំនប់សម្រាប់ការពារជម្រកត្រី<br>-ពង្រឹងវិធានការការពារព្រៃលិចទឹក<br>-គាំទ្រសកម្មភាពសហគមន៍ព្រៃលិចទឹក<br>-បង្កើត/ពង្រឹងសហគមន៍ព្រៃលិចទឹក<br>-បង្កើត/ពង្រឹងសហគមន៍ចិញ្ចឹមត្រី<br>-កំណត់ព្រំប្រទល់ដែន | |

| | | | | | |
|---|---|---|---|---|---|
| | | | | នេសាទ<br>-កំណត់ព្រំប្រទល់សហគមន៍នេសាទ<br>-បោះបង្គោលដែនព្រំប្រទល់កន្លែងនេសាទសហគមន៍<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>-ផ្សព្វផ្សាយច្បាប់ជលផល<br>-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ<br>-អប់រំ និងផ្សព្វផ្សាយបម្រាមនេសាទនៅរដូវត្រីពង | |
| ១៣.កាត់បន្ថយមរណៈមាតា និងទារកក្រោយសម្រាល | សាលាឃុំ | -បង្កើនការលុបបំបាត់អត្រាស្លាប់មាតា និងទារកក្រោយសម្រាល | -ពង្រឹងនិងពង្រីកការផ្តល់សេវាគាំពារសុខភាពមាតា និងទារក | -កម្មវិធីពន្យាកំណើត<br>-សេវាសុខភាពស្ត្រីមានផ្ទៃពោះ<br>-ផ្តល់ការអប់រំពីសុខភាពបន្តពូជ<br>-ជំរុញសកម្មភាពទទួលយកសេវាសុខភាពស្ត្រីមានផ្ទៃពោះ<br>-ផ្តល់ប្រាក់ឧបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះមកសម្រាលកូននៅមណ្ឌលសុខភាព<br>-ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះឲ្យទៅសម្រាលកូនដោយពេទ្យឆ្មប<br>-អប់រំឲ្យស្ត្រីចេះរបៀបការពារជម្ងឺឆ្លងកាមរោគ និងជម្ងឺអេដស៍<br>-មិនរើសអើង និងគាំទ្រដល់អ្នកកើតមេរោគអេដស៍<br>-ផ្តល់ថ្នាំជាតិដែក/វិតាមីនអាដល់កុមារ<br>-ជម្រុញឪពុកម្តាយយកកុមារទៅចាក់ថ្នាំការពារជម្ងឺ៧មុខ | |
| ១៤.ឲ្យមានថាមពលអគ្គិសនីប្រើប្រាស់គ្រប់ផ្ទះ | សាលាឃុំ | -ទូទាំងឃុំសង្កាត់មានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ | -ពង្រឹងកិច្ចសហការជាមួយអង្គភាពជំនាញដើម្បីជម្រុញការផ្គត់ផ្គង់ថាមពល<br>អគ្គិសនី | -រៀបចំបណ្តាញអគ្គិសនីតាមភូមិ | |

ប្រភពទិន្នន័យ៖ *របាយការណ៍ក្បេត្រ-បរិស្ថាន ផែនការអភិវឌ្ឍន៍ឃុំ២០១៧-២០២២ និងក្រុមប្រឹក្សាឃុំចំណាក្រោម ឆ្នាំ២០១៨*

## ខ. គម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតដែលបានអនុម័តរួច

នៅក្នុងឃុំចំណាក្រោម បច្ចុប្បន្នមិនមានគម្រោងអភិវឌ្ឍន៍ណាមួយ ដែលត្រូវបានអនុម័តរួចដើម្បីដំណើរការជួយជំរុញក្នុងការអភិវឌ្ឍន៍ឃុំឡើយ ។

ផែនទី ១៖ ផែនទីគម្រោងអាទិភាពឃុំចំណាក្រោម



### ២.១.២. ចំណោលប្រជាសាស្ត្រគិតទៅដល់ឆ្នាំ២០៣២

ការព្យាករណ៍ពីកំណើនប្រជាជន ជាចំនុចសំខាន់ណាស់ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម ដែលអាចឱ្យយើងដឹងមុននូវចំនួនប្រជាជនក្នុងឃុំរយៈពេល១៥ឆ្នាំខាងមុខដ៏វែង អត្រាកំណើនជាមធ្យមរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដែលបានបង្ហាញក្នុងជំពូកទី១បានឱ្យដឹងគឺ២,៥៣ភាគរយ ដូច្នេះប្រជាពលរដ្ឋក្នុងឃុំនឹងមានការកើនឡើងរហូតដល់ឆ្នាំ២០៣២ ត្រូវបានធ្វើចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ១៣ ៩១៨នាក់

-អត្រាកំណើនមធ្យមប្រចាំឆ្នាំ: ២,៥៣ %

-ចំនួនប្រជាជនកើនឡើងក្នុងរយៈពេល១ឆ្នាំ: **១៣ ៩១៨ នាក់** x **២,៥៣** % = **៣៥២ នាក់/ឆ្នាំ**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើនឡើងបាន: ៣៥២នាក់/ឆ្នាំ x ១៥ឆ្នាំ =៥ ២៨០ នាក់**

**-ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ខាងមុខទៀត: ១៣ ៩១៨នាក់ +៥ ២៨០នាក់= ១៩ ១៩៨នាក់**

ចំណែកចំនួនគ្រួសារនៅក្នុងឃុំ នឹងមានការកើនឡើងនៅក្នុងឆ្នាំ ២០៣២ ត្រូវបានចំណោលតាមរយៈការគណនាដូចខាងក្រោម៖

-ចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៧ គឺ ១៣ ៩១៨ នាក់

-ចំនួនគ្រួសារសរុបក្នុងឆ្នាំ ២០១៧ គឺ ២ ៨២៨ គ្រួសារ

**-ចំនួនសមាជិកមធ្យមក្នុងមួយគ្រួសារក្នុងឆ្នាំ ២០១៧ គឺ:**

**១៣ ៩១៨ នាក់ /២ ៨២៨ គ្រួសារ = ៤,៩២នាក់/គ្រួសារ**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខចំនួនគ្រួសារកើនឡើងបាន:

**៥ ២៩១នាក់ /៤,៩២នាក់/គ្រួសារ = ១ ០៧៥គ្រួសារ**

-ដូច្នេះចំនួនគ្រួសារសរុបក្នុងរយៈពេល១៥ឆ្នាំខាងមុខទៀតមាន:

**២ ៨២៨គ្រួសារ + ១ ០៧៥គ្រួសារ = ៣ ៩០៣គ្រួសារ**

តារាង 30៖ ចំណោលប្រជាសាស្ត្រនៃចំនួនគ្រួសារ និងប្រជាជនសរុប (០៥ឆ្នាំ)

| ឆ្នាំ | ចំនួនគ្រួសារ | ចំនួនប្រជាជន(នាក់) | |
|---|---|---|---|
| | | សរុប | ស្រី |
| ២០១៧ | ២ ៨២៨ | ១៣ ៩១៨ | ៧ ២៥៥ |
| ២០២២ | ៣ ១៨៨ | ១៥ ៦៨២ | ៨ ១៧៤ |
| ២០២៧ | ៣ ៥៤៨ | ១៧ ៤៤៥ | ៩ ០៩៤ |
| ២០៣២ | ៣ ៩០៣ | ១៩ ២០៩ | ១០ ០១៣ |

**☞ចំណាំ៖**

- ចំណោលប្រជាសាស្ត្រសម្រាប់១៥ឆ្នាំខាងមុខ៖ អត្រាកំណើនមធ្យមប្រចាំឆ្នាំxចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន/១០០
- ដូច្នេះក្នុងរយៈពេល១៥ឆ្នាំខាងមុខប្រជាជនកើន៖ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ x ១៥
- ដូច្នេះប្រជាជនសរុបក្នុងរយៈពេល១៥ទៀតមាន៖ចំនួនអត្រាកំណើនប្រជាជន១៥ខាងមុខ+ចំនួនប្រជាជនឆ្នាំបច្ចុប្បន្ន

តារាង 31៖ ចំណោលប្រជាសាស្រ្តតាមក្រុមអាយុ (០៥ឆ្នាំ)

| ស្ថិតិតាមក្រុមអាយុ | ២០១៧ | | ២០២២ | | ២០២៧ | | ២០៣២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុពី០-ឆ្នាំ២ | ៦៣៦ | ៣១១ | ៧១៦ | ៣៥០ | ៧៩៧ | ៣៩០ | ៨៧៧ | ៤២៩ |
| អាយុពី៣- ៤ឆ្នាំ | ៧៣៨ | ៣៦៥ | ៨១៨ | ៤០៤ | ៨១៨ | ៤៤៤ | ៨១៨ | ៤៨៣ |
| អាយុ៥ឆ្នាំ | ៥៧៧ | ៣០១ | ៦៥០ | ៣៣៩ | ៧២៣ | ៣៧៧ | ៧៩៦ | ៤១៥ |
| អាយុ៦-១១ឆ្នាំ | ១ ៨៥៥ | ៩១៨ | ២ ០៩០ | ១ ០៣៤ | ២ ៣២៥ | ១ ១៥១ | ២ ៥៦០ | ១ ២៦៧ |
| អាយុ១២-១៤ឆ្នាំ | ១ ០២៥ | ៥៤៣ | ១ ១៥៥ | ៦១២ | ១ ២៨៥ | ៦៨១ | ១ ៤១៥ | ៧៤៩ |
| អាយុ១៥-១៧ឆ្នាំ | ១ ០១២ | ៥៥៩ | ១ ១៤០ | ៦៣០ | ១ ២៦៨ | ៧០១ | ១ ៣៩៧ | ៧៧២ |
| អាយុ១៨-២៤ឆ្នាំ | ១ ៧០១ | ៨៩៨ | ១ ៩១៧ | ១ ០១២ | ២ ១៣២ | ១ ១២៦ | ២ ៣៤៨ | ១ ២៣៩ |
| អាយុ២៥-៦០ឆ្នាំ | ៥ ៣០៤ | ២ ៨១៩ | ៥ ៩៧៦ | ៣ ១៧៦ | ៦ ៦៤៨ | ៣ ៥៣៣ | ៧ ៣២០ | ៣ ៨៩១ |
| អាយុ៦១ឆ្នាំ | ១ ០៧០ | ៥៤១ | ១ ២០៦ | ៦១០ | ១ ៣៤១ | ៦៧៨ | ១ ៤៧៧ | ៧៤៧ |
| ប្រជាជនសរុប | ១៣ ៩១៨ | ៧ ២៥៥ | ១៥ ៦៦៩ | ៨ ១៦៨ | ១៨ ៦៥២ | ៩ ០៨០ | ២១ ៦៣៩ | ៩ ៩៩២ |
| **ចំនួនគ្រួសារ** | **២ ៨២៨** | | **៣ ១៨៨** | | **៣ ៥៤៨** | | **៣ ៩០៣** | |

## ២.១.៣. តម្រូវការដីធ្លីជាមូលដ្ឋាន

### ក. ដីលំនៅឋាន

ដីលំនៅឋាន ភូមិ គឺសំដៅទៅដល់ដីដែលប្រើប្រាស់សម្រាប់សង់ផ្ទះ និងសម្រាប់សួនដំណាំនៅជុំវិញផ្ទះតាមគ្រួសារ ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីលំនៅឋានមានទំហំ ៣១១,២៧ហិកតា និងមានគ្រួសារសរុបចំនួន ២ ៨២៨ គ្រួសារ គឺជាស្ថានភាពរស់នៅរបស់ប្រជាជនមានភាពសមស្របមិនមានបញ្ហាពីការខ្វះដីសម្រាប់លំនៅឋានឡើយ លើកលែងតែគ្រួសារមួយចំនួនតូច គឺស្មើនឹងចំនួន ៥៥គ្រួសារប៉ុណ្ណោះ ដែលមិនមានដីសម្រាប់សាងសង់លំនៅឋាន ហើយបច្ចុប្បន្នគ្រួសារទាំងនោះកំពុងតែរស់នៅលើដីចំណីប្រឡាយជាដីសាធារណៈ និងគ្រួសារមួយចំនួនទៀតកំពុងតែរស់នៅលើដីកម្មសិទ្ធិរបស់អ្នកដ៏ទៃ (យោងតាមទិន្នន័យក្នុងជំពូកទី១ ត្រង់ចំណុច១.៣.១ អំពីការកាន់កាប់ និងគ្រប់គ្រងការប្រើប្រាស់ដី) ដែលត្រូវយកចិត្តទុកដាក់ធ្វើការដោះស្រាយជូនតាមរយៈដីសម្បទានដីសង្គមកិច្ចមាននៅទីតាំងក្រៅឃុំ តាមការសម្រេចចរបស់គណៈកម្មាធិការសម្ប ទានដីសង្គមកិច្ច ។

ក្នុងឆ្នាំ២០១៧ ផ្ទៃដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារមានចំនួន៖

**៣១១,២៧ ហិកតា /២ ៨២៨គ្រួសារ = ០,១១ហិកតា/គ្រួសារ**

បើយោងទៅតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច តម្រូវឱ្យមានដីលំនៅឋានយ៉ាងច្រើនចំនួន ០,២៥ហិកតាក្នុងមួយគ្រួសារ ដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូនទៅ ៥៥គ្រួសារ ដែលគ្មានដីពិតប្រាកដសម្រាប់សង់លំនៅឋាន ដើម្បីទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋដែលមានទីតាំងផ្សេងពីឃុំចំណាក្រោមនេះ។

ដូច្នេះ ដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្ម ក្នុងចំនួនតាមការគណនាដូចខាងក្រោម៖

**តម្រូវការលំនៅឋានសម្រាប់ឆ្នាំ២០៣២ ដីលំនៅឋានត្រូវកើនឡើងដល់ ៖**

**១ ០៧៥នាក់ x ០,១១ហិកតា/គ្រួសារ = ១១៨,២៥ហ.ត**

ចំណែកការដោះស្រាយដីលំនៅឋានជូនគ្រួសារដែលគ្មានដីពិតប្រាកដចំនួន៥៥គ្រួសារតាមរយៈដីសម្បទានសង្គមកិច្ចចំនួនៈ **៥៥គ្រួសារ x ០,២៥ហិកតា /គ្រួសារ = ១៣,៧៥ហិកតា**

តារាង 32៖ តម្រូវការដីសម្រាប់លំនៅឋានក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ២ ៨២៨គ្រួសារ | ៣ ៩០៣គ្រួសារ | ១ ០៧៥គ្រួសារ |
| **តម្រូវការដីលំនៅឋាន** | **៣១១,២៧ហិកតា** | **៤២៩,៥២ហិកតា** | **១១៨,២៥ហិកតា** |

ខ. ដីកសិកម្ម

ចំពោះដីកសិកម្មគឺ សំដៅទៅលើដីសម្រាប់ធ្វើស្រែ និងដីចម្ការដំណាំ ។ នៅក្នុងឆ្នាំ២០១៧ ដែលជាឆ្នាំគោលយើងបានដឹងថា ដីកសិកម្មមានទំហំ ១៤ ៩៥២,៤៨ហិកតា និងមានគ្រួសារសរុបចំនួន ២ ៨២៨គ្រួសារ អាចធ្វើស្រែផលិតស្រូវបានសល់ពីការហូបចុកខ្លះសម្រាប់ការនាំចេញទៅទីផ្សារដោះស្រាយជីវភាព ជាស្ថានភាពដែលប្រជាពលរដ្ឋអាចរស់នៅក្នុងជីវភាពសមរម្យបាន លើកលែងតែគ្រួសារចំនួន ១៤៤គ្រួសារ ប៉ុណ្ណោះ ដែលមិនមានដីសម្រាប់ធ្វើកសិកម្មផ្ទាល់ខ្លួន និងមួយចំនួនស៊ីឈ្នួលគេ ។

ដូច្នេះបច្ចុប្បន្នទំហំដីកសិកម្មសម្រាប់មួយគ្រួសារមានចំនួន៖

**១៤ ៩៥២,៤៨ហិកតា /២ ៨២៨គ្រួសារ =៥,២៩ហិកតា/គ្រួសារ**

តែបើតាមអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ចែងតម្រូវឱ្យមានដីកសិកម្មយ៉ាងច្រើន ២ហិកតាក្នុង១គ្រួសារដែលអាចប្រើប្រាស់សម្រាប់ដោះស្រាយជូន ១៤៤គ្រួសារដែលគ្មានដីពិតប្រាកដសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារដើម្បីទទួលបានដីសម្បទានសង្គមកិច្ចពីរដ្ឋដែលមាននៅទីតាំងផ្សេងពីឃុំចំណាក្រោម។

ដូច្នេះដើម្បីធានានិរន្តរភាពនៃការរស់នៅដូចបច្ចុប្បន្ន ចំពោះប្រជាជនដែលមានកំណើនក្នុងរយៈពេល ១៥ឆ្នាំខាងមុខ ត្រូវការដោះស្រាយដីសម្រាប់ធ្វើកសិកម្មចំនួនតាមការគណនាដូចខាងក្រោម៖

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ គ្រួសារកើនឡើងចំនួនៈ **១ ០៧៥គ្រួសារ**

-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ (២០១៧-២០៣២) ដីកសិកម្មត្រូវកើនឡើងៈ

**១ ០៧៥គ្រួសារ x ៥,២៩ហិកតា/គ្រួសារ = ៥ ៦៨៦,៧៥ហិកតា**

**-ដូច្នេះក្នុងរយៈពេល១៥ឆ្នាំ(២០១៧-២០៣២) ដីកសិកម្មសរុបមានចំនួនៈ**

**១៤ ៩៥២,៤៨ហិកតា + ៥ ៦៨៦,៧៥ហិកតា = ២០ ៦៣៩,២៣ហិកតា**

ចំណែកការដោះស្រាយដីកសិកម្មជូនទៅគ្រួសារ ដែលគ្មានដីពិតប្រាកដចំនួន ១៤៤ គ្រួសារ តាមរយៈសម្បទានសង្គមកិច្ចមានចំនួនៈ **១៤៤គ្រួសារ x ២ ហិកតា/គ្រួសារ = ២៨៨ហិកតា**

តារាង 33៖ តម្រូវការដីសម្រាប់ដីកសិកម្មក្នុងឆ្នាំ២០៣២

| បរិយាយ | ២០១៧ បច្ចុប្បន្ន | អនាគត ២០៣២ | បម្រែបម្រួលតម្រូវការដី |
|---|---|---|---|
| គ្រួសារ | ២ ៨២៨គ្រួសារ | ៣ ៩០៣គ្រួសារ | ១ ០៧៥គ្រួសារ |
| តម្រូវការដីកសិកម្ម | ១៤ ៩៥២,៤៨ហិកតា | ២០ ៦៣៩,២៣ហិកតា | ៥ ៦៨៦,៧៥ហិកតា |

### គ. ដីព្រៃឈើ

ព្រៃឈើផ្តល់នូវផលិតផលនានា ដូចជា ឈើហ៊ុប ឈើគ្រឿងសង្ហារឹម ឈើបង្គោល អុស និងអនុផលនានា មានជ័រ វល្លិ ឱសថ ដែលគាំទ្រដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅតាមជនបទ តាមរយៈការប្រើប្រាស់ដោយផ្ទាល់ឬតាមរយៈការលក់ដូរ។ ទន្ទឹមនេះ ព្រៃឈើក៏បានដើរតួយ៉ាងសំខាន់នៅក្នុងចំណោមតួនាទីដទៃទៀត ដូចជាការទាក់ទាញទឹកភ្លៀង បញ្ចុះសីតុណ្ហភាព មានអាកាសធាតុបរិសុទ្ធ(ផ្តល់ខ្យល់អាកាសបរិសុទ្ធ)បញ្ចេញនូវឧស្ម័នអុកស៊ីសែន (ជួយស្រូបយកឧស្ម័នកាបូននិច និងបញ្ចេញឧស្ម័នអុកស៊ីសែនដល់មនុស្ស) ការពារគ្រោះ ធម្មជាតិ (ជួយទប់ទល់នឹងខ្យល់ព្យុះ ទឹកជំនន់ ជួយការពារការហូរច្រោះដី និងបាក់ដី)ធ្វើឱ្យដីមានជីជាតិ ជាតំបន់ទេសចរធម្មជាតិ ។ ចំណែកព្រៃលិចទឹកសាប ជាជម្រកត្រីពង ផ្តល់ជីជាតិដី សម្រាប់ធ្វើកសិកម្ម រក្សាជីវសាស្ត្រចម្រុះ។

ចំពោះស្ថានភាពប្រើប្រាស់ដីធ្លីបច្ចុប្បន្ននៅក្នុងឃុំចំណាក្រោម បានឲ្យដឹងថា នៅក្នុងឃុំមានព្រៃគម្ពោតសរុបចំនួន ៣៥,២៧ហិកតា ស្មើនឹង ០,១៥ភាគរយ នៃផ្ទៃដីឃុំទាំងមូល ព្រៃល្បោះមាន ២៨,៣៨ហិកតា និងមានព្រៃលិចទឹកទំហំ ៤ ៤៦៥,១៥ហិកតា ស្មើនឹង ១៨,៩៨ភាគរយនៃដីឃុំទាំងមូល ដែលក្នុងស្ថានភាពបែបនេះ នាពេលអនាគត ឃុំចំណាក្រោមមិនមានតការពង្រីកផ្ទៃដីបន្ថែម សម្រាប់ព្រៃឈើក្រៅតែពីការដាំដើមឈើបន្ថែមលើដីសាធារណៈផ្សេងៗដូចជា តាមដងផ្លូវ ប្រឡាយ អាងស្តុកទឹក សាលាឃុំ សាលារៀន មណ្ឌលសុខភាព និងតាមវត្តអារាមជាដើមប៉ុណ្ណោះសម្រាប់ផ្តល់ផលជាម្លប់ ពណ៌បៃតង ធ្វើឱ្យដីមានជីជាតិ ផ្តល់អុកស៊ីសែន ស្រូបឧស្ម័នកាបូនិកជួយដល់សុខភាពប្រជាពលរដ្ឋ។ល។

### ឃ. ធនធានទឹក

នៅក្នុងឃុំចំណាក្រោម មានធនធានទឹកជាច្រើនដូចជា ទំនប់ អាង ប្រព័ន្ធស្រោចស្រព និងស្រះទឹក ដែលមានសក្តានុពលសម្រាប់ផលិតកម្មកសិកម្ម ដើម្បីជួយទ្រទ្រង់នៅក្នុងដំណាក់កាលរាំងស្ងួត ព្រមទាំងងាយស្រួលក្នុងការជួយអន្តរាគមន៍បានមួយផ្នែកផងដែរ ។ ដូចនេះឃុំត្រូវតែយកចិត្តទុកដាក់កែលម្អប្រព័ន្ធធារាសាស្ត្រ និងស្តារប្រព័ន្ធចំណាក្រោម ដែលមានស្រាប់ ព្រមទាំងរិះរកប្រភពទឹកនានាពីក្នុងតំបន់ជុំវិញឃុំ តាមរយៈស្ថាប័នជំនាញផ្នែកធនធានទឹក ដើម្បីទាញយកមកផ្គត់ផ្គង់ដល់ការស្រោចស្រព និងតម្រូវការប្រើប្រាស់ផ្សេងៗទៀតនៅក្នុងឃុំទាំងមូល សម្រាប់ប្រើប្រាស់ទឹកក្នុងការធ្វើស្រែឲ្យបាន២ទៅ៣ដង ទាំងស្រែប្រាំង និងវស្សា ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។

ដូច្នេះ នាពេលអនាគតឃុំចំណាក្រោម មានគម្រោងស្តារអាងស្តុកទឹកចំនួន ០៤កន្លែង ដែលមានទំហំ ៥៩០,៥៧ហ.ត ដើម្បីបំពេញតម្រូវរបស់ប្រជាពលរដ្ឋនៅថ្ងៃខាងមុខ ដែលទីតាំងស្តារអាងស្តុកទឹកនេះ ជាផ្ទៃដីឃុំគម្រោងទុកស្តារសម្រាប់សហគមន៍ ដែលមានផ្ទៃដីចំនួន ២៨០,៤៧ហ.ត ស្ថិតនៅ៣ភូមិ (ស្ពានគ្រេង,ចំណាក់,ដីអាប់)អាងស្តុកទឹកត្រពាំងតាអោន ស្ថិតខាងកើតផ្លូវ ហើយមានផ្ទៃដីចំនួន ៩៣,០២ហ.ត និងអាងត្រពាំងតាអោន ដែលស្ថិតនៅខាងលិចផ្លូវ មានផ្ទៃដីចំនួន ១១៣,៣១ហ.ត ព្រមទាំងអាងស្តុកទឹកសហគមន៍ព្រីងទោល មានផ្ទៃដីចំនួន ១០៣,៧៧ហ.ត ដែលស្ថិតនៅភូមិចំណាក់តែ ដោយឡែកសម្រាប់ដីស្រែនៅក្នុងតំបន់២ និង៣ជុំវិញបឹងទន្លេសាប ត្រូវស្នើសុំការអនុញ្ញាតពីអាជ្ញាធរខេត្តកំពង់ធំជាមុនទើបអាចធ្វើការស្តារ និងជួសជុលបាន ដើម្បីមានលទ្ធភាពប្រើប្រាស់ក្នុងការបង្ហូរទឹកស្រោចស្រពគ្របដណ្តប់ទៅលើផ្ទៃដីស្រែនៅក្នុងឃុំទាំងមូល ។ តាមរយៈការបង្ហាញពីមន្ត្រីធនធានទឹកបានបញ្ជាក់ថា ឃុំចំណាក្រោមនេះ មានប្រភពទឹកសំខាន់ជាងគេ គឺ ស្ទឹងស្ទោង ទំនប់ ៣០កញ្ញា និងបឹងមួយចំនួន ដែលហូរប្រទាក់គ្នាតាមផ្លូវទឹក ដែលបានបំបែកចេញ ពីស្ទឹងស្ទោងផ្នែក

ខាងលើតាមរយៈប្រឡាយមេ និងរងជាដើមចុះមកតំបន់ទំនាបទាបវាលស្រែប្រាំងក្នុងភូមិសាស្ត្រតំបន់ព្រៃលិចទឹកខាងត្បូងនៃឃុំ ។

ប្រភពទឹកទាំងនេះ សម្រាប់ការនាំទឹកមកស្រោចស្រពដំណាំស្រូវនៅរដូវប្រាំង និងនៅពេលមានគ្រោះរាំងស្ងួត ហើយក៏អាចជាជម្រកត្រីនាំឱ្យកើនឡើងបរិមាណត្រី បូកផ្សំជាមួយការយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារលាយឡំជាមួយបន្លែចម្រុះ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែដែលជាទម្រង់មួយនៃវារីវប្បកម្ម ដែលជាបច្ចេកទេសមួយជួយដើម្បីបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមវាលស្រែ ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែដែលបំផ្លាញផលស្រូវផង ដែលអាចផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់បំផុត សម្រាប់ប្រជាពលរដ្ឋនៅក្នុងឃុំគួរទទួលបាននូវអាហារ សម្រាប់ទ្រទ្រង់សុខភាព និងជីវិតរស់នៅអោយមានភាពល្អប្រសើរ ។

## ង. ហេដ្ឋារចនាសម្ព័ន្ធ និងការប្រើប្រាស់ជាសាធារណៈផ្សេងៗទៀត

### ង.១.វិស័យអប់រំ

កុមារគ្រប់រូប អាចមានសិទ្ធិរៀនសូត្រ មិនថាពួកគេស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ ។ ការផ្តល់ការគាំទ្រគ្រប់គ្រាន់ទៅដល់ការរៀនសូត្ររបស់កុមារ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីឱ្យពួកគេអាចអភិវឌ្ឍន៍ខ្លួនឈានទៅសម្រេចបានសក្តានុពលរបស់ពួកគេ។ យ៉ាងណាមិញនៅក្នុងឃុំចំណាក្រោម រយៈពេល១៥ឆ្នាំទៅមុខនឹងមានការកើនឡើងនូវចំនួនកុមារ និងមនុស្សវ័យជំទង់ក្នុងវ័យសិក្សា ដូចមានការគណនានៅក្នុងចំណុច ២.១.២ ស្តីពីចំណោលប្រជាសាស្ត្រខាងលើ ដែលចាំបាច់ត្រូវគិតគូរដោះស្រាយបន្ទប់រៀនបន្ថែមនៅគ្រប់កម្រិតនៅតាមទីតាំងសាលារៀនដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន ។

❖ **មត្តេយ្យសិក្សា:**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ កុមារមានអាយុពី៣-៥ឆ្នាំ នឹងកើនឡើងចំនួនៈ ៤ ២៤៤នាក់

-តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ បានឱ្យដឹងពីការកំណត់សម្រាប់មត្តេយ្យសាលាក្នុងមួយថ្នាក់មានចំណុះកុមារសិក្សារៀនសូត្រ **៥០នាក់**

**-ដូច្នេះក្នុងរយៈពេល ១៥ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់មត្តេយ្យត្រូវការបន្ថែមចំនួនៈ**

**៤ ២៤៤នាក់ /៥០ នាក់/បន្ទប់= ៨៥បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៥ បន្ទប់បន្ថែមចំនួនៈ**

**៨៥បន្ទប់ /៥ បន្ទប់/អគារ= ១៧ អគារ**

❖ **បឋមសិក្សា**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ៦-១១ ឆ្នាំនឹងកើនឡើងចំនួនៈ ២ ៥៦០នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់បឋមសិក្សាត្រូវការបន្ថែមចំនួនៈ**

**២៥៦០នាក់ ៖ ៤៥នាក់/បន្ទប់ = ៥៧បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ៦ បន្ទប់បន្ថែមចំនួនៈ**

**៥៧បន្ទប់ ៖ ៦ បន្ទប់/អគារ = ៩អគារ**

-តែក្នុងករណីត្រូវរៀន**២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សាតែចំនួនៈ**

**៩អគារ/វេន ៖ ២ វេន = ៥អគារ**

❖ **អនុវិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១២-១៤ ឆ្នាំនឹងកើនឡើងចំនួនៈ ១ ៤១៥នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

**១៤១៥នាក់ ៖ ៤៥នាក់/បន្ទប់ =៣១បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ១២ បន្ទប់បន្ថែមចំនួនៈ**

**៣១បន្ទប់ ៖ ១២បន្ទប់/អគារ =៣អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សារតែចំនួនៈ

**៣ អគារ / វេន ៖ ២ វេន = ២អគារ**

❖ **វិទ្យាល័យ**

-ក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ សិស្សមានអាយុពី ១៥-១៧ឆ្នាំនឹងកើនឡើងចំនួនៈ ១ ៣៩៧ នាក់

**-ដូច្នេះក្នុងរយៈពេល ១៥ ឆ្នាំ (២០១៧-២០៣២) បន្ទប់សិក្សាសម្រាប់ថ្នាក់អនុវិទ្យាល័យសិក្សាត្រូវការបន្ថែមចំនួនៈ**

**១៣៩៧នាក់ ៖ ៤៥នាក់/បន្ទប់ = ៣១បន្ទប់**

**-ដែលនឹងត្រូវការសាងសង់អគារសិក្សាដែលមាន ១២ បន្ទប់បន្ថែមចំនួនៈ**

**៣១ បន្ទប់ ៖ ១២បន្ទប់/អគារ = ៣អគារ**

-តែក្នុងករណីត្រូវរៀន២វេនក្នុងមួយថ្ងៃដូចបច្ចុប្បន្នត្រូវការបន្ថែមអគារសិក្សារតែចំនួនៈ

**៣អគារ / វេន ៖ ២ វេន = ២អគារ**

តារាង 34៖ កំណើនកុមារ តម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ២០១៨ ដល់ឆ្នាំ២០៣២

| បរិយាយ | ចំនួនក្នុងឆ្នាំ២០១៧ | អនាគត២០៣២ | បម្រែបម្រួល |
|---|---|---|---|
| **សាលាមេត្តយ្យ** | | | |
| សិស្ស | ១១៩ នាក់ | ៤ ២៤៤នាក់ | ៤ ១២៥នាក់ |
| បន្ទប់ | ៦ បន្ទប់ | ៨៥ បន្ទប់ | ៧៩ បន្ទប់ |
| អគារ | ៦ អគារ | ១៧ អគារ | ១១ អគារ |
| **សាលាបឋមសិក្សា** | | | |
| សិស្ស | ២០៤៣ នាក់ | ២ ៥៦០នាក់ | ៥១៧ នាក់ |
| បន្ទប់ | ៦៣ បន្ទប់ | ៥៧បន្ទប់ | -៦បន្ទប់ |
| អគារ | ១០ អគារ | ៩ អគារ | -១អគារ |
| **អនុវិទ្យាល័យ** | | | |
| សិស្ស | ៤០៦ នាក់ | ១ ៤១៥នាក់ | ១ ០០៩ នាក់ |
| បន្ទប់ | ១០ បន្ទប់ | ៣១បន្ទប់ | ២១ បន្ទប់ |
| អគារ | ១ អគារ | ៣ អគារ | ២ អគារ |
| **វិទ្យាល័យ** | | | |

| | | | |
|---|---|---|---|
| សិស្ស | ០០នាក់ | ១ ៣៩៧នាក់ | ១ ៣៩៧ នាក់ |
| បន្ទប់ | ០០ បន្ទប់ | ៣១ បន្ទប់ | ៣១ បន្ទប់ |
| អគារ | ០០ អគារ | ៣ អគារ | ៣ អគារ |

### ង.២. វិស័យសុខាភិបាល

នៅក្នុងឃុំចំណាក្រោម មានមណ្ឌលសុខភាពមួយកន្លែងដែលស្ថិតនៅក្នុងភូមិសណ្តាន់ ហើយបើផ្អែកទៅតាមកំណើនប្រជាជន ដែលមានការកើនឡើង និងស្ថានភាពភូមិសាស្ត្ររបស់ឃុំទាំងមូល យើងឃើញថាភូមិដែលនៅឆ្ងាយពីមណ្ឌលសុខភាពមានចំនួន ០៦ភូមិ ភូមិលៀប ភូមិព្រះនង្គ័ល ភូមិសំព័រ ភូមិស្រីរងិត ភូមិជីអាប់ និងភូមិចំណាក់។ ជាយុទ្ធសាស្ត្រក្រុមប្រឹក្សាឃុំអណ្តិតិទី៤ ក៏ដូចជាមេភូមិ ដូច្នេះជាគោលការណ៍ ឃុំបានលើកផែនការពង្រីក និងសាងសង់អាគារបន្ថែម នៅក្នុងបរិវេណមណ្ឌលសុខភាពមានស្រាប់នៅក្នុងភូមិសណ្តាន់ ដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងឃុំទាំងមូល អាចមានលទ្ធភាពទទួលសេវានៅទីនោះ ។ ឃុំមានផែនការស្នើសុំមធ្យោបាយដឹកជញ្ជូនអ្នកជម្ងឺ សម្ភារបរិក្ខាពេទ្យ ថ្នាំសង្កូវ និងបុគ្គលិកពេទ្យបន្ថែមទៀតរយៈពេល ១៥ឆ្នាំ ខាងមុខដើម្បីងាយស្រួល ផ្តល់ការគាំទ្រសេវាថែទាំ និងព្យាបាលសុខភាពផ្សេងៗរបស់ប្រជាពលរដ្ឋបានរហ័សទាន់ចិត្តនិងទាន់ពេល ។

### ង.៣. អគ្គិសនី

អគ្គិសនី គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ជីវិតរស់នៅរបស់មនុស្សយើង។ អគ្គិសនីផ្តល់ឲ្យយើងនូវសន្តិសុខ សុវត្ថិភាព សុខភាព និងភាពសំបូររុងរឿង ដូចជាជួយដោះស្រាយបញ្ហា និងធ្វើឲ្យកាន់តែប្រសើរឡើងនូវសន្តិសុខ សុវត្ថិភាព ការប្រែប្រួលអាកាសធាតុ ផលិតកម្មស្បៀងអាហារ និងការពង្រឹងសេដ្ឋកិច្ចដោយរួមទាំងការអប់រំ និងកំសាន្តផងដែរ ។

យោងទៅតាមទិន្នន័យឃុំចំណាក្រោមដូចបានរៀបរាបក្នុងជំពូកទី១ ប្រជាពលរដ្ឋប្រើប្រាស់បណ្តាញអគ្គិសនីមានចំនួន ៨៤៩ខ្នងផ្ទះ ស្មើនឹង ១៧ភាគរយ នៅសល់ ៨៣ភាគរយ ទៀតដែលមិនមានភ្លើងអគ្គិសនីប្រើប្រាស់នៅឡើយ ។ ដូច្នេះ នៅពេលអនាគត១៥ឆ្នាំទៅមុខទៀតនឹងមានគ្រួសារកើនឡើងថែមទៀត អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ជាពិសេសក្រុមប្រឹក្សាឃុំចំណាក្រោម ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការដោះស្រាយពង្រីកបណ្តាញអគ្គិសនីតភ្ជាប់ផ្គត់ផ្គង់ឱ្យដល់គ្រប់គ្រួសារបានប្រើប្រាស់ ។

### ង.៤. ទីលានចាក់សំរាម

សំរាម គឺជាកាកសំណល់ដែលគេបានបោះបង់ចោល ហើយវាមានពីរបែប គឺកាកសំណល់រឹងនិងរាវ។ ដូច្នេះសំរាមគឺជាអ្វីដែលបំបែកចេញពីបរិស្ថានយើង និងជាការបង្កើតកន្លែងគរមួយផ្សេងទៀតប្រសិនបើយើងមិនប្រុងប្រយ័ត្ន ។ មានគំនរសំរាម នៅពេលមានភ្លៀងធ្លាក់ចុះមក គឺដូចជាការចម្រោះជាតិពុល គ្រប់បែបយ៉ាង ឱ្យហូរជ្រាបទៅបំពុលដី បំពុលទឹក និងបំពុលដល់ប្រភពទឹកនៅក្នុងស្រទាប់ដីខាងក្រោម ជាហេតុធ្វើឱ្យទឹកស្អាតក្លាយជាទឹកមិនស្អាត មានលោហៈធ្ងន់ និងជួនកាលមានបាក់តេរីកាចៗ ដែលនៅពេលនោះ មានលេចឡើងនូវជម្ងឺរាតត្បាតផ្សេងៗដោយសារតែការទទួលទានទឹកមិនស្អាត ។

ចំពោះសំរាមនៅក្នុងឃុំចំណាក្រោម បច្ចុប្បន្ននេះប្រជាពលរដ្ឋភាគច្រើនបោះចោលសំរាមនៅក្បែរផ្ទះ ខ្លះចោលរាយប៉ាយនៅតាមផ្លូវ ខ្លះដុតចោល ដែលធ្វើឱ្យរងការបំពុលពីផ្សែងដុត និងបាត់បង់សោភ័ណភាពក្នុងភូមិ

ឃុំ។ ដើម្បីអាចគ្រប់គ្រងសំរាមបាន ឃុំត្រូវរកទីតាំងនៅក្នុងឃុំ ដែលនៅដាច់ដោយឡែកឆ្ងាយពីភូមិធ្វើជាទីលានចាក់សំរាមមួយកន្លែង ដើម្បីប្រមូលសំរាមដែលមាននៅក្នុងឃុំយកទៅរក្សាទុកឱ្យបានគត់មត់ ឬត្រូវប្រមូលសំរាមប្លាស្ទិកយកទៅកែច្នៃផលិតឡើងវិញ ចំណែកសំរាមចេញពីផ្ទះបាយនិងស្លឹកឈើផ្សេងពីប្លាស្ទិកអាចកែច្នៃធ្វើជាជីដូចជាជីកំប៉ុស្តជាដើម ដើម្បីប្រើប្រាស់ក្នុងការបង្កើនគុណភាពដីដាំដុះ ។ ជារួមសំខាន់ជាងគេបំផុតត្រូវលុបបំបាត់សំរាម ប្លាស្ទិកឱ្យអស់ពីភូមិ ឃុំ ។

### ង.៥. ស្រះទឹក និងអណ្តូងទឹក

ទឹកគឺជាផ្នែកមួយនៃធាតុដ៏សំខាន់បំផុត សម្រាប់រាងកាយមនុស្ស ជាពិសេសសម្រាប់សុខភាព ដើម្បីធានាបាននូវការរស់រានមានជីវិតរបស់មនុស្ស។ ទឹកអាចនឹងមាននៅគ្រប់ទីកន្លែ ប៉ុន្តែមិនត្រូវបានយកមកសម្រាប់ការទទួលទានបានទាំងអស់នោះទេ គឺត្រូវការទឹកដែលស្អាត ។ នៅក្នុងឃុំចំណាក្រោម បច្ចុប្បន្នមានការប្រើប្រាស់ទឹកស្អាតសម្រាប់ទទួលទាន តាមរយៈការប្រើទឹកស្រះ និងអណ្តូងដូចបានរៀបរាប់ក្នុងជំពូកទី១នៃរបាយការណ៍នេះ ប៉ុន្តែបានរកឃើញថា ចំនួនស្រះទឹកនិងអណ្តូងទាំងអស់នេះមិនមានបរិមាណគ្រប់គ្រាន់សម្រាប់បំពេញតម្រូវរបស់មនុស្ស និងសត្វចិញ្ចឹមគ្រប់គ្រាន់នារដូវប្រាំងបានឡើយ ។

ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងការខ្វះខាតនាពេលបច្ចុប្បន្នក៏ដូចជាឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋនៅក្នុងរយៈពេល១៥ឆ្នាំខាងមុខបាន អាជ្ញាធរដែនដីពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំចំណាក្រោម ត្រូវយកចិត្តទុកដាក់លើកទឹកចិត្តឱ្យប្រជាពលរដ្ឋក្នុងឃុំត្រងទឹកភ្លៀងនៅរដូវវស្សារក្សាទុកក្នុងអាងស្តុកតាមផ្ទះរៀងៗខ្លួន សម្រាប់ទុកដោះស្រាយការប្រើប្រាស់នៅរដូវប្រាំងដែលខ្សត់ទឹក ហើយថែមពីលើនេះទៀតក៏ត្រូវបំផុសឱ្យមានការរៀបចំជីកស្រះសហគមន៍ផងដែរ ព្រមទាំងជំរុញលើកទឹកចិត្តដល់វិស័យឯកជនឱ្យផលិតទឹកស្អាតតបណ្តាញឱ្យដល់គ្រប់ខ្នងផ្ទះប្រជាពលរដ្ឋបានប្រើប្រាស់គ្រប់ក្រុមគ្រួសារដែលជាជម្រើសដ៏ល្អបំផុត ។

## ២.២. តំបន់រសើប

តំបន់រសើប គឺជាតំបន់ ដែលទាមទារនូវកិច្ចការពារបន្ថែម និងជាពិសេសដោយផ្អែកលើសារៈសំខាន់ ឬជីវចម្រុះនៃបរិស្ថាន បេតិកភ័ណ្ឌវប្បធម៌ តម្លៃខាងផ្លូវចិត្តដែលមានលក្ខណៈដូចជា៖ តំបន់ព្រៃណីសម្រាប់ជនជាតិដើមភាគតិច ឬក៏មូលហេតុសំខាន់ៗផ្សេងៗទៀត ។ តំបន់បង្ហាញបញ្ហាចោទ ចាំបាច់ត្រូវតែកំណត់ឱ្យបានច្បាស់ ដើម្បីធានាថាឃុំនិងអ្នកពាក់ព័ន្ធត្រូវការដឹងឮនូវតំបន់ដែលត្រូវការពារពិសេសទាំងនេះ ។ តំបន់រសើបដែលមាននៅក្នុងឃុំចំណាក្រោម ត្រូវបានកំណត់ទៅដីសង្ស័យថាមានមីនចំនួន ០៣ កន្លែងប៉ុណ្ណោះ ដែលក្នុងនោះស្ថិតនៅក្នុងភូមិព្រះនង្គល ១កន្លែង ភូមិត្រពាំងទ័ពស្តេច ១កន្លែង និងភូមិស្រីរងឹត ១កន្លែង ដែលត្រូវទាមទារនូវកិច្ចការពារបន្ថែមពិសេសដើម្បីធ្វើការហាមឃាត់ប្រជាពលរដ្ឋចូលទៅកាន់កាប់ និងប្រើប្រាស់ដីតំបន់នេះ ដែលនឹងនាំឱ្យពួកគាត់មានគ្រោះថ្នាក់ពីគ្រាប់មីន ដែលមិនទាន់ផ្ទុះទាំងនោះ និងដីតំបន់៣ជុំវិញបឹងទន្លេសាប សហគមន៍នេសាទនិងតំបន់ប្រើប្រាស់ច្រើនយ៉ាង ទីទួលបុរាណ ប្រាសាទ និងស្ថានីយ៍បុរាណជា ដើមដែលត្រូវយកចិត្តទុកដាក់និងការពារ ។ តំបន់រសើបដែលមាននៅក្នុងឃុំចំណាក្រោម ដូចបានរៀបរាប់ខាងលើមានបង្ហាញនៅក្នុងផែនទីតំបន់រសើបខាងក្រោម ។

ផែនទី 10៖ ផែនទីតំបន់រសើបឃុំចំណាក្រោម



## ២.៣. ការប្រឈម

### ២.៣.១. ការប្រឈមដោយធម្មជាតិ

#### ក. កំណើនប្រជាជន

ការកើនឡើងរបស់ប្រជាពលរដ្ឋ គឺកើនឡើងនូវសេចក្តីត្រូវការ ពង្រីកដីស្រែ ចម្ការ លំនៅឋានបន្ថែមទៀត ដែលជាមូលហេតុនៃការបាត់បង់ព្រៃឈើ ព្រៃលិចទឹក ដោយសារការកាប់ធ្វើអុសដុត ធ្វើជាដីកសិកម្ម ដែលជាកត្តាធ្វើឲ្យមានការប៉ះពាល់ដល់ការប្រើប្រាស់ធនធានធម្មជាតិ ក៏ដូចជាដីធ្លីផងដែរហើយបញ្ហាប្រឈមមួយចំនួនដូចជាៈ

-មានការខ្វះខាតដីលំនៅឋាន ដែលនាំឱ្យមានការដោះស្រាយផលប៉ះពាល់ទៅដល់ដីស្រែ

-មានការខ្វះខាតដីស្រែ ដែលនាំឱ្យពិបាកដោះស្រាយ ដោយនៅក្នុងឃុំពុំមានដីសល់ទំនេរសម្រាប់បំពេញការខ្វះខាតនេះ

-មានការខ្វះខាតដល់ការផ្តល់សេវាអប់រំ ដែលត្រូវដោះស្រាយការសាងសង់សាលារៀន គ្រូបង្រៀន និងសម្ភារៈសិក្សាបន្ថែម

-មានការខ្វះខាតសេវាសុខាភិបាល ដែលត្រូវដោះស្រាយគ្រូពេទ្យ ឧបករណ៍និងសម្ភារៈពេទ្យនិងថ្នាំពេទ្យបន្ថែម

-មានការខ្វះខាតទឹកស្អាត អគ្គិសនី ដែលត្រូវដោះស្រាយផ្គត់ផ្គង់បន្ថែម។

#### ខ. គ្រោះធម្មជាតិ ការរេចរិលនៃធម្មជាតិ

បច្ចុប្បន្ននៅក្នុងឃុំចំណាក្រោម គេបានកត់សំគាល់ថា មានជួបប្រទះនូវគ្រោះធម្មជាតិកើតឡើងស្ទើរតែរៀងរាល់ឆ្នាំ ដូចជាគ្រោះរាំងស្ងួតជាដើម ទន្ទឹមនឹងនោះដីធ្លីដែលជាធនធានធម្មជាតិកម្រក៏មានភាពរិចរិលទៅៗ ដូចជាធ្វើឱ្យដីស្រែរឹង និងខ្សោះជីជាតិដោយសារការប្រើប្រាស់ជីគីមី និងថ្នាំគីមីសម្លាប់សត្វល្អិតលើដំណាំស្រូវ និងដំណាំដទៃទៀតមិនស្របតាមបទដ្ឋានបច្ចេកទេស ដែលបានធ្វើការណែនាំដោយមន្ត្រីជំនាញកសិកម្មស្រុក និងខេត្ត។ ទន្ទឹមនឹងនេះ មានការថយចុះនិងបាត់បង់ធនធានជលផលជាពិសេសមច្ឆាជាតិ ដោយការប្រើប្រាស់ឧបករណ៍ឆក់ដែលជាឧបករណ៍នេសាទខុសច្បាប់ ។ ទៅថ្ងៃអនាគតប្រជាពលរដ្ឋនៅតែបន្ត ជួបប្រទះនូវបញ្ហាប្រឈមទាំងអស់នេះជាដដែលបើមិនមានយន្តការឬដំណោះស្រាយទប់ទល់នឹងគ្រោះរាំងស្ងួត ព្រមទាំងមានការកែប្រែឥរិយាបថក្នុងការប្រើប្រាស់ដីធ្លីសម្រាប់កសិកម្មឱ្យបានសមស្របទេនោះ។

### ២.៣.២. ការប្រឈមដោយ ការអភិវឌ្ឍន៍ដែលពុំមាននិរន្តរភាព

ជាការពិតណាស់រាល់គម្រោងអភិវឌ្ឍន៍នានា ពាក់ព័ន្ធការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសការប្រើប្រាស់ដីក្នុងទីតាំងភូមិសាស្ត្រណាមួយ តែងនាំមកការរីកចម្រើនជានិច្ច តែផ្ទុយទៅវិញបើគម្រោងអភិវឌ្ឍន៍ទាំងនោះពុំទាន់បានគិតគូរគ្រប់ជ្រុងជ្រោយទៅដល់ទីតាំងភូមិសាស្ត្រនីមួយៗ និងសក្តានុពលនៃធនធានដែលមាន វានឹងនាំមកនូវផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងបរិស្ថាននាពេលអនាគត ដោយមិនអាចធានាចិរភាពនៃគម្រោងទាំងនោះដល់កូនចៅជំនាន់ក្រោយក្នុងតំបន់នោះបានឡើយ ដូចជា ស្ថានភាពនៅក្នុងឃុំចំណាក្រោម ដែលជាឃុំគោលដៅសិក្សារៀបចំផែនការប្រើប្រាស់ដីដូចបានរៀបរាប់ក្នុងជំពូកទី១ នៃរបាយការណ៍នេះបានឱ្យដឹងថាឃុំចំណាក្រោម មានស្ថានភាពភូមិសាស្ត្រជាវាលទំនាបមានធនធានដីអំណោយផលដល់ដំណាំស្រូវ ដែលជាសក្តានុពលទៅដល់ការអភិវឌ្ឍន៍ដល់ឃុំនេះ ដោយមិនមានការអះអាងណាផ្សេងក្រៅពីនេះនៅឡើយ ។

ដូចនេះឃុំចំណាក្រោមគួរជៀសវាងដាច់ខាតនៅគម្រោងអភិវឌ្ឍន៍ទាំងឡាយណាដែលនាំឱ្យមានផលប៉ះពាល់ដល់ការបាត់បង់ដីស្រែដែលខ្លួនមាន ធ្វើឱ្យឃុំមានការថយចុះឱកាសអភិវឌ្ឍន៍ ដូចជាគម្រោងចាក់លុបដីស្រែបង្កក ទុកលក់ឬពុះដីឡូត៍លក់ ដើម្បីកេងយកផលចំណេញពីឈ្មួញ និងគម្រោងជីកយកអាចម៍ដីយកលក់ជាដើម ។ លើកលែងតែគម្រោងណាដែលពាក់ព័ន្ធ ដែលធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធកសិកម្មដូចជាកសិដ្ឋានផលិតពូជស្រូវ ស្រែគម្រូផលិតជីធម្មជាតិ ទុកដាក់គ្រឿងយន្តកសិកម្ម ទន្ទឹមនិងនេះក៏នៅមានគម្រោងអភិវឌ្ឍន៍ដល់ការរស់នៅ និងបរិស្ថាន ដែលគួរជៀសវាងផងដែរ ដូចជា គម្រោងបង្កើតសិប្បកម្ម ឧស្សាហកម្ម ដែលធ្វើឱ្យមានការបង្ហូរទឹកស្អុយកខ្វក់ជាដើម។ល។ ទន្ទឹមនឹងការប្រឈមដោយសារការអភិវឌ្ឍន៍ខាងលើដែលត្រូវជៀសវាង ក៏នៅមានការប្រឈមទៅ និងអំពើអនាធិបតេយ្យ ដែលកើតឡើងពីការដោះស្រាយការខ្វះខាតរបស់ប្រជាពលរដ្ឋក្នុងឃុំផងដែរ ដូចជាការសាងសង់ផ្ទះស្នាក់លើដីនៅតាមមាត់ចំណាក្រោម មាត់ស្ទឹង តាមចិញ្ចើមផ្លូវសាធារណៈ ការទន្ទ្រានដីទួលសាធារណៈ ធ្វើស្រែបំពានលើចំណាក្រោម ព្រមទាំងការនេសាទខុសច្បាប់ជាដើម ។

## ២.៤. ឱកាស

### ២.៤.១. ដោយអំណោយផលពីធម្មជាតិ

នៅក្នុងលោកយើងនេះ ធម្មជាតិបានផ្តល់នូវធនធានដ៏មានសារសំខាន់សម្រាប់ធ្វើអ្វីៗគ្រប់បែបយ៉ាង ដែលមនុស្សចង់ធ្វើ ដូចជាមនុស្សប្រើប្រាស់ដីនឹងទឹកសម្រាប់ការដាំដំណាំ ឈើធ្វើអុសដុតសម្រាប់ផ្តល់កំដៅ ឬ សាងសង់ទីជម្រក ខ្យល់អាកាស ត្បូងថ្ម ប្រេង ឧស្ម័នធម្មជាតិ និងរ៉ែជាវត្ថុធាតុដើមជាច្រើនទៀត ដូចជាដែកទង់ដែងសម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ។ ចំណែកនៅក្នុងឃុំចំណាក្រោម យើងផ្តោតសំខាន់ទៅធនធានដីដែលមានសក្តានុពលលើសលប់ទៅលើការអភិវឌ្ឍន៍ឃុំ ដូចបានរកឃើញ និងរៀបរាប់នៅក្នុងជំពូកទី១នៃរបាយការណ៍នេះ ដូចខាងក្រោម៖

- ស្ថានភាពដីជាវាលទំនាប អំណោយផលដល់ការដាំដុះដំណាំស្រូវ
- នៅជិតប្រភពទឹកទន្លេ អាចមានលទ្ធភាពនាំទឹកមកស្រោចស្រពដំណាំស្រូវនៅពេលជួបប្រទះគ្រោះរាំងស្ងួត និងមានលទ្ធភាពនាំទឹកមកស្រោចស្រពបង្កើនរដូវធ្វើស្រែបានច្រើនដង
- នៅរដូវវស្សាមានភ្លៀងធ្លាក់ច្រើនអាចស្រោចស្រពដំណាំស្រូវបាន
- អាកាសធាតុ ក្តៅ ហើយសើម អំណោយផលដល់ការលូតលាស់របស់រុក្ខជាតិ

### ២.៤.២. ដោយបច្ចេកវិទ្យាថ្មីៗ

ជីវិតរស់នៅ ដែលយើងកំពុងតែទទួលបានភាពប្រសើរឡើងនាពេលបច្ចុប្បន្ននេះ គឺដោយសារតែមានការអភិវឌ្ឍន៍ ផ្នែកបច្ចេកវិទ្យា ។ បច្ចេកវិទ្យាថ្មីៗធ្វើឱ្យមានការផ្លាស់ប្តូរបានប្រសើរឡើងនៃជីវិតរស់នៅរបស់យើង ដែលអ្វីៗបច្ចុប្បន្នកាន់តែប្រសើរឡើង និងងាយស្រួលជាងមុន ។ បច្ចេកវិទ្យាថ្មីអាចកាត់បន្ថយបាននូវពេលវេលា និងការចំណាយទៅលើកម្លាំងពលកម្មក្នុងផលិតកម្មនានា ។

បច្ចុប្បន្ន ឃុំចំណាក្រោមដែលមានសក្តានុពលខ្លាំងពឹងផ្អែកទៅលើផលិតកម្មដំណាំស្រូវ ហើយនាពេលអនាគតក៏នៅតែពឹងផ្អែកលើផលិតកម្មដំណាំស្រូវដដែលដែរនោះ នឹងចាំបាច់ត្រូវការបច្ចេកវិទ្យាទំនើបទាន់សម័យសម្រាប់វិស័យកសិកម្មដំណាំស្រូវ ដើម្បីជួយជំរុញឱ្យមានការកើនឡើងផលិតផលស្រូវអាចដោះស្រាយបាននូវសន្តិសុខស្បៀង និងប្រាក់ចំណូលកាន់តែខ្ពស់នាំឱ្យជីវភាពរស់របស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើងនៅក្នុងពេលដែល

មានកំណើនប្រជាពលរដ្ឋកាន់តែខ្ពស់ ។ តាមរយៈបច្ចេកវិទ្យាថ្មី នឹងនាំឱ្យប្រជាពលរដ្ឋមានឱកាសអាចប្រើប្រាស់គ្រឿងយន្តកសិកម្មទំនើបទាន់សម័យសម្រាប់ការផលិតដំណាំស្រូវដែលរួមមានដូចជា ៖ ម៉ាស៊ីនភ្ជួររាស់ដី ម៉ាស៊ីនពង្រាបដីស្រែដោយប្រើប្រព័ន្ធឡាស៊ែរ ម៉ាស៊ីនដកស្ទូងជ្រូនបាញ់ថ្នាំសម្លាប់សត្វល្អិត និងដាក់ជី ម៉ាស៊ីនច្រូតកាត់និងបោកបែនព្រមទាំងដឹកជញ្ជូនជាដើម។ល។

### ២.៤.៣. ដោយគម្រោងវិនិយោគ

នាពេលអនាគត នៅឃុំចំណាក្រោម ដែលមានសក្តានុពលខ្ពស់ទៅលើដំណាំស្រូវ នឹងនាំឱ្យមានផ្តួចផ្តើមបង្កើតគម្រោងវិនិយោគនានា ដែលភាគច្រើនផ្តោតទៅលើដំណាំស្រូវ ដូចជា គម្រោងបង្កើតកសិដ្ឋានកសិកម្មដើម្បីជំរុញការផលិតកម្មដំណាំស្រូវ គម្រោងវិនិយោគទៅលើការកែច្នៃផលិតផលស្រូវដើម្បីនាំចេញដែលនឹងផ្តល់ការងារបន្ថែមទៅដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនប្រាក់ចំណូលអោយបានកាន់តែខ្ពស់ នាំឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើង ព្រមទាំងជួយកាត់បន្ថយបាននូវភាពក្រីក្រ ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។

## ២.៥. បញ្ហា មូលហេតុ និងដំណោះស្រាយ

បើផ្អែកតាមការរកឃើញនៅក្នុងជំពូកទី១នៃរបាយការណ៍នេះ អាចឱ្យយើងធ្វើការវិភាគនិងចងក្រងបាននូវបញ្ហាដែលកើតមាននៅក្នុងឃុំចំណាក្រោម មូលហេតុដែលនាំឱ្យកើតមានបញ្ហា និងដំណោះស្រាយបញ្ហាទាំងអស់នេះ ដោយមានបង្ហាញអំពីទីតាំងដែលកើតមានបញ្ហានៅក្នុងតារាង ព្រមទាំងកំណត់បាននូវទីតាំងបញ្ហានៅក្នុងផែនទីទៀតផងដែរ ដូចមាននៅខាងក្រោមនេះ៖

តារាង 35៖ បញ្ហាប្រឈម និងសក្តានុពល (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ)

| បញ្ហាប្រឈម | ទីតាំងបញ្ហា | មូលហេតុនៃបញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| ១.ទីតាំងលំនៅឋាន នៅលើដីសាធារណៈរបស់រដ្ឋ (លើស្ទឹង ប្រឡាយ...) (៥៥គ្រួសារ) | គ្រប់ភូមិ | ក-កំណើនប្រជាជនក្នុងឃុំ និងខ្វះដីលំនៅឋាន | ក.១ ខ.១-មន្ទីរ ឬក្រសួង ពាក់ព័ន្ធ ដោះស្រាយដីសម្បទានសង្គមកិច្ច |
| | | ខ-រស់នៅតាំងពីដូនតា មក | ខ.១-បញ្ឈប់ការសាងសង់លំនៅឋានថ្មីនៅលើដីសារធារណៈរបស់រដ្ឋ<br>ខ.២-ស្រង់ស្ថិតិប្រជាជននៅលើដីសាធារណៈរបស់រដ្ឋ<br>ខ.៣-ផ្សព្វផ្សាយច្បាប់ភូមិបាល |
| ២.កង្វះខាតទីលានទុកដាក់សម្រាម ក្នុងឃុំ | របស់ឃុំរួម | ក-គ្មានសណ្តាប់ធ្នាប់ មិនមានទីតាំង សមរម្យ | ក.១-យល់ដឹងពីការបែងចែកសម្រាម (ប្រភេទសម្រាមនីមួយៗ) |
| | | ខ-កង្វះខាតទីលានចាក់សម្រាម (អត់មានដី) | ខ.១.គ.១-ជម្រុញឲ្យក្រុមហ៊ុនវិនិយោគក្នុងការប្រមូលសម្រាមកែច្នៃ<br>ខ.២-មន្ទីរ ឬក្រសួង ពាក់ព័ន្ធ ដោះស្រាយដីសម្បទានសង្គមកិច្ច។ |
| | | គ-ចោលសម្រាមលើដីសារធារណៈរបស់រដ្ឋ | |
| ៣.ផ្លូវពិបាកធ្វើដំណើរចំពោះ | | ក-ផ្លូវខូច | ក.១-ជួសជុលផ្លូវលំក្រាលគ្រួសក្រហម |

| បញ្ហាប្រឈម | ទីតាំងបញ្ហា | មូលហេតុនៃបញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| ផ្លូវគ្រួសក្រហម | គ្រប់ភូមិ | | ក.២-ក្រាលបេតុង ឬ កៅស៊ូ |
| | | ខ-ផ្លូវត្រូវទឹកហូរដាច់ (ទឹកភ្លៀង) | ខ.១-ដាក់កាត់ផ្លូវ |
| | | គ-គ្មានស្ពានឆ្លង | គ.១-ធ្វើស្ពានឆ្លង |
| ៤.ខ្វះដីកសិកម្ម (១៨៤គ្រួសារ) | គ្រប់ភូមិ | ក-លក់សងបំណុល | ក.ខ.គ.១-ស្នើសុំដីសម្បទានសង្គមកិច្ច |
| | | ខ-កំណើនគ្រួសារក្នុងភូមិ | |
| | | គ-គ្មានដីកសិកម្មបម្រុងទុក | |
| | | ឃ-ដីកសិកម្មតិច | ឃ.១-ផ្ដល់បច្ចេកទេសកសិកម្មទំនើបៗ |
| ៥.ខ្វះប្រភពទឹក | គ្រប់ភូមិ | ក-ខ្វះទឹកនៅរដូវប្រាំង | ក.ខ.គ.១-ធ្វើអាងស្តុកទឹកឲ្យសហគមន៍ |
| | | ខ-ខ្វះអាងស្តុកទឹកនៅរដូវប្រាំង | |
| | | គ-ខ្វះប្រព័ន្ធប្រឡាយ(មិនគ្រប់តាមតម្រូវការ) | គ.១-សាងសង់ប្រព័ន្ធធារាសាស្រ្តបន្ថែម<br>គ.២-ជួសជុលហេដ្ឋារចនាសម្ព័ន្ធធន់ធានទឹក |
| | | ឃ-ខ្វះខាត់ទឹកកសិកម្មទាំងស្រុងនៅរដូវប្រាំង | ឃ.ង.១-បង្កើតសហគមន៍ប្រើប្រាស់ទឹក |
| | | ង-ខ្វះសហគមន៍ប្រើប្រាស់ទឹក | |
| ៦.ទិន្នផលស្រូវទាប | គ្រប់ភូមិ | ក-ដីអត់រៀបស្មើ | ក.១-កៀរដីឲ្យស្មើ |
| | | ខ-ដីខ្សោះជីជាតិ | ខ.គ.ង.១-បណ្តុះបណ្តាលការប្រើប្រាស់ដីធម្មជាតិ និងថ្នាំសម្លាប់សត្វល្អិត |
| | | គ-កណ្តុល ខ្យងក្រហម សត្វបំផ្លាញ | |
| | | ឃ-ខ្វះពូជស្រូវល្អ | ឃ.១-ផ្តល់ពូជស្រូវមានទិន្នផលខ្ពស់<br>ឃ.២-ជ្រើសរើសពូជល្អ ដែលធន់អាកាសធាតុ និងតម្រូវការទីផ្សារ |
| | | ង-ខ្វះជី | ង.២-ប្រែគុណភាពដី ដោយប្រើជីកំប៉ុស្ត |
| | | ច-ខ្វះប្រឡាយបញ្ចេញបញ្ចូលទឹក | ច.១-ស្តារប្រឡាយនិងធ្វើទ្វារទឹក<br>ច.២-ធ្វើទ្វាទឹក និងប្រឡាយថ្មី |
| | | ឆ-មិនស្ទូវថៃទាំ | ឆ.ជ.១-បណ្តុះបណ្តាលបច្ចេកទេសដំណាំស្រូវ |
| | | ជ-ធ្វើស្រែតាមទម្លាប់ចាស់ | ជ.២ -ស្រែបង្ហាញតាមបែបទំនើប |
| ៧. បាត់បង់ព្រៃលិចទឹក  | ១.ភូមិស្រីរងឹត<br>២.ភូមិស្វាយអៀ<br>៣.ភូមិចំណាក់ | ក-កាប់រានយកដីធ្វើស្រែប្រាំង | ក.ខ.១-ផ្សព្វផ្សាយច្បាប់ជលផល |
| | | ខ-កាប់ឧសដុត | ខ-១-ដាំដើមឈើឡើងវិញ |
| ៨. បាត់បង់ធនធានជលផល | គ្រប់ភូមិ | ក-ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ | ក.ខ.គ.ឃ.ង.១-ផ្សព្វផ្សាយច្បាប់ជលផល |

| បញ្ហាប្រឈម | ទីតាំងបញ្ហា | មូលហេតុនៃបញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| | | ខ-ខ្វះជម្រកត្រីពង<br>គ-កំណើនអ្នកនេសាទច្រើនយ-នេសាទនៅរដូវត្រីពង<br>ង-ប្រើប្រាស់ឧបករណ៍ខុសច្បាប់ | ខ.គ.២-បង្កើនការចិញ្ចឹមត្រីតាមគ្រួសារ<br>ក.ឃ.ង.២-អប់រំ និងផ្សព្វផ្សាយបំរាមនេសាទនៅរដូវត្រីពង |
| | | ច-ការលប់បឹងធម្មជាតិ | ច.១-ផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ជលផល ទប់ស្កាត់ការប្រើឧបករណ៍ខុសច្បាប់ |
| | | ឆ-ការកាប់បំផ្លាញព្រៃលិចទឹក | ឆ.១-បង្កើតសហគមន៍ការពារព្រៃលិចទឹក |
| | | ជ-ការបំពុលទឹកដោយចាក់ កាកសំណល់រឹងរាវចូលក្នុងទឹក | ជ.១-អប់រំផ្សព្វផ្សាយពីច្បាប់ និងផលប៉ះពាល់ពីការគ្រប់គ្រងកាក សំណល់រឹងរាវគ្រប់ប្រភេទ<br>ជ.២-បង្កើតបទបញ្ជាផ្ទៃក្នុងសហគមន៍ស្តីពីការគ្រប់គ្រងកាកសំណល់រឹងរាវ |
| ៩. ខ្វះទឹកស្អាតប្រើប្រាស់ប្រាស់ | គ្រប់ភូមិ | ក-គ្មានទឹកស្អាតប្រើប្រាស់<br>ខ-ប្រភពទឹកស្អាតនៅឆ្ងាយ | ក.១-ធ្វើឧបករណ៍ចម្រោះទឹកឲ្យស្អាត<br>ក.ខ.២-តបណ្តាញទឹកស្អាត<br>ខ.៣-ធ្វើអាងស្តុកទឹក |
| | | គ-អណ្តូងភាគច្រើនមិនអាចប្រើបាន (ក្រហមជូរ ប្រៃ) | គ-ជីកអណ្តូងទឹកស្អាត |

ផែនទី 11៖ ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ



# ជំពូក ៣៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគតឆ្នាំ២០១៧-២០៣២

## ៣.១. តម្រូវការ ស្ថានភាព និងសក្តានុពលដីជាក់ស្តែង

### ៣.១.១. តម្រូវការដីទៅតាមប្រភេទ

នៅពេលអនាគតរហូតដល់ឆ្នាំ២០៣២ នៅក្នុងឃុំចំណាក្រោម នឹងមានការកើនឡើងចំនួនប្រជាពលរដ្ឋដល់ ១៩ ២០៩នាក់ ដែលត្រូវនឹងចំនួន ៣ ៩០៣គ្រួសារ ។ ដោយសារសន្ទុះនៃកំណើនប្រជាពលរដ្ឋនេះហើយ ដែលតម្រូវឱ្យមានការគិតគូរយកចិត្តទុកដាក់ដល់ការរកដីបន្ថែម សម្រាប់លំនៅឋានភូមិជូនទោដល់ប្រជាពលរដ្ឋដែលមានចំនួនកើនឡើង ដើម្បីធានាឱ្យមាននិរន្តរភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំចំណាក្រោម ទៅថ្ងៃអនាគតបន្តពីពេលបច្ចុប្បន្ន ដូចបានរកឃើញនៅក្នុងជំពូកទី២ ខាងលើនៃរបាយការណ៍នេះ ។ ដូច្នេះជាការឆ្លើយតបតាមការរកឃើញខាងលើ ចំពោះដីលំនៅឋាន ភូមិ ត្រូវបានកំណត់យកដីស្រែវស្សាតំបន់១ជុំវិញបឹងទន្លេសាប សម្រាប់ដោះស្រាយពង្រីកផ្ទៃដីលំនៅឋានបន្ថែម ។ តែដោយសារទំហំផ្ទៃដី ដែលត្រូវបានប្រើប្រាស់បច្ចុប្បន្នក្នុងឃុំ មានការប្រែប្រួលកើនឡើងស្របគ្នា ទៅនឹងកំណើនប្រជាពលរដ្ឋនាពេលអនាគត ដើម្បីដោះស្រាយបានទៅតាមតម្រូវការដីសម្រាប់ដីលំនៅឋាន និងដីអាងសហគមន៍បន្ថែមនោះ គឺជាដំណោះស្រាយសមស្របដីសម្រាប់លំនៅឋានត្រូវប្រើប្រាស់ដីភូមិលំនៅឋានដែលមានស្រាប់និងបន្ថែមដីពីស្រែវស្សាតំបន់១ជុំវិញបឹងទន្លេសាបសម្រាប់សាងសង់លំនៅឋានបន្ថែមទៀតសម្រាប់រយៈពេល១៥ឆ្នាំទៅមុខ ហើយម្យ៉ាងទៀតការតាំងលំនៅឋានមានលក្ខណៈប្រមូលផ្តុំវានឹងផ្តល់ភាពងាយស្រួលដល់ការផ្គត់ផ្គង់ទឹកស្អាត ភ្លើង និងសេវាសង្គមផ្សេងៗទៀតដូចជាសេវាអប់រំ សេវាសុខភាពជាដើម។ល។

ចំពោះដីស្រែ មិនត្រឹមតែមិនបានពង្រីកបន្ថែមតាមការគិតគូរខាងលើនោះទេ តែត្រូវទទួលរងការបាត់បង់ខ្លះថែមទៀត ប្រសិនបើដីស្រែប្រាំងនៅតំបន់៣ជុំវិញបឹងទន្លេសាប ដែលជាដីការពារជុំវិញបឹងទន្លេសាបមិនត្រូវបានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋកាន់កាប់អាស្រ័យផលនោះឡើយ ករណីមានប្រជាពលរដ្ឋបានកំពុងតែធ្វើស្រែ និងអាស្រ័យផលពិតប្រាកដមែន ត្រូវស្នើសុំការដោះស្រាយក្នុងការផ្តល់ដីនៅក្នុងតំបន់នេះពីរាជរដ្ឋាភិបាល ដោយឈរលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល ហើយប្រសិនបើមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យឃ្មៀលដីនេះជូនមែនក៏ដីនេះមិនមែនជាកម្មសិទ្ធិរបស់ប្រជាជនដែរ ប្រជាជនគ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលតែប៉ុណ្ណោះ ដោយអាចមិនមានសិទ្ធិចាត់ចែងនោះឡើយ ។ ជាដំណោះស្រាយគឺ ត្រូវតែគិតគូរពិចារណាដោយយកចិត្តទុកដាក់ តាមរយៈការបង្កើនផលិតភាព គុណភាព និងពិពិធកម្មកសិកម្មដំណាំស្រូវ ដោយត្រូវធ្វើស្រែបង្កើនរដូវឱ្យបានពី២ទៅ៣ដងក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ។

### ៣.១.២. ស្ថានភាពនៃដីធ្លី និងសក្តានុពល

ពេលអនាគត ធនធានដីនៅក្នុងឃុំចំណាក្រោម នៅតែរក្សាទំហំក្រឡាផ្ទៃសរុប ២៣ ៦២៨ហិកតាដដែល ហើយមានការប្រើប្រាស់សម្រាប់លំនៅឋាន (រួមទាំងហេដ្ឋារចនាសម្ព័ន្ធមួយចំនួន និងដំណាំជុំវិញលំនៅឋាន) ដីស្រែ(រួមទាំងប្រព័ន្ធធារាសាស្ត្រនឹងហេដ្ឋារចនាសម្ព័ន្ធ) ដីទួលបុរាណដ្ឋាន ដីដាំព្រៃឈើបម្រុងទុកអភិវឌ្ឍន៍ក្នុងឃុំ ដីបឹង ដីអាងស្តុកទឹក និងដីស្រះ ដូចកាប្រើប្រាស់ដីបច្ចុប្បន្ន ដដែលដោយគ្រាន់តែមានការប្រែប្រួលតិចតួចពីដីស្រែប្រាំងនៅក្នុងតំបន់៣ ដែលជាដីការពារជុំវិញបឹងទន្លេសាប ទៅជាដីព្រៃលិចទឹកវិញ ប្រសិនបើមិនត្រូវបាន

អនុញ្ញាតពីរាជរដ្ឋាភិបាល ឲ្យទៅប្រជាពលរដ្ឋកាន់កាប់អាស្រ័យផល ដោយមានការស្នើសុំពីអាជ្ញាធរដែនដីទេនោះ ចំណែកព្រៃល្បោះ និងព្រៃគុម្ពោតនឹងទៅជាដីដាំកូនឈើក្នុងឃុំ និងដីទួលចំនួន៩កន្លែងទៀតនឹងក្លាយទៅជាទីទួលបុរាណដ្ឋាន ចំណែកដីទួលក្រៅពីនេះនឹងទៅជាដីស្រែ ហើយទំហំផ្ទៃដីតំបន់ប្រើប្រាស់នីមួយ ៗ ដូចមានរៀបរាប់ក្នុងសេចក្តីអត្ថាធិប្បាយអំពីការបែងចែកដីតាមតម្រូវការប្រើប្រាស់ខាងក្រោមនេះ ។ ជាទូទៅធនធានដី នៅក្នុងឃុំចំណាក្រោម មានសក្តានុពលខ្ពស់ សមស្របទៅលើកសិកម្មដំណាំស្រូវ ដោយសារដីក្នុងឃុំមានទីតាំងភូមិសាស្ត្រអំណោយផលពីធម្មជាតិដូចបានរៀបរាប់ក្នុងជំពូកទី២ខាងលើ ។ ដូច្នេះ ការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និងការសម្រេចចិត្តប្រើប្រាស់ដីទៅថ្ងៃអនាគតនៅក្នុងឃុំចំណាក្រោម ដែលបានផ្តោតសំខាន់ទៅលើកសិកម្មដំណាំស្រូវជាចម្បង គឺជាការប្រើប្រាស់បានត្រឹមត្រូវចំនូវសក្តានុពលនៃដីហើយក៏ជាការគាប់ជួន ដែលភាពអំណោយផលពីធនធានដីនៅក្នុងឃុំសមស្របទៅលើវិស័យកសិកម្មដំណាំស្រូវនេះ ក៏ស្របទៅនឹងគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងតួនាទីវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទដែលមានចែងក្នុងមុំទី១ ចតុកោណទី៤នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤មានការរបស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភាដែលជាការផ្តល់ឱកាសដ៏ល្អដល់អាចអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់ខ្លួនឱ្យឃុំរីកចម្រើនបានតាមរយៈការជំរុញធ្វើពិពិធកម្មកសិកម្មដំណាំស្រូវនៅលើផ្ទៃដីកសិកម្មដ៏ធំល្វឹងល្វើយស្ទើរតែពេញដែនដីឃុំទាំងមូលដើម្បីបង្កើនទិន្នផលស្រូវ ដែលជាដំណាំដ៏មានសារៈសំខាន់សម្រាប់ជាស្បៀងផ្គត់ផ្គង់ការហូបចុក មិនអាចខ្វះបាននិងការនាំចេញទៅលក់នៅទីផ្សារ ដើម្បីបានចំណូលផ្គត់ផ្គង់តម្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង រួមទាំងចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិតាមរយៈសកម្មភាព ធ្វើពាណិជ្ជកម្មនាំអង្ករចេញរបស់រាជរដ្ឋាភិបាល ។

ចំណែកដី ដែលមានទំហំតិចតួច ដែលបានកំណត់ ជាដីសម្រាប់ការសាងសង់លំនៅឋាន នៅលើដីខ្ពស់ជាប់តាមដងផ្លូវសំខាន់ៗ ដែលមិនលិចទឹកនៅរដូវវស្សា បានផ្តល់ភាពងាយស្រួលនៅក្នុងការធ្វើដំណើរចេញចូល និងងាយស្រួលក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត សម្រាប់បម្រើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុងឃុំបានប្រកបដោយជាសុកភាព ព្រមទាំងដី ដែលប្រើប្រាស់សម្រាប់ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាការប្រើប្រាស់បានត្រឹមត្រូវផងដែរ ។

ស្ថានភាពដី ដែលត្រូវប្រើប្រាស់ទាំងនោះមានដីលំនៅឋាន និងដីកសិកម្មដំណាំស្រូវ ជាកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ចំណែកដីព្រៃលិចទឹករបស់សហគមន៍ គឺជាដីកម្មសិទ្ធិឯកជនរបស់រដ្ឋ(កម្មសិទ្ធិរបស់ឃុំចំណាក្រោម) ចំណែកដីអាងចំនួន១០ ដីបឹង ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ គឺជាដីកម្មសិទ្ធិរបស់រដ្ឋ ដែលយើងទាំងអស់គ្នា ត្រូវធ្វើការពារថែទាំឱ្យបានគង់វង្ស សម្រាប់បម្រើឱ្យជាផលប្រយោជន៍សាធារណៈដោយមិនត្រូវឱ្យមានការរំលោភកាន់កាប់ប្រើប្រាស់បម្រើផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួនបានឡើយ ។

## ៣.២. ការបែងចែកដីទៅតាមតម្រូវការប្រើប្រាស់

### ៣.២.១. ការវិភាគអន្តរអំពើរវាងតំបន់ផ្សេងៗ

ជាទូទៅ ការកំណត់តំបន់ប្រើប្រាស់ដីបានផ្តោតសំខាន់លើមុខងារការប្រើប្រាស់ដី សម្រាប់គោលបំណងផ្សេងៗដូចជា ផ្លូវ កសិកម្ម លំនៅឋាន ពាណិជ្ជកម្ម សួនកំសាន្ត ព្រៃឈើ និងព្រៃលិចទឹក។ល។ ទន្ទឹមនឹងនោះ ការប្រើប្រាស់ដីតែងតែមានការផ្លាស់ប្តូរមុខងាររបស់វាតែការផ្លាស់ប្តូរមុខងារប្រើប្រាស់ដីនេះត្រូវតែគិតគូពិចារណាឱ្យបានហ្មត់ចត់ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវយោលតាមស្ថានភាពច្បាប់ សេដ្ឋកិច្ច សង្គម និង បរិស្ថាន

ហើយត្រូវតែប្រាកដថា ដីដែលបានប្តូរមុខងារប្រើប្រាស់ហើយនោះ ត្រូវតែមានតម្លៃសេដ្ឋកិច្ច ឬ ផលប្រយោជន៍ខ្ពស់ជាងមុខងារប្រើប្រាស់មុន តាមរយៈការរក្សាជំហរច្បាស់លាស់ក្នុងការបង្កើនធនធានប្រើប្រាស់ ប្រកបដោយប្រសិទ្ធិភាព ជាមួយនឹងផលប៉ះពាល់ដ៏តិចតួចបំផុតចំពោះមនុស្សជំនាន់ក្រោយ ។ ឧទាហរណ៍ដូចជាការផ្លាស់ប្តូរពីដីព្រៃឈើរេចរិលទៅជាដីសម្រាប់កសិកម្ម វានឹងនាំឱ្យមានការបាត់បង់បរិមាណដីព្រៃឈើដែលផ្តល់ប្រយោជន៍ច្រើនយ៉ាងដល់សហគមន៍មូលដ្ឋាន តែត្រូវបានកើតឡើងជំនួសដោយវាលស្រែ សម្រាប់ផលិតកម្មស្រូវ ដែលជាចំណីអាហារមិនអាចខ្វះបាន ដែលទាំងនេះជាការបង្ហាញឱ្យឃើញពីអន្តរអំពើរវាងមុខងារប្រើប្រាស់ដីមួយ ជាមួយមុខងារប្រើប្រាស់ដីមួយផ្សេងទៀតនៅលើទីតាំងដីដដែល ។

យ៉ាងណាមិញ នៅក្នុងរយៈពេល១៥ឆ្នាំខាងមុខ រហូតទៅដល់ឆ្នាំ២០៣២ សម្រាប់ការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម គឺត្រូវបានធ្វើការគិតគូរយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋដូចដែលបានរៀបរាប់ខាងលើ ជាពិសេសនោះ គឺការដោះស្រាយការបែងចែកការប្រើប្រាស់ដីធ្លីដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ តាមគោលការណ៍របស់រាជរដ្ឋាភិបាល និងដោយឈរលើស្មារតីនៅក្នុងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានសម្រាប់ការប្រើប្រាស់ដីធ្លីក្នុងឃុំ ។បញ្ហាដែលត្រូវដោះស្រាយខាងលើនេះ យើងសង្កេតឃើញនៅក្នុងឃុំមានការដោះស្រាយដីមួយចំនួនដូចខាងក្រោម៖

**-ពង្រីកដីលំនៅឋាន៖** ការពង្រីកដីលំនៅឋាន សម្រាប់ប្រើប្រាស់បំពេញបន្ថែមការខ្វះខាតឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋពេលអនាគត ត្រូវបានកំណត់យកដីស្រែវស្សាទំហំផ្ទៃដី ១២,២១ហិកតា ដែលនឹងមានការប្រែប្រួលថយចុះផ្ទៃដីស្រែដែលជាមូលដ្ឋាននៃការអភិវឌ្ឍន៍នៅក្នុងឃុំចំណាក្រោម វានឹងនាំឲ្យមានការថយចុះផលិតផលស្រូវ តិចតួច ដែលនឹងនាំឲ្យបាត់បង់ប្រាក់ចំណូលតិចតួចរបស់ប្រជាពលរដ្ឋ តែបរិមាណផ្ទៃដីសម្រាប់លំនៅឋាន មានការកើនឡើង ដែលជាតម្រូវការចាំបាច់សម្រាប់ដោះស្រាយការស្នាក់នៅរបស់ប្រជាពលរដ្ឋ ដែលជាអាទិភាពមិនអាចខ្វះបាន ។

តារាង 36៖ តារាងប្រើប្រាស់ដីនាពេលអនាគតឃុំចំណាក្រោម

| ប្រភេទការប្រើប្រាស់ដី | ផ្ទៃដីបច្ចុប្បន្ន (ហិកតា) | ផ្ទៃដី១៥ក្រោយ (ហិកតា) | បម្រែបម្រួល (ហិកតា) |
|---|---|---|---|
| **ក.ដីលំនៅឋាន ភូមិ** | **៣១១,២៧** | **៣២៣,៤៨** | **១២,២១** |
| -ដីលំនៅដ្ឋាន ភូមិ ក្រៅតំបន់ជុំវិញបឹងទន្លេសាប | ៥៤,៩៧ | ៥៤,៩៧ | 0 |
| -ដីលំនៅដ្ឋាន ភូមិ ក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ២៥៦,៣ | ២៦៨,៥ | ១២,២១ |
| **ខ.ដីស្រែវស្សា** | **៥ ០៩៦,៩៦** | **៥ ០៨៤,៧៥** | **-១២,២១** |
| -ដីស្រែវស្សាក្រៅតំបន់ជុំវិញបឹងទន្លេសាប | ១ ០៩៤,៧៧ | ១ ០៩៤,៧៧ | 0 |
| -ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ៣ ៩០២,៣២ | ៣ ៨៩០,១១ | -១២,២១ |
| -ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៩៩,៨៧ | ៩៩,៨៧ | 0 |
| **គ.ដីស្រែប្រាំង** | **៨ ២៦៧,៣** | **៨ ២៦៧,៣** | **0** |
| -ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប | ៦៦១,១ | ៦៦១,១ | 0 |
| -ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប | ៤ ៨៩៣,៨៨ | ៤ ៨៩៣,៨៨ | 0 |
| -ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប | ២ ៧១២,២៩ | ២ ៧១២,២៩ | 0 |

| | | | |
|---|---|---|---|
| ឃ.ដីស្រែប្រាំង និងស្រែវស្សាតំបន់៣ជុំវិញបឹងទន្លេសាប | ១ ៥៨៨,២២ | ១ ៥៨៨,២២ | 0 |
| ង.ព្រៃគុម្ពោត | ៣៥,២៧ | ៣៥,២៧ | 0 |
| ច.ព្រៃល្បោះ | ២៨,៣៨ | ២៨,៣៨ | 0 |
| ឆ.ព្រៃលិចទឹក | ៤ ៤៦៥,១៥ | ៤ ៤៦៥,១៥ | 0 |
| ជ.ស្រះ | ៣២,៨៦ | ៣២,៨៦ | 0 |
| ឈ.បឹង | ២៧១,២១ | ២៧១,២១ | 0 |
| ញ.អាងស្តុកទឹក | ៣ ៥៣១,៤៥ | ៣ ៥៣១,៤៥ | 0 |
| ផ្ទៃដីឃុំសរុប | ២៣ ៦២៨ | ២៣ ៦២៨ | 0 |

តារាង 37៖ តារាងផែនការផ្នែកហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំ២០១៧ (ម៉ែត្រ) | ប្រវែងផ្លូវឆ្នាំ២០៣២ (ម៉ែត្រ) | បម្រែបម្រួល(ម៉ែត្រ) |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | ១៧ ៦០៨,១១ | ៤៤ ៤១៥,៧៩ | ៣៩ ៩០៣,៤៩ |
| ផ្លូវក្រាលគ្រួសក្រហម | ១០ ៨៩៩,៧៧ | ៧០ ៤៩៣,៧៣ | ២៣ ៤៨៧,៣៦ |
| ផ្លូវលំដីស/ផ្លូវរទេះ | ១៦២ ២៨៥,៤ | ៦២ ៨៦៥,១៥ | ៦៣ ៣៩០,៨៥ |
| ប្រឡាយមេ | ៦ ២២១,៣៧ | ៨ ៩១៨,១៤ | ២ ៦៩៦,៧៧ |
| ប្រឡាយរង | ១៦ ៥៤៩,៨៦ | ២៥ ២០៩,០៩ | ៨ ៦៥៩,២៣ |
| ប្រឡាយតូច | ៤៤ ៩៩៨,៦០ | ៤៤ ៩៩៨,៦០ | ០០ |

តារាង 38៖ តារាងផែនការផ្នែកសេវាកម្មនាពេលអនាគត

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំ២០១៧ | ចំនួនសម្រាប់១៥ឆ្នាំក្រោយ | បម្រែបម្រួល |
|---|---|---|---|
| សាលាមតេយ្យ | ៦អគារ/៦បន្ទប់ | ១៧អគារ/៨៥បន្ទប់ | ១១អគារ/៧៩បន្ទប់ |
| សាលាបឋមសិក្សា | ១អគារ/៦៣បន្ទប់ | ៩អគារ/៥៧បន្ទប់ | -១អគារ/-៦បន្ទប់ |
| សាលាអនុវិទ្យាល័យ | ៤អគារ/១០បន្ទប់ | ៣អគារ/៣១បន្ទប់ | ២អគារ/២១បន្ទប់ |
| សាលាវិទ្យាល័យ | ០០អគារ/០០បន្ទប់ | ៣អគារ/៣១បន្ទប់ | ៣អគារ/៣១បន្ទប់ |
| មណ្ឌលសុខភាព | ០១កន្លែង | ០១កន្លែង | ០កន្លែង |
| ទីតាំងផ្សារ | ០១កន្លែង | ០១កន្លែង | ០កន្លែង |

### ៣.២.២. ផែនទីប្រើប្រាស់ដីអនាគត

ការកំណត់ការប្រើប្រាស់ដី នាពេលអនាគតនៅក្នុងឃុំចំណាក្រោម គឺជាការសម្រេចចិត្តមួយដ៏ត្រឹមត្រូវបំផុត ដោយធ្វើការពឹងផ្អែកទាំងស្រុងទៅលើការវិភាគដីដ៏សមស្របមួយ តាមរយៈការវាយតម្លៃតាមបែបសាមញ្ញទៅលើធនធានដី រយៈកម្ពស់ ទីជម្រាល ធនធានទឹក ការកាន់កាប់ដី និងសក្តានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនាពេលបច្ចុប្បន្ន ដោយយកផែនទីប្រើប្រាស់ដីធ្លីបច្ចុប្បន្ន ធ្វើជាមូលដ្ឋាន សម្រាប់នៅក្នុងការគិតគូរពិចារណាដូចមានរំលេចឱ្យឃើញនៅក្នុងតារាងប្រើប្រាស់ដីពេលអនាគតខាងលើនេះ ព្រមទាំងនៅក្នុងផែនទីប្រើប្រាស់ដី

នាពេលអនាគតដូចខាងក្រោមនេះ ដែលសមស្របអាចទទួលយកបាន និងអាចប្រើប្រាស់មានប្រសិទ្ធិភាពតាមរយៈការបង្ហាញយ៉ាងពិស្តារពីជម្រើសដ៏ល្អសម្រាប់ការប្រើប្រាស់ដីនាពេលអនាគតរបស់ឃុំនេះ។ ទន្ទឹមនឹងនោះផែនទីប្រើប្រាស់ដីនាពេលអនាគតខាងក្រោម ក៏មានការអត្ថាធិប្បាយលម្អិតទៅលើតំបន់ប្រើប្រាស់ដីនីមួយៗ ដែលបានកំណត់នៅលើផែនទីនេះផងដែរ ។

ផែនទី 12៖ ផែនទីប្រើប្រាស់ដីអនាគតក្នុងឃុំចំណាក្រោម



### ៣.២.៣. សេចក្តីអត្ថាធិប្បាយអំពីការប្រើប្រាស់ដីនាពេលអនាគត

ផ្អែកតាមផែនទីប្រើប្រាស់ដីអនាគតឃុំចំណាក្រោមខាងលើ បានបង្ហាញឲ្យឃើញថាការប្រើប្រាស់ដីនៅក្នុងឃុំដូចខាងក្រោម៖

#### ក. ដីលំនៅឋាន ភូមិ

ដីលំនៅឋាន ភូមិ ជាដីត្រូវបានប្រើប្រាស់សម្រាប់លំនៅឋានមានលាយសួនដំណាំ និងឈើហូបផ្លែ ។ នៅក្នុងឃុំចំណាក្រោម មានដីលំនៅឋាន ភូមិ ស្ថិតនៅក្រៅដីតំបន់ជុំវិញបឹងទន្លេសាប និងក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីលំនៅឋាន ជាដីដែលបានកាន់កាប់ដោយប្រជាពលរដ្ឋ (ដីកម្មសិទ្ធិឯកជន) មានទំហំផ្ទៃដីចំនួន ៣១១,២៧ ហិកតា មិនទាន់បានចុះបញ្ជីកាន់កាប់ជាប្រព័ន្ធនៅឡើយទេ ដែលបច្ចុប្បន្ននេះ ត្រូវបានប្រើប្រាស់សម្រាប់ដីលំនៅឋាន ភូមិ ដោយពុំមានការពង្រីកបន្ថែម សម្រាប់ដោះស្រាយនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ ២០៣២នោះឡើយ ដោយបច្ចុប្បន្ននេះ ដីលំនៅឋានភូមិនៅមានភាពទូលាយអាចដោះស្រាយសម្រាប់សាងសង់លំនៅឋានរហូតដល់ឆ្នាំ ២០៣២បាន ។ ដីលំនៅឋានភូមិជាវាលទំនាបមធ្យម ហើយដីជាប្រភេទដីល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌ខ្មៅ និងមានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅរដូវវស្សា ។ តំបន់នេះ ពឹងផ្អែកលើប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពដំណាំរួមផ្សំជុំវិញលំនៅឋានបានមកពីស្ទឹងស្ទោង ប្រឡាយ អណ្តូងស្នប់ និងស្រះ ហើយត្រូវនាំទឹកមកប្រើប្រាស់ដោយម៉ូទ័របូម និងស្នប់សប់ដោយដៃ ។ នាពេលអនាគត ទីតាំងដីលំនៅឋានភូមិដែលមានស្រាប់នាពេលបច្ចុប្បន្ននេះ នឹងត្រូវរក្សាទុកជាដីសម្រាប់សាងសង់លំនៅឋានដដែល ដោយសារតែទីតាំងដីនេះ មានស្ថានភាពជាដីខ្ពស់មិនលិចទឹកនៅរដូវវស្សា និងនៅជាប់ផ្លូវសំខាន់ៗនៅក្នុងឃុំ ធ្វើឲ្យងាយស្រួលក្នុងការចេញចូលប្រកបរបររកស៊ីរបស់ប្រជាពលរដ្ឋ ដែលសមស្របសម្រាប់ការតាំងលំនៅឋាន និងជាជម្រកដ៏កក់ក្តៅ សម្រាប់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ។ ទំហំដីលំនៅឋាន ជាមធ្យមសម្រាប់មួយគ្រួសារនាពេលអនាគត បើផ្អែកទៅតាមកំណើនប្រជាជនរហូតដល់ឆ្នាំ ២០៣២ដែលនឹងមានប្រជាជនកើនឡើងរហូតដល់ចំនួន ៣ ៩០៣គ្រួសារ និងដីលំនៅឋានមិនមានការប្រែប្រួលកើនឡើងដូចរៀបរាបខាងលើ គឺរក្សាទំហំ ៣១១,២៧ហិកតា ដូច្នេះទៅថ្ងៃអនាគត១៥ឆ្នាំទៅមុខ ការប្រើប្រាស់ដីលំនៅឋាន មានទំហំ ០,០៨ហិកតា ក្នុងមួយគ្រួសារ ដែលប្រហាក់ប្រហែលនិងដីប្រើប្រាស់ដីលំនៅឋាននាពេលបច្ចុប្បន្នដែរ គឺចំនួន ០,១១ហិកតាក្នុងមួយគ្រួសារ ។

-ទំហំដីលំនៅឋានជាមធ្យមសម្រាប់មួយគ្រួសារ១៥ឆ្នាំខាងមុខ =

**៣១១,២៧ហិកតា /៣ ៩០៣គ្រួសារ=០,០៨ហិកតា**

#### ខ. ដីស្រែវស្សា

ដីស្រែវស្សាក្នុងឃុំចំណាក្រោម នៅពេលអនាគត ភាគច្រើនលើសលប់ស្ថិតនៅប៉ែកខាងត្បូងផ្លូវជាតិលេខ ៦ និងមានតិចតួចនៅប៉ែកខាងជើងផ្លូវជាតិលេខ៦ និងមានផ្ទៃដីសរុបចំនួន ៥ ០៩៦,៩៦ ហិកតា ដែលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែវស្សា ដោយពុំមានការពង្រីកបន្ថែម សម្រាប់ការដោះស្រាយទៅនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២ នោះឡើយ ។ ដីស្រែវស្សានេះ មានសណ្ឋានភាពដីជាវាលទំនាបទាបមានប្រភេទដីជាដីកណ្តេងពណ៌ខ្មៅ និងប្រផេះ ដោយពឹងផ្អែកលើទឹកភ្លៀង ប្រឡាយ ស្ទឹងស្ទោង និងអាង ៣០កញ្ញាជាដើម ដែលនាំទឹកមកស្រោចស្រពតាមរយៈប្រព័ន្ធប្រឡាយ ដោយប្រើប្រាស់ម៉ាស៊ីនបូមទឹកបូមចេញពីប្រភពទឹកទាំងនោះ និងតាមរយៈទ្វារទឹកចូលទៅក្នុងប្រឡាយ ។ នាពេលអនាគតទីតាំងដីស្រែវស្សា ក្នុងតំបន់១ជុំវិញបឹងទន្លេសាប នឹង

ត្រូវបានកាត់បន្ថយទំហំផ្ទៃដីតិចតួចទំហំ ១២,២១ហិកតា សម្រាប់បង្កើតជាដីលំនៅឋាន ភូមិ ដែលជាតម្រូវការចាំបាច់ មិនអាចខ្វះបានសម្រាប់ការកើនឡើងនៃប្រជាពលរដ្ឋនៅក្នុងឃុំ ហើយក្រៅពីនោះដីស្រែវស្សាទំហំផ្ទៃដី ៥ ០៨៤,៧៥ ហិកតា នៅរក្សាទុកជាដីស្រែវស្សាដូចបច្ចុប្បន្នដដែល ដោយសារទីតាំងដីនេះ មានស្ថានភាពជាដីទាបលិចទឹកនៅ រដូវវស្សាសមស្រប សម្រាប់ដំណាំស្រូវផ្តល់ផលិតផលផ្គត់ផ្គង់ដល់ការបរិភោគសម្រាប់ជីវិតរស់របស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅស្រុកដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ ។ ដីស្រែវស្សា នៅពេលអនាគតមានទីតាំងស្ថិតនៅតាមបីតំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-ដីស្រែវស្សាក្រៅតំបន់ការពាជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្រៅតំបន់ការពាជុំវិញបឹងទន្លេសាប មានផ្ទៃដីចំនួន ១ ០៩៤,៧៧ ហិកតា ស្ថិតនៅខាងជើងផ្លូវជាតិលេខ៦ ។ ដីស្រែវស្សាក្រៅតំបន់ការពារជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៣ ៨៩០,១១ ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦។ ដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប ជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៩៩,៨៧ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ បន្តជាប់ពីដីស្រែវស្សាក្នុងតំបន់១ជុំវិញបឹងទន្លេសាប។ដីស្រែវស្សាក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ។

គ. ស្រែប្រាំង

ដីស្រែប្រាំងនៅឃុំចំណាក្រោម នៅពេលអនាគត ស្ថិតនៅភាគខាងត្បូងនៃឃុំ ដែលមានផ្ទៃដីសរុបចំនួន ៨ ២៦៧,៣ ហិកតា ដែលពេលបច្ចុប្បន្នត្រូវបានប្រើប្រាស់ជាដីស្រែប្រាំង ដោយពុំមានការពង្រីកបន្ថែមសម្រាប់ការដោះស្រាយនឹងកំណើនប្រជាជនរហូតដល់ឆ្នាំ២០៣២នោះឡើយ ។ ដីស្រែប្រាំងទាំងនេះ មានសណ្ឋានភាពជាដីទំនាបទាបលិចទឹករយៈពេលវែង មានប្រភេទដីកណ្តោងល្បាប់ពណ៌ខ្មៅ និងលើទឹកភ្លៀង បឹង ត្រពាំង ប្រឡាយ អាងស្តុកទឹក និងទន្លេសាបជាដើម ដែលនាំទឹកមកស្រោចស្រពតាមរយៈប្រព័ន្ធប្រឡាយ ដោយប្រើប្រាស់ម៉ាស៊ីនបូមទឹកបូមចេញពីប្រភពទឹកទាំងនោះចូលទៅក្នុងប្រឡាយ។នាពេលអនាគតទីតាំងដីនេះនឹងត្រូវរក្សាទុកជាដីស្រែប្រាំងដដែល ដោយសារតែទីតាំងដីនេះមានស្ថានភាពជាដីទាបលិចទឹកខ្លាំងនៅរដូវវស្សាមិនអាចធ្វើស្រែវស្សាបានសមស្របសម្រាប់ដំណាំស្រូវប្រាំងនៅពេលទឹកស្រកចុះវិញ សម្រាប់ផ្គត់ផ្គង់ការហូបចុកសម្រាប់ជីវិតរស់នៅរបស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅប្រទេសបានចំណូលបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ។ ដីស្រែប្រាំង នៅពេលអនាគតមានទីតាំងស្ថិតនៅតាមបីតំបន់ផ្សេងគ្នាដូចខាងក្រោម៖

**-ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៦៦១,១ហិកតា ស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៦ ដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប គឺជាដីកម្មសិទ្ធិឯកជន ត្រូវបានកាន់កាប់និងចាត់ចែងប្រើប្រាស់ដោយប្រជាពលរដ្ឋ។

**-ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ៤ ៨៩៣,៨៨ ហិកតា ស្ថិតនៅភាគខាងត្បូងនៃឃុំបន្តពីដីស្រែប្រាំងក្នុងតំបន់១ជុំវិញបឹងទន្លេសាប ។ ដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋអាចមានសិទ្ធិត្រឹមកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងលក់ដូរបានឡើយ។

**-ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបមានផ្ទៃដីចំនួន ២ ៧១២,២៩ ហិកតា ស្ថិតនៅភាគខាងត្បូងឃុំបន្តពីដីស្រែប្រាំងក្នុងតំបន់២ជុំវិញបឹងទន្លេសាប ។ ដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក នៅជុំវិញបឹងទន្លេសាប និងការសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទ ។ នាពេលអនាគត ក្នុងករណីដីស្រែប្រាំងក្នុងតំបន់៣ជុំវិញបឹងទន្លេសាបនេះ មិនមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ឱ្យផ្ទៀលចេញពីតំបន់ការពារព្រៃលិចទឹកតាមកាស្នើសុំរបស់អាជ្ញាធរដែនដីពាក់ព័ន្ធ ដោយផ្អែកលើឯកសារលិខិត បទដ្ឋានគតិយុត្តិ និងបទបញ្ជានានារបស់រាជរដ្ឋាភិបាលទេនោះ គឺដីស្រែប្រាំងទាំងនេះនឹងនៅតែកំណត់ការប្រើប្រាស់ជាដីព្រៃលិចទឹកជុំវិញបឹងទន្លេសាបដែលត្រូវការពារដដែល ។ តែទោះបីមានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យផ្ទៀលដីទាំងនេះ ជូនសម្រាប់ប្រើប្រាស់ជាដីស្រែក៏ដោយ ក៏ដីស្រែទាំងនេះមិនមែនជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋដែរ គឺពួកគាត់គ្រាន់តែអាចមានសិទ្ធិកាន់កាប់អាស្រ័យផលប៉ុណ្ណោះ ដោយមិនមានសិទ្ធិចាត់ចែងនោះឡើយ។

### យ. ដីស្រែប្រាំង និងស្រែវស្សា

ដីស្រែប្រាំងនិងស្រែវស្សា នៅក្នុងឃុំចំណាក្រោម នៅពេលអនាគត ស្ថិតនៅភាគខាងត្បូងនៃឃុំដែលស្ថិតក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មានផ្ទៃដីទំហំ ១ ៥៨៨,២២ ហិកតា មានជម្រាលទាបសម្រាប់ដំណាំស្រូវប្រាំង និងស្រូវវស្សាដែលលិចទឹករយៈពេលខ្លី មានប្រភេទដីកណ្ដោងពណ៌ខ្មៅប្រផេះ ដោយប្រើប្រាស់ទឹកភ្លៀង ទឹកទន្លេសាបបឹងនិងអាងស្តុកទឹក។ នាពេលអនាគតទីតាំងដីស្រែប្រាំង និងស្រែវស្សា នឹងត្រូវរក្សាទុកជាដីស្រែប្រាំង និងស្រែវស្សាដដែល ដោយសារទីតាំងនេះមានស្ថានភាពជាដីទាបលិចទឹកតាមរដូវ សមស្របសម្រាប់ដំណាំស្រូវផ្តល់ផលិតផលផ្គត់ផ្គង់ដល់ការបរិភោគសម្រាប់ជីវិតរស់នៅរបស់មនុស្ស និងនៅសល់លក់ទៅទីផ្សារក្នុងនិងក្រៅស្រុក ដើម្បីបង្កើនប្រាក់ចំណូលជាតិ និងគ្រួសារ ។

### ង. ព្រៃគុម្ពោត

ព្រៃគុម្ពោតនៅក្នុងឃុំចំណាក្រោម នៅពេលអនាគត មានទំហំផ្ទៃដីសរុបចំនួន ៣៥,២៧ ហិកតា ដែលជាព្រៃដុះរាយប៉ាយនៅក្នុងភូមិសាស្ត្រក្នុងឃុំ ស្ថិតនៅភាគកណ្ដាលឆៀងខាងលិច និងខាងកើតផង និងនៅភាគកណ្ដាលឆៀងខាងជើង ហើយដុះលាយជាមួយដីស្រែវស្សា និងមានខ្លះជាព្រៃទួលបុរាណ តែមិនមានទ្រុងទ្រាយធំនោះទេមានជាឈើត្បែង ត្រាច កកោះ ចំបក់ ធ្លកជាដើម ។ ក្នុងនោះមានដីទួលបុរាណចំនួន១០កន្លែង ដែលគ្រប់គ្រងដោយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងក្រៅពីនោះជាព្រៃតាមក្បាលស្រែ ជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ នាពេលអនាគតទីតាំងដីនេះ នឹងត្រូវប្រើប្រាស់ជាដីទួលបុរាណដ្ឋាន ដើម្បីការពារ និងថែរក្សាទុកសម្រាប់ការសិក្សាស្រាវជ្រាវជាប្រយោជន៍ដល់ជាតិ ដែលត្រូវហាមជីកកកាយ កប់សាកសព និងកាប់រានកាន់កាប់ប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន ។

ច. ព្រៃល្បោះ

ព្រៃល្បោះនៅក្នុងឃុំចំណាក្រោម នាពេលអនាគត ស្ថិតនៅភាគខាងត្បូងនៃឃុំនៅជាប់លាយឡំជាប់ក្នុងតំបន់ព្រៃលិចទឹកតំបន់៣ជុំវិញបឹងទន្លេសាប ដែលមានផ្ទៃដីទំហំ ២៨,៣៨ហិកតា មានប្រភេទឈើត្បែង ត្រាចកកោះ ដង្កៀបក្តាម ល្បៀង ចំបក់ ត្រសេក ផ្តៀក ធ្លក រកា រាំង កណ្តោល ច្រេស និងស្វាយព្រៃ។ នាពេលថ្ងៃអនាគត ព្រៃល្បោះនេះ នឹងត្រូវរៀបចំជាតំបន់នោះជាព្រៃការពារសម្រាប់សហគមន៍ ដើម្បីចូលរួមថែរក្សាការពារព្រៃឈើសម្រាប់កូនចៅយើងជំនាន់ក្រោយឲ្យបានស្គាល់ប្រភេទឈើ និងជាជម្រកសត្វគ្រប់ប្រភេទនិងជាពិសេសការលើកស្ទួយវិស័យបរិស្ថានក្នុងឃុំឲ្យមានភាពស្រស់បំព្រងបៃតង។

ឆ. ព្រៃលិចទឹក

ព្រៃលិចទឹកនៅក្នុងឃុំចំណាក្រោម នៅពេលអនាគត ស្ថិតនៅខាងភាគត្បូងនៃឃុំ ដែលមានវិសាលភាពធំធេងក្នុងភូមិសាស្ត្រឃុំទាំងមូល មានផ្ទៃដីទំហំ ៤ ៤៦៥,១៥ហិកតា ។ ដីព្រៃលិចទឹកក្នុងតំបន់៣នេះ សំបូរទៅដោយដើមឈើចម្រុះដុះលាយឡំគ្នា ដូចជា ៖ ដើមក្ទំភ្នែង ត្រស់ កប្បាសព្រៃ ស្នាច់ ដើមរាំងជាដើម គឺជាដីសាធារណៈរបស់រដ្ឋដែលគ្រប់គ្រង ដោយខណ្ឌរដ្ឋបាលជលផល ខេត្តកំពង់ធំ ។ ព្រៃលិចទឹកនេះកំពង់ត្រូវបានរងនូវការកាប់រានយកដីសម្រាប់ធ្វើស្រែប្រាំងពីប្រជាពលរដ្ឋក្នុងភូមិនិងខាងក្រៅភូមិ ។ នាពេលអនាគត ព្រៃលិចទឹក នឹងត្រូវរៀបចំជាសហគមន៍នេសាទ តាមរយៈក្រុមប្រឹក្សាឃុំ និងជំនាញជលផល ដើម្បីធ្វើការការពារព្រៃលិចទឹក និងការពារជីវចម្រុះគ្រប់ប្រភេទ ជាពិសេសនោះសម្រាប់ផ្តល់ជាជម្រកសត្វ និងជួយបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋក្នុងគ្រួសារ ។

ជ. ស្រះទឹក

ស្រះទឹកនៅក្នុងឃុំចំណាក្រោម មានស្រះទឹកចំនួន៥៦ ទំហំ ៣២,៨៦ហិកតា ដែលអាចប្រើប្រាស់ទឹកសម្រាប់ការស្រោចស្រព និងសត្វពាហនៈក្នុងឃុំបាន ។ ស្រះទាំងនេះមាននៅតាមតំបន់មួយចំនួនក្នុងភូមិសាស្ត្រស្រែប្រាំងនិងស្រែវស្សា និងស្ថិតនៅលាយឡំជាមួយតំបន់លំនៅឋាន ស្រះទឹកដូចបានបង្ហាញនេះ ភាគច្រើនជាការជីកជាលក្ខណៈឯកជន សម្រាប់ការប្រើប្រាស់ប្រចាំគ្រួសាររបស់ពួកគាត់។ នាពេលអនាគតស្រះទឹកទាំងនេះនឹងនៅតែប្រើប្រាស់ជាស្រះទឹកទុកជាជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ច្រើនយ៉ាងក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីនដែលជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។

**-ស្រះក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

ឃុំចំណាក្រោម មានស្រះចំនួន ៥១កន្លែងទៀត មានផ្ទៃដីទំហំ ២៥,៣៤ ហិកតា ដែលស្ថិតនៅភាគខាងត្បូងផ្លូវជាតិលេខ៦ ជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ។ នាពេលអនាគតស្រះទឹកទាំងអស់នេះ នឹងនៅតែជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល និងព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីនជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

**-ស្រះក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

ឃុំចំណាក្រោម មានស្រះចំនួន ៥កន្លែងទៀត មានផ្ទៃដីទំហំ ៣,៦៦ ហិកតា ដែលស្ថិតនៅចុងភាគខាងត្បូងនៃឃុំ ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ ការរំលោភកាន់កាប់ដីព្រៃលិចទឹក នៅជុំវិញបឹងទន្លេសាប និងសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទបន្ថែមទៀតទេ។ នាពេលអនាគតស្រះទឹកទាំងអស់នេះនឹងនៅតែជាប្រភពទឹកស្រោចស្រពនិងប្រើប្រាស់ច្រើនយ៉ាងនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល និងព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្គល់ប្រូតេអ៊ីន ដែលជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

**ឈ. ដីបឹង**

នៅក្នុងឃុំចំណាក្រោម មានបឹងតូចនិងធំសរុបចំនួន៧៥បឹងមានផ្ទៃដីទំហំ ២៧១,២១ហិកតា ដែលមានច្រើនជាងគេនៅដីតំបន់ស្រែប្រាំង ក្នុងដីព្រៃលិចទឹកតំបន់២និងតំបន់៣ជុំវិញបឹងទន្លេសាប ក្នុងនោះក៏មានដីបឹងអភិរក្សសហគមន៍នេសាទមួយកន្លែង (ស្ពានគ្រុងអភិវឌ្ឍន៍)។ បឹងធម្មជាតិទាំងអស់នេះជាដីសាធារណៈរបស់រដ្ឋ ដែលអនាគត ត្រូវការពារនិងថែរក្សាទុកប្រើប្រាស់ សម្រាប់ជាប្រភពទឹកស្រោចស្រពដំណាំកសិកម្ម និងប្រើប្រាស់ច្រើនយ៉ាងក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធន ធានជលផលសម្រាប់ជាអាហារផ្គល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់ក្នុងជីវិតរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

**ញ. អាងស្តុកទឹក**

អាងស្តុកទឹកក្នុងឃុំចំណាក្រោម នៅពេលអនាគត ៤២កន្លែង ស្ថិតនៅភាគខាងត្បូងនៃឃុំ ដែលមានផ្ទៃដីសរុបចំនួន ៣ ៥៣១,៤៥ ហិកតា ដែលបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់ជាអាងស្តុកទឹក ដោយពុំមានការពង្រីកបន្ថែមសម្រាប់ដោះស្រាយទឹកស្រោចស្រពរហូតដល់ឆ្នាំ២០៣២នោះឡើយ។ពេលអនាគតអាងស្តុកទឹកទាំងនេះនឹងនៅតែជាប្រភពទឹកស្រោចស្រពនិងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្គល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ។ អាងស្តុកទឹកនៅពេលអនាគតមានទីតាំងស្ថិតនៅតាមបីតំបន់ផ្សេងគ្នាដូចខាងក្រោមៈ

**-អាងស្តុកទឹកក្នុងតំបន់១ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានចំនួន ៥កន្លែង មានផ្ទៃដីសរុប ២៤៤,៧៦ហិកតា។ អាងស្តុកទឹកនេះ គឺជាដីកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋ ហើយក្នុងពេលបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ ។ នាពេលអនាគតអាងស្តុកទឹកទាំងនេះ នឹងនៅតែជាប្រភពទឹកស្រោចស្រពសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែល ព្រមទាំងជាប្រភពធនធានជលផលសម្រាប់ជាអាហារផ្គល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ ហើយក៏ជាទីតាំងមានទេសភាពប្រណិតគួរឱ្យទាក់ទាញសម្រាប់ជាតំបន់ទេសចរណ៍ផងដែរ ។

**-អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់២ជុំវិញបឹងទន្លេសាបមានចំនួន ៣១កន្លែង មានផ្ទៃដីសរុប ២ ៧៤០,២៦ហិកតា។ អាងស្តុកទឹកនេះ គឺជាដីសាធារណៈរបស់រដ្ឋ ដែលប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែកាន់កាប់អាស្រ័យផលប៉ុណ្ណោះ

ដោយមិនមានសិទ្ធិក្នុងការចាត់ចែងឡើយ ហើយក្នុងពេលបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់សម្រាប់ការស្រោចស្រព និងប្រើប្រាស់ផ្សេងៗទៀតតាមការចាំបាច់របស់ប្រជាពលរដ្ឋ ព្រមទាំងជាប្រភពធនធានមច្ឆាជាតិទៀតផង ដែលអាចប្រើប្រាស់បានពេញមួយឆ្នាំ ។ នាពេលអនាគតអាងស្តុកទឹកទាំងនេះ នឹងនៅតែជាប្រភពទឹកស្រោចស្រពនិងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែលនិងព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់ នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ ហើយក៏ជាទីតាំងមានទេសភាពប្រណិតគួរឱ្យទាក់ទាញសម្រាប់ជាតំបន់ទេសចរណ៍ផងដែរ ។

**-អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប**

អាងស្តុកទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប មាន ០៦ កន្លែង មានផ្ទៃដីសរុបទំហំ ៥៤១,៥៩ហិកតា ។ អាងស្តុកទឹកនេះ ជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅក្នុងតំបន់ដែនព្រៃលិចទឹក ដែលហាមការកាប់រានដី ការដុតបំផ្លាញ រំលោភកាន់កាប់ដីព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប និងសាងសង់សំណង់ថ្មីៗគ្រប់ប្រភេទបន្ថែមទៀត។ នាពេលអនាគតអាងស្តុកទឹកទាំងនេះ នឹងនៅតែជាប្រភពទឹកស្រោចស្រព និងប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដដែលនិងព្រមទាំងជាប្រភពធនធានជលផល សម្រាប់ជាអាហារផ្តល់ប្រូតេអ៊ីន ជាប្រយោជន៍យ៉ាងសំខាន់នៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ហើយក៏ជាទីតាំងមានទេសភាពប្រណិត គួរឱ្យទាក់ទាញសម្រាប់ជាតំបន់ទេសចរណ៍ផងដែរ ។

## ៣.៣. ដំណោះស្រាយផ្សេងៗ ក្នុងករណីខ្វះខាតដីធ្លី

ជាការពិត នៅពេលបច្ចុប្បន្ននេះ យើងបានរកឃើញថានៅក្នុងឃុំចំណាក្រោមមានប្រជាពលរដ្ឋក្រីក្រខ្វះខាតដីលំនៅឋានចំនួន ៥៥គ្រួសារ និងដីធ្វើកសិកម្មជាលក្ខណៈគ្រួសារពិតប្រាកដមានចំនួន ១៤៤គ្រួសារ ដូចបានអធិប្បាយនៅក្នុងជំពូកទី១នៃរបាយការណ៍នេះ ដែលប្រជាពលរដ្ឋមួយចំនួនកំពុងរស់នៅលើដីចិញ្ចើមផ្លូវ ដីចំណីប្រឡាយ និងលើដីចំណីស្ទឹង ដែលពួកគាត់កំពុងតែស៊ីឈ្នួលធ្វើការឱ្យគេដើម្បីចិញ្ចឹមជីវិត និងរស់នៅជាអចិន្ត្រៃយ៍។ ដូច្នេះដើម្បីដោះស្រាយដីសម្រាប់សាងសង់លំនៅឋាន និងសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារដែលអាចផ្តល់ឱកាសឱ្យពួកគាត់ មានជម្រកសម្រាប់រស់នៅសមរម្យ និងបង្កើតឱកាសការងារ ដើម្បីទទួលបានប្រាក់ចំណូលជូនពួកគាត់បាន អាជ្ញាធរដែនដីនៅគ្រប់ជាន់ថ្នាក់ត្រូវខិតខំដោះស្រាយ តាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ចនៅថ្នាក់ក្រោមជាតិដែលត្រូវផ្តួចផ្តើមឡើងដោយក្រុមប្រឹក្សាឃុំចំណាក្រោម។ ដីធ្លីដែលត្រូវដោះស្រាយជូនពួកគាត់ដូចបានធ្វើការវិភាគដោះស្រាយនៅក្នុងជំពូក២ ត្រង់ចំណុច២.១.៣ខាងលើ ដីសម្រាប់លំនៅឋានមានទំហំ ១៣,៧៥ហិកតា និងដីសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ មានទំហំ ២៨៨ហិកតា ។

## ៣.៤. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

និរន្តរភាពនៃការប្រើប្រាស់ដី គឺជាការធានាឱ្យបាននូវគោលដៅ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ដីទាំងនោះ ហើយការធានាទាំងអស់នេះត្រូវតែកើតមានឡើងជាបន្តបន្ទាប់ជារៀងរហូតដោយពុំមានឈប់ឈរ ។ និរន្តរ-ភាព គឺជាចំណុចស្នូលសម្រាប់ការប្រើប្រាស់ដីនៅគ្រប់តំបន់គោលដៅទាំងអស់តាមរយៈការកំណត់កត្តាចាំបាច់នានា សម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធិភាព និងធានាឱ្យមាននិរន្តរភាព ។

### ៣.៤.១. កត្តាចាំបាច់សម្រាប់ធានានិរន្តរភាព

ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គម ព្រមការទាំងថែរក្សាការពារបរិស្ថាន និងធនធានធម្មជាតិប្រកបទៅដោយចេរភាព ។ ដោយធាធានបានការផ្គត់ផ្គង់សេចក្ដីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននិងបន្តដល់កូនចៅរបស់ពួកគាត់ទៅជំនាន់ក្រោយទៀត ត្រូវតែយកចិត្តទុកដាក់ដល់ការគ្រប់គ្រងទៅលើការប្រើប្រាស់សេវាកម្មលើវិស័យទាំងអស់នៅក្នុងឃុំ ដែលបានកំណត់រួចតាមរយៈការខិតខំប្រឹងប្រែងអនុវត្តឱ្យសម្រេចបានទៅលើកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

#### ក. ការគ្រប់គ្រងប្រព័ន្ធកសិកម្ម

បើពិនិត្យទៅលើលក្ខណៈភូមិសាស្ត្រ និងសក្ដានុពលនៃធនធានដែលមាននៅក្នុងឃុំ ដែលក្រុមការងារបានធ្វើការសិក្សាស្រាវជ្រាវរកឃើញ បានកំណត់ច្បាស់ថា ឃុំនេះមានគោលដៅអភិវឌ្ឍន៍ទៅថ្ងៃអនាគតពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង ដែលក្នុងនោះបានផ្ដោតសំខាន់ទៅលើដំណាំស្រូវ ។ ដូចនេះឃុំចំណាក្រោមនឹងមានតួនាទីសំខាន់មួយនៅក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករបស់រាជរដ្ឋាភិបាល ដែលចាំបាច់ទាមទារឱ្យមានការគ្រប់គ្រងប្រព័ន្ធកសិកម្មក្នុងឃុំឱ្យបានរឹងមាំ និងមាននិរន្តរភាពទៅថ្ងៃអនាគត ដោយត្រូវយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវ ដើម្បីបង្កើនទិន្នផលឱ្យបានខ្ពស់អស់សក្ដានុពលអាចមានលទ្ធភាពនាំស្រូវចេញបានច្រើនសល់ពីការហូបចុកឆ្លើយតបទៅនឹងកំណើនប្រជាពលរដ្ឋ ។

ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ឃុំដូចខាងលើត្រូវមានការគ្រប់គ្រងដីស្រែក្នុងឃុំឱ្យបានគត់មត់ដោយរាល់ការសម្រេចចិត្តប្ដូរមុខងារប្រើប្រាស់ដី ពីកសិកម្មទៅបម្រើឱ្យការសាងសង់ និងបម្រើឱ្យការប្រើប្រាស់ផ្សេងទៀត ត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រកបទៅដោយតម្លាភាព ដោយអនុលោមទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងត្រូវមានការផ្សព្វផ្សាយជាចំហ ។ ម្យ៉ាងទៀតដីស្រែប្រាំង និងដីស្រែប្រាំងនិងស្រែវស្សានៅក្នុងឃុំបច្ចុប្បន្ន បានរកឃើញថាមានផ្ទៃដីទំហំ ៤ ៣០០,៥១ ហិកតា ស្ថិតនៅក្នុងតំបន់៣ដែលជាដែនការពារព្រៃលិចទឹក ប្រសិនបើមិនមានការអនុញ្ញាតពីរដ្ឋាភិបាល ឱ្យប្រជាពលរដ្ឋបន្តកាន់កាប់អាស្រ័យផលនៅពេលអនាគតតាមរយៈការស្នើរសុំពីអាជ្ញធរដែនដីទេនោះ នឹងត្រូវរក្សាទុកជាដីព្រៃលិចទឹកវិញនឹងនាំឱ្យទំហំផ្ទៃដីស្រែប្រាំងមានការថយចុះ។ ទន្ទឹមនឹងការគ្រប់គ្រងដីស្រែ ត្រូវគិតគូរពីទឹកស្រោចស្រពដំណាំស្រូវដោយត្រូវធ្វើយ៉ាងណាអាចធ្វើស្រែបង្កើនរដូវ និងស្រែប្រាំងឱ្យបានបីដងនៅក្នុងមួយឆ្នាំ ដោយតាមរយៈការស្ដារប្រព័ន្ធប្រឡាយចាស់ៗ ដែលមានស្រាប់អាចនាំទឹកទៅស្រោចស្រពដីស្រែបានគ្រប់គ្រាន់ ព្រមទាំងត្រូវបានកំនត់យកប្រភពទឹកអាង៣០កញ្ញា ដែលស្ថិតក្នុងឃុំព្រះដំរី ក្នុងស្រុកស្ទោង និងស្ទឹងស្ទោង ហូរកាត់ភូមិសាស្ត្រឃុំ នៅភាគខាងកើត ដើម្បីអាចផ្ដល់ទឹកមកតាមប្រព័ន្ធប្រឡាយមេ និងប្រឡាយរងជាច្រើនទៀតមកផ្គត់ផ្គង់ទឹកសម្រាប់ធ្វើស្រែ ។ បន្ទាប់ពីកត្តាដី និងទឹកនៅមានកត្តាបច្ចេកទេសដាំដុះថែមទៀត ដោយត្រូវគិតគូរជំរុញការធ្វើស្រែបែបប្រពលវប្បកម្មទំនើបដូចមានលើកឡើងតាមការវិភាគក្នុងជំពូក២ត្រង់ចំណុចការផ្ដល់ឱកាសដោយបច្ចេកវិទ្យាទំនើប ដែលកត្តានេះនឹងលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារកសិកម្មបានច្រើនផងដែរ ពីព្រោះយុវជនតែងគិតថាការធ្វើស្រែនាំឱ្យមានការនឿយហត់ ប្រឡាក់ប្រឡូសដីភក់ មិនស្អាតបាត ដែលជាការយល់ខុស គឺតាមពិតការធ្វើស្រែ តាមបែបប្រពលវប្បកម្មទំនើប កសិករក៏អាចពាក់ក្រវ៉ាត់កប្រើប្រាស់កុំព្យូទ័រក្នុងបន្ទប់ម៉ាស៊ីនត្រជាក់បានដូចគ្នា។ ក្នុងការគ្រប់គ្រងប្រព័ន្ធកសិកម្មនៅឃុំចំណាក្រោម មិនមែនយកចិត្តទុកដាក់តែនៅលើការជំរុញផលិតកម្មកសិកម្មដូចខាងលើប៉ុណ្ណោះទេ តែត្រូវខិតខំពង្រឹងការប្រមូលគ្នាចងក្រងជាសហគមន៍កសិករ ដើម្បីជ្រើសរើសតំណាង

អាចទៅចូលរួមតស៊ូមតិក្នុងការចចាររកទីផ្សារក៏ដូចជាមួយឈ្មួញដោយធានាការធ្វើស្រែបានផលស្រូវមានគុណភាព តាមស្តង់ដារតម្រូវទីផ្សារ និងធានាលំនឹងតម្លៃក្នុងទីផ្សារផងដែរ ។

តាមការគណនាដែលផ្អែកលើការការគិតគូរនៅក្នុងជំពូកទី២ ត្រង់ចំណុច ១.២.៣ អាចឱ្យយើងរំពឹងទុកអំពីបរិមាណផលស្រូវនាំចេញនាពេលអនាគតក្នុងអំឡុងពេល១៥ខាងមុខដូចខាងក្រោមៈ

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ប្រជាពលរដ្ឋកើនឡើងដល់ **១៩ ២០៩នាក់**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ ដីស្រែកើនដល់ **១៤ ៩៤០ហិកតា**

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ទិន្នផលស្រូវ ៤តោន ក្នុងមួយហិកតា

-ក្នុងរយៈពេល១៥ឆ្នាំខាងមុខ កំណត់ធ្វើស្រែបាន៣ដងក្នុងមួយឆ្នាំ

**-ដូច្នេះក្នុងកំឡុងពេល១៥ឆ្នាំ២០១៧-២០៣២** (ផលិតផលស្រូវទទួលបានក្នុងមួយឆ្នាំជាមធ្យម):

**១៤ ៩៤០ហិកតា x ៤តោន/ហិកតា x ៣ដង =១៧៩ ២៨០តោន/ឆ្នាំ**

-ប្រជាពលរដ្ឋ១នាក់ ត្រូវការអង្ករសម្រាប់ហូបក្នុងមួយឆ្នាំមានចំនួន ១៤៣គីឡូក្រាម ដែលបើគិតជាស្រូវត្រូវការចំនួន **២២៤ គីឡូក្រាម** *(ផ្អែកតាមរបាយការណ៍ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)*

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខត្រូវការបរិមាណស្រូវសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងមួយឆ្នាំជាមធ្យមៈ

១៩ ២០៩នាក់ x ២២៤ គីឡូក្រាម = **៤ ៣០២ ៨១៦គីឡូក្រាម/ឆ្នាំ**

ស្មើប្រហាក់ប្រហែល **៤ ៣០៣តោន/ឆ្នាំ**

-ក្នុងអំឡុងពេល១៥ឆ្នាំខាងមុខ ត្រូវការបរិមាណពូជស្រូវក្នុងមួយឆ្នាំជាមធ្យមៈ

**១៤ ៩៤០ហិកតា x ៣០០គីឡូក្រាម =៤ ៤៨២ ០០០គីឡូក្រាម/ឆ្នាំ**

ស្មើប្រហាក់ប្រហែល **៤ ៤៨២តោន/ឆ្នាំ**

-ដូច្នេះក្នុងកំឡុងពេល១៥ឆ្នាំខាងមុខ ផលិតផលស្រូវទទួលបានសម្រាប់ការនាំចេញក្នុងមួយឆ្នាំជាមធ្យមៈ

**១៧៩ ២៨០តោន/ឆ្នាំ-៤ ៣០៣តោន/ឆ្នាំ -៤ ៤៨២តោន/ឆ្នាំ = ១ ៨៨ ០៦៥តោន/ឆ្នាំ**

-តែបើគិតជាអង្ករវិញអាចនាំចេញបានក្នុងមួយឆ្នាំជាមធ្យមៈ

**១៨៨ ០៦៥តោន/ឆ្នាំ x ៦០% = ១១២ ៨៣៩តោន/ឆ្នាំ**

### ខ. ការគ្រប់គ្រងព្រៃឈើ ជលផល និងធនធានសំខាន់ៗផ្សេងៗទៀត

ដោយឡែកធនធានព្រៃឈើវិញ យើងបានរកឃើញថា នៅក្នុងឃុំចំណាក្រោមមានដីព្រៃល្បោះតិចតួច និងដីគុម្ពោតដែលសមស្របអាចដាំដើមឈើបាន ហើយនឹងដីនៅតាមទីសាធារណៈតាមដងផ្លូវ ប្រឡាយទឹក ទីទួល ទីធ្លាសាលាឃុំ ទីធ្លាសាលារៀនទីធ្លា មណ្ឌលសុខភាព ទីធ្លានៅតាមវត្តអារាម និងនៅតាមលំនៅឋានជាដើម។ល។ ដើម្បីឱ្យមានដើមឈើពណ៌បៃតងនៅពាសពេញទូទាំងឃុំបម្រើផលប្រយោជន៍ ដូចបានលើកឡើងនៅក្នុងជំពូកទី២នៃរបាយការណ៍នេះហើយត្រូវបន្តថែទាំដើមឈើទាំងនោះឱ្យបាននៅគង់វង្ស និងលូតលាស់បានល្អ ។

ទោះបីនៅក្នុងឃុំចំណាក្រោម មិនមានធនធានព្រៃឈើធម្មជាតិច្រើនក៏ដោយក៏ប៉ុន្តែនៅក្នុងឃុំមានសំបូរទៅដោយព្រៃលិចទឹក ដែលជាធនធានជលផលដ៏កម្រ ដែលរាជរដ្ឋាភិបាលបានកំណត់ជាដីការពារជុំវិញបឹងទន្លេសាប ដោយហាមដាច់ខាតដល់ការរំលោភដីព្រៃលិចទឹកទាំងនេះ ដើម្បីរក្សាលំនឹងធម្មជាតិដែលជាជម្រកមច្ឆាជាតិរបបជលសាស្រ្ត ការសាយភាយនៃល្បាប់និងប្រព័ន្ធជីវចម្រុះនៅក្នុងបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ។ ចំណែកធនធានជលផលនៅក្នុងឃុំវិញ បច្ចុប្បន្នមាននៅតាមស្ទឹងស្ទោង បឹង ស្រះទឹក អាងស្តុកទឹក និងប្រឡាយទឹក និងក្នុងស្រែនារដូវវស្សាដែលអាចឱ្យប្រជាពលរដ្ឋក្នុងឃុំអាចទទួលផលជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ ។ តែទៅ

ថ្ងៃអនាគតក៏ត្រូវខិតខំយកចិត្តទុកដាក់ក្នុងការចិញ្ចឹមត្រីថែមទៀតតាមស្រះក្តី បែរក្តី និងតាមបច្ចេកទេសប្រើចង់កៅស៊ូក្តី ដើម្បីបានផលគ្រប់គ្រាន់ផ្តល់ជាប្រភពប្រូតេអ៊ីនសាច់ដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋនៅក្នុងឃុំចំណាក្រោម ។ ចំពោះស្ថានភាពសមស្របក្នុងឃុំគួរចិញ្ចឹមត្រីតាមបែបចិញ្ចឹមក្នុងស្រះខ្នាតតូច ស្រះចិញ្ចឹមត្រីតាមគ្រួសារ និងកសិដ្ឋានចិញ្ចឹមត្រីក្នុងស្រែដែលជាទម្រង់មួយនៃការបង្កើនបរិមាណត្រី ដោយអាចបង្កើនផលិតភាពជលផលតាមប្រពលវប្បកម្ម(តាមវាលស្រែ) ហើយមានប្រយោជន៍ក្នុងការប្រើត្រីសម្រាប់ទប់ទល់សត្វល្អិត និងដង្កូវហ្វូងក្នុងស្រែ ដែលបំផ្លាញផលដំណាំ ដូចបានលើកឡើងជាអនុសាសន៍នៅក្នុងជំពូកទី២នៃរបាយការណ៍នេះផងដែរ ។ ចំណែកធនធានសំខាន់ៗផ្សេងទៀតលើសពីការរៀបរាប់ខាងលើនេះ ពុំមានឃើញគួរកត់សម្គាល់ឡើយ ។

### ៣.៨.២. គម្រោងគាំទ្រចាំបាច់ សម្រាប់គាំទ្រនិរន្តរភាព

ដើម្បីមានមធ្យោបាយនៅក្នុងការធ្វើឱ្យសម្រេចបាននូវការគ្រប់គ្រងប្រព័ន្ធកសិកម្មនិងធនធានសំខាន់ៗសម្រាប់ការគាំទ្រដល់និរន្តរភាពនៃការអភិវឌ្ឍន៍ និងអភិរក្ស ដីធ្លីនិងធនធានធម្មជាតិក្នុងឃុំចាំបាច់ត្រូវបង្កើតឱ្យមានគម្រោងគាំទ្រជាអាទិភាពមួយចំនួនដូចខាងក្រោម៖

-ជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្រ
-ការជួសជុល និងថែរទាំផ្លូវ
-កសាងផ្លូវក្រាលកៅស៊ូ
-បណ្តុះបណ្តាលផលិតជីកំប៉ុស្ត
-បណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ជីគីមី
-បណ្តុះបណ្តាលពីការដាំដំណាំស្រូវ
-តបណ្តាញទឹកស្អាតឱ្យបានដល់គ្រប់ភូមិ
-តបណ្តាញអគ្គិសនីឱ្យបានដល់គ្រប់ភូមិ
-បង្កើតទីលានចាក់សំរាម
-គម្រោងចុះបញ្ជីដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធ
-គម្រោងកៀរដីដោយប្រព័ន្ធឡាស៊ែ
-ស្តារបឹង ស្ទឹង អូរ សាងសង់ចំណាក្រោមជើងក្អែបនិងប្រព័ន្ធធារាសាស្ត្រ
-ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម(ផលិតកម្មដំណាំស្រូវ ) ដល់ប្រជាពលរដ្ឋ
-ដាំដើមតាមមាត់ស្ទឹងបន្ថែមនិងការពារព្រៃមាត់ស្ទឹងដែលមានស្រាប់
-ធ្វើការផ្សព្វផ្សាយពីច្បាប់ជលផលឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ
-បំផុសការចិញ្ចឹមត្រីតាមលក្ខណៈគ្រួសារ
-លែងកូនត្រីចូលក្នុងបឹងធម្មជាតិ
-ជម្រុញភូមិ១ ផលិតផល១
-ពង្រឹងក្រុមផលិតពូជស្រូវ
-ដាក់លូបង្ហូរទឹកតាមមុខផ្ទះនៅជាប់ផ្លូវ
-ដោះស្រាយដីសម្បទានសង្គមកិច្ច
-ជំរុញធ្វើប័ណ្ណក្រីក្រឱ្យដល់ស្ត្រីគ្រប់គ្នា
-ការផ្តល់អាហាររូបត្ថម្ភដល់ស្ត្រី និងកុមារ

-ផ្សព្វផ្សាយពីការចាក់វ៉ាក់សាំងការពារជម្ងឺដល់ស្ត្រីមានផ្ទៃពោះ កុមារ
-ពង្រឹងសេវាថែទាំសុខភាព និងព្យាបាលជម្ងឺជូនដល់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង
-ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ
-ផ្សព្វផ្សាយពីច្បាប់ភូមិបាល និងច្បាប់ បទដ្ឋានគតិយុត្តនានា ជូនដល់ប្រជាពលរដ្ឋ

## ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់២០៣២)

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម ក្នុងឆ្នាំ២០១៧នេះបានឱ្យដឹងថា ជាឃុំមួយក្នុងចំណោមឃុំទាំង១៣ របស់ស្រុកស្ទោងខេត្តកំពង់ធំ មានភូមិចំនួន ១០ និងមានផ្ទៃដីសរុបចំនួន ២៣ ៦២៨ហិកតា ។ នៅក្នុងឆ្នាំ២០១៧ ឃុំចំណាក្រោម មានប្រជាពលរដ្ឋរស់នៅ ៨ ០៧៥នាក់ ក្នុងនោះស្ត្រី ៤ ២៥៨នាក់ គិតជាគ្រួសារមានចំនួន ២ ៨២៨គ្រួសារ ហើយមានដង់ស៊ីតេប្រជាជនមធ្យម ២៣៦នាក់/គ.ម² ។ នៅក្នុងឃុំត្រូវបានបែងចែកជាបីតំបន់ ដោយយោងតាមរបាយការណ៍កៀគ្រប់បរិស្ថាន ដែលតំបន់ទី១ ជាតំបន់វាលទំនាបមធ្យម សម្រាប់ដំណាំចម្រុះ និងលំនៅឋាន និងដីជម្រាលមធ្យមសម្រាប់ដំណាំស្រូវវស្សា និងដំណាំចម្រុះ មានស្រូវប្រាំងតិចតួច ដីតំបន់នេះមានដីជាតិមធ្យម ជាប្រភេទដីជាល្បាយខ្សាច់ពណ៌ក្រហមព្រឿងៗ ដីកណ្តេងពណ៌ខ្មៅ ដីល្បាយខ្សាច់ពណ៌ខ្មៅ ប្រើប្រាស់ទឹកប្រឡាយ ទឹកភ្លៀង ទឹកស្រះ និងទឹកអណ្តូង ។ ចំពោះដីតំបន់ទី២ ជាដីវាលទំនាបទាប សម្រាប់ដំណាំស្រូវវស្សា និងប្រាំងលិចទឹករយៈពេលខ្លីផង និងជាដីជម្រាលជាប្រភេទដីកណ្តេង ពណ៌ខ្មៅ ប្រផេះ ប្រើប្រាស់ទឹកប្រឡយ ទឹកភ្លៀង បឹង អាងស្តុកទឹកនិងទឹកទន្លេសាប ។ ចំណែកដីតំបន់ទី៣ជុំវិញបឹងទន្លេសាបវិញ ជាតំបន់វាលទំនាបទាបនិងជម្រាលទាបសម្រាប់ដំណាំស្រូវប្រាំង និងដីព្រៃលិចទឹករយៈពេលវែង និងមានដីជីជាតិប្រភេទដីកណ្តេងល្បាប់ពណ៌ខ្មៅ ប្រើប្រាស់ការស្រោចស្រពប្រឡាយទឹក ទឹកភ្លៀង បឹង ទឹកទន្លេសាប និងអាងស្តុកទឹក ។

នៅក្នុងឃុំចំណាក្រោម បានផ្តល់នូវមុខរបរសំខាន់ៗដល់ប្រជាពលរដ្ឋភាគច្រើន សម្រាប់ប្រកបរបរកសិកម្ម រហូតដល់ប្រមាណ ៨៧ភាគរយ ស្មើនឹង ៥ ៥៤៧នាក់ មុខរបរសេវាកម្មមាន ១៣ភាគរយ ស្មើនឹង ៨២៨នាក់ និងសិប្បកម្មមិនមាននោះទេ។ ទន្ទឹមនេះឃុំចំណាក្រោមមានទឹកស្ទឹងពីរទៀតឈ្មោះថា ស្ទឹងនាងសល្វាច និងស្ទឹងស្ទោងនៅជាប់ព្រំប្រទល់ជាមួយឃុំប្រឡាយ ដែលជាប្រភពទឹកមួយសម្រាប់ចែកចាយទឹកនិងនាំទឹកសម្រាប់ធ្វើការស្រោចស្រពតាមរយៈអូរ និងប្រឡាយនៅក្នុងពេលរដូវវស្សា ដែលមានបានបង្ហាញឲ្យឃើញថាបច្ចុប្បន្ននេះ នៅក្នុងឃុំចំណាក្រោម មានប្រឡាយសរុបចំនួន ៣១ខ្សែ ប្រវែង ៦៧ ៧៦៩,៨៣ ម៉ែត្រ ប្រឡាយមេមាន ៣ខ្សែ ប្រវែង ៦ ២២១,៣៧ម៉ែត្រ ប្រឡាយរងមាន ៧ខ្សែ ប្រវែង ១៦ ៥៤៩,៨៦ម៉ែត្រ ប្រឡាយតូចមានចំនួន ២១ខ្សែ ប្រវែង ៤៤ ៩៩៨,៦០ម៉ែត្រ និងទ្វារស្ទាក់ទឹកចំនួន ៦កន្លែង ដែលអាចនាំទឹក ដើម្បីមកស្រោចស្រពដីស្រែពេលជួបគ្រោះរាំងស្ងួតនៅរដូវវស្សា តាមរយៈប្រឡាយទាំងនេះ ដែលជាចំនួនច្រើនល្មមគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់ស្រោចស្រពដីស្រែក្នុងឃុំបាន ។ បន្ថែមពីលើនេះ ឃុំចំណាក្រោមមានផ្លូវជាតិលេខ៦ដែលជាអ័ក្សច្រកផ្លូវសេដ្ឋកិច្ចភ្ជាប់ពីពីតំបន់ភូមិសាស្ត្រខេត្តសៀមរាប កំពង់ធំនិងភ្នំពេញ ជាការផ្តល់ឱកាសឱ្យឃុំចំណាក្រោម អាចទាញយកប្រយោជន៍ពីការអភិវឌ្ឍន៍តាមផ្លូវនេះទៅថ្ងៃអនាគតបាន ។ ទន្ទឹមនឹងនេះ ឃុំនៅមានផ្លូវផ្សេងទៀតគ្រប់គ្រាន់អាចភ្ជាប់ទំនាក់ទំនងពីភូមិមួយទៅភូមិមួយនៅក្នុងឃុំនិងអាចភ្ជាប់ទំនាក់ទំនងទៅឃុំនិងស្រុកផ្សេងរួមទាំងទីរួមខេត្តកំពង់ធំ និងខេត្តសៀមរាបបានដោយងាយ ។ ចំពោះកំណើនប្រជាជនវិញបានរកឃើញថា នៅក្នុងរយៈពេល១៥ឆ្នាំទៅមុខរហូតដល់ឆ្នាំ២០៣២ នឹងមានប្រជាជនកើនឡើងរហូតដល់ ១៩ ២០៩នាក់ ដែលនឹងត្រូវយកចិត្តទុកដាក់គិតគូររកដំណោះស្រាយអំពីការប្រើប្រាស់ដី ដើម្បីឆ្លើយតបបានទៅនឹងតម្រូវការរបស់ប្រជាជន ។ ទន្ទឹមនេះក៏បានរកឃើញអំពីបញ្ហាប្រឈមមួយចំនួនលើសកម្មភាពការអភិវឌ្ឍន៍ឃុំចំណាក្រោមបច្ចុប្បន្នផងដែរ ដូចជា ការធ្វើស្រែដែលមានសក្តានុពលក្នុងការអភិវឌ្ឍន៍ឃុំមិនទាន់ទទួលផលស្រូវសមស្របអស់ពីលទ្ធភាពនៅឡើយ ដោយសារ

ដីស្រែទាំងនេះកាន់តែខ្សត់ជីជាតិ ខ្វះទឹកស្រោចស្រពសម្រាប់ផ្គត់ផ្គង់ដល់ការធ្វើស្រែបង្កើនរដូវ ខ្វះចំណេះដឹងអំពីបច្ចេកទេសនៃការដាំដុះ ខ្វះចំណេះដឹងពីបច្ចេកទេសការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ប្រព័ន្ធប្រឡាយដែលមានស្រាប់បានរាក់ ខ្វះកម្លាំងពលកម្មដោយសារចំណាកស្រុកច្រើនបាត់កម្លាំងពលកម្មជិតពាក់កណ្ដាលនៃកម្លាំងពលកម្មដែលមាន និងតម្លៃកសិផលមិនមានស្ថេរភាពដោយឈ្មួញជាអ្នកកំណត់តម្លៃ។ល។ ទន្ទឹមការរកឃើញបញ្ហាមួយចំនួនលើសកម្មភាពអភិវឌ្ឍន៍ឃុំ ក៏បានរកឃើញថា ការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោមក្នុងបច្ចុប្បន្ននេះបានចំទិសដៅនិងមានភាពសមស្រប ដូចជា ការប្រើប្រាស់ដីសម្រាប់ដីលំនៅឋានភូមិ កសិកម្ម ប្រព័ន្ធផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រជាដើម ដែលទៅថ្ងៃអនាគតក៏នៅតែរក្សាមុខងារប្រើប្រាស់ដីទាំងនោះឱ្យនៅដដែល ដោយគ្រាន់តែមានការកែប្រែតិចតួចទៅតាមតម្រូវការដីចាំបាច់ប្រមាណ ១២,២១ ហិកតា ពីដីស្រែទៅជាដីលំនៅឋាន សម្រាប់ការពង្រីកដីលំនៅឋានស្របទៅនឹងកំណើនប្រជាសាស្ត្រ និងភាពរីកចម្រើននៅក្នុងឃុំប៉ុណ្ណោះ។ បន្ថែមពីលើនេះក៏បានរកឃើញវិធីដោះស្រាយបញ្ហាផ្សេងៗទៀតផងដែរសម្រាប់អនាគតដូចជាត្រូវសាងសង់បន្ទប់រៀនបន្ថែម ពង្រឹងការផ្ដល់សេវាសុខាភិបាលឱ្យបានប្រសើរឡើង ជំរុញឱ្យប្រជាពលរដ្ឋហូបទឹកស្អាត និងប្រើប្រាស់បង្គន់អនាម័យ ជួសជុលផ្លូវ ស្ពារប្រឡាយទឹក ដាំដើមឈើនៅតាមទីសាធារណៈ និងជំរុញការចិញ្ចឹមត្រីនៅក្នុងស្រែ។ល។ ចំណែកដីស្រែដែលមិនអាចពង្រីកបាន តែត្រូវបានកាត់បន្ថយតិចតួចដើម្បីដោះស្រាយទៅនឹងកំណើនប្រជាជនសម្រាប់សាងសង់លំនៅឋាន ដូច្នេះត្រូវពង្រឹងការធ្វើស្រែឱ្យបាន២ទៅ៣ដងនៅក្នុងមួយឆ្នាំ និងធ្វើស្រែតាមបែបប្រពលវប្បកម្ម ដើម្បីបង្កើនទិន្នផលស្រូវឱ្យបានខ្ពស់អស់សក្ដានុពល ដែលមានសម្រាប់ផ្គត់ផ្គង់ការហូបចុក និងនាំស្រូវចេញបានចំនួន **១៨៨ ០៦៥តោន/ឆ្នាំ** ដើម្បីជួយផ្គត់ផ្គង់ទៅដល់ជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងឃុំឱ្យបានកាន់តែប្រសើរឡើង សមស្របទៅនឹងកំណើនប្រជាពលរដ្ឋព្រមទាំងជួយជំរុញកំណើនសេដ្ឋកិច្ចក្នុងឃុំ ។ ការរកឃើញភាពសមស្របនិងជម្រើសនៃការប្រើប្រាស់ដីនៅក្នុងឃុំ នាពេលអនាគតនេះបានមកពីការវាយតម្លៃដ៏ត្រឹមត្រូវដោយផ្អែកលធនធាន រយៈកម្ពស់ដី ទីជម្រាល ធនធានទឹក ដី ការកាន់កាប់ដី និងសក្ដានុពលនៃការប្រើប្រាស់ដីនៅក្នុងឃុំនេះជាដើម ដើម្បីធានាថា ការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោមទៅអនាគតប្រកបដោយចីរភាព និងសមធម៌ ។

ដូច្នេះដើម្បីសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីនៅក្នុងឃុំស្របតាមស្ថានភាពដីជាក់ស្ដែង និងសក្ដានុពលនៃធម្មជាតិ សម្រាប់ការគាំទ្រកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមប្រកបទៅដោយចីរភាព និងសមធម៌ រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ នាពេលអនាគតដូចបានរកឃើញមានចែងលម្អិតនៅក្នុងរបាយការណ៍បច្ចេកទេសនេះរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាឃុំ ដែលជាតំណាងប្រជាពលរដ្ឋនៅក្នុងឃុំ ហើយមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅ នៅក្នុងឃុំចំណាក្រោម ត្រូវខិតខំអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួច ដោយបញ្ជ្រាបទៅនិងផែនការអភិវឌ្ឍន៍ឃុំឱ្យបានប្រកបដោយប្រសិទ្ធិភាពខ្ពស់បំផុត ដើម្បីធានាភាពជោគជ័យនៃផែនការនេះ ៕

លេខ៖.៥៣៣/២០.....................

បានពិនិត្យ និង សូមគោរពជូន

**លោកអភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និងនគរូបនីយកម្មស្រុកស្តោង មេត្តាពិនិត្យ និង សម្រេច។**

ថ្ងៃ......ចន្ទ ៤កើត......ខែ ស្រាពណ៍ ឆ្នាំ ...ជូត ទោស័ក.........ព.ស. ២៥៦៤

ចំណាក្រោម ថ្ងៃទី...១៣.....ខែ.....សីហា......ឆ្នាំ២០២០

**មេឃុំចំណាក្រោម**

ហេង_ប៊ុនហ៊ី

លេខ÷....០២៣/២០...................

បានពិនិត្យ និង សូមគោរពជូន

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និង ជាប្រធានគណៈកម្មាធិការ**

**រៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ មេត្តពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់ ។**

ថ្ងៃ.....ពុធ ៦កើត.............ខែស្រាពណ៍ ឆ្នាំ....ជូត ទោស័ក.........ព.ស. ២៥៦៤

ស្តោង ថ្ងៃទី...១០...............ខែ...សីហា.....ឆ្នាំ ២០២០

**អភិបាលនៃគណៈអភិបាលស្រុក និង ជាប្រធាន**

**គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកស្តោង**

**ណែត សារី**

លេខ៖ ៥៤៥៧/២០២១

បានឃើញ និងឯកភាពសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

ថ្ងៃ ព្រហស្បតិ៍ ៦កើត ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

កំពង់ធំ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០២១

**អភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ**

ស៊ុខ_ល៊ុ

# ឯកសារឧបសម្ព័ន្ធ

# ផែនទីហេដ្ឋារចនាសម្ព័ន្ធ ឃុំចំណាក្រោម



# ផែនទីប្រព័ន្ធធារាសាស្ត្រ ឃុំចំណាក្រោម



# ផែនទីប្រើប្រាស់ដីសាមញ្ញ ឃុំចំណាក្រោម



# ផែនទីគម្រោងវិនិយោគ ឃុំចំណាក្រោម



# ឯកសារឧបសម្ព័ន្ធ



សកម្មភាពក្រុមការងារចូលរួមប្រជុំទទួលការណែនាំពីនីតិវិធីរៀបចំផែនការប្រើប្រាស់ដីថ្នាក់ឃុំ ពីប្រធានគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន



សកម្មភាពក្រុមការងារចុះប្រមូលទិន្នន័យពីអាជ្ញាធរដែនដី និងមន្ត្រីជំនាញថ្នាក់ស្រុក ខេត្ត



កិច្ចប្រជុំពិភាក្សាអំពីផែនទីប្រើប្រាស់ដីបច្ចុប្បន្នឃុំចំណាក្រោម





សកម្មភាពក្រុមការងារចុះទីវាលស្រង់ទិន្នន័យបំពេញបន្ថែមលើ
ផែនទីប្រើប្រាស់ដីបច្ចុប្បន្នដែលមានស្រាប់ឃុំចំណាក្រោម





សកម្មភាពចូលរួមត្រួតពិនិត្យ ណែនាំ ការអនុវត្តគម្រោងរបស់អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិ (NIO)





កិច្ចប្រជុំក្រុមប្រឹក្សាឃុំចំណាក្រោម ដើម្បីពិនិត្យ និងឯកភាពទៅលើ
សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម





កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មស្រុកស្ទោង ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម





កិច្ចប្រជុំគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និងឯកភាពទៅលើ សេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកស្ទោង
ក្រុមប្រឹក្សាឃុំចំណាក្រោម

ថ្ងៃ..................ខែ..........ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ចំណាក្រោមថ្ងៃទី...១២...ខែ..តុលា....ឆ្នាំ២០២០..

**សេចក្តីជូនដំណឹង**
**ស្តីពីការបិទផ្សាយជាសាធារណៈផែនការប្រើប្រាស់ដីអនាគតឃុំចំណាក្រោម**

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB )។
- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd ។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។
- តម្រូវការចាំបាច់នៃការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

ដើម្បីបានជម្រាបជូនក្នុងសេចក្តីយោងខាងលើ និងស្របតាមការរៀបចំផែនការប្រើប្រាស់ដី និងលទ្ធផលការងារ ដែលសម្រេចបានទៅតាមនីតិវិធីនាពេលកន្លងមកក្រុមប្រឹក្សាឃុំចំណាក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ សូមគោរពជម្រាបជូនដល់គ្រប់ស្ថាប័ន អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់មេត្តាជ្រាបថា៖ នៅថ្ងៃទី.១២..ខែ.តុលា.....ឆ្នាំ២០២០.. ដល់ថ្ងៃទី២៥..ខែ...វិច្ឆិកា..ឆ្នាំ២០២០..ឃុំចំណាក្រោម ធ្វើការរៀបចំបិទផ្សាយជាសាធារណៈនូវឯកសារ និងផែនការប្រើប្រាស់ដីអនាគត ដែលសម្រេចបាន នៅទីតាំងសាលាឃុំខាងលើ ដើម្បីធ្វើការពិនិត្យ កែសម្រួល និងផ្តល់យោបល់។

អាស្រ័យហេតុនេះ សូមបងប្អូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ មេត្តាជួយផ្សព្វផ្សាយ និងចូលរួមពិនិត្យផ្តល់យោបល់អោយបានកុះករ កុំបីអាក់ខានឡើយ ។

សូមបងប្អូនជនរួមជាតិ មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ ។

ប្រធានក្រុមប្រឹក្សាឃុំ និងជា
មេឃុំចំណាក្រោម
(ហត្ថលេខា និងត្រា)
ចេង_ប៊ុនធី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលស្រុកស្ទោង
ក្រុមប្រឹក្សាឃុំ ចំណាក្រោម

**របាយការណ៍ការបូកសរុប**
**លទ្ធផល នៃការបិទផ្សាយជាសាធារណៈ នូវឯកសារផែនទី និង**
**សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចំណាក្រោម**

យោង: - កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៣ រវាង រាជរដ្ឋាភិបាលកម្ពុជានិងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។
- កិច្ចសន្យាលេខ CON-LUP/RICE-SDP/CLUP/MUMUPC/CS/ ០១ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៧ រវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន SBK Research & Development Co.,Ltd។
- អនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៩ ស្តីពីនិតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំចំណាក្រោម បានបិទផ្សាយជាសាធារណៈនៅទីតាំង សាលាឃុំចំណាក្រោម នូវឯកសារផែនទី និងសៀវភៅព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម (បានប្រជុំអនុម័តថ្នាក់ស្រុកស្ទោងរួចរាល់ជាស្ថាពរ) ចាប់ពីថ្ងៃទី.១២.ខែ.តុលា.....ឆ្នាំ ២០២០ ដល់ថ្ងៃទី..២៥...ខែ....វិច្ឆិកា ឆ្នាំ ២០២០ មានរយៈពេល ៤៥ ថ្ងៃជាលទ្ធផលមានដូចខាងក្រោម៖

**១. ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ ចំណាក្រោម**

- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីលម្អិតបច្ចុប្បន្ន មានទំហំជាខ្នាត A0
- បានធ្វើការបិទផ្សាយផែនទីប្រើប្រាស់ដីអនាគតសម្រាប់រយៈពេល ១៥ឆ្នាំ ២០១៧ ដល់ ២០៣២ មានទំហំជាខ្នាត A0
- **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**

**២. សៀវភៅផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចំណាក្រោម**

- ជំពូក ១ ៖ ព័ត៌មានស្តីពី ស្ថានភាពឃុំចំណាក្រោម
  - ចាប់ពី ១.១. ស្ថានភាពឃុំ ១.១.១. ទីតាំងរដ្ឋបាលឃុំ រហូតដល់ ១.៤. ទីផ្សារ និង ខ្សែសង្វាក់ផលិតផល ១.៤.៣. ឧបសគ្គ និង ឱកាស។
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**
- ជំពូក ២ ៖ ការវិភាគតម្រូវការ សក្តានុពល និង ឧបសគ្គសម្រាប់អនាគត
  - ចាប់ពី ២.១. តម្រូវការសម្រាប់អនាគត់ ២.១.១. ផែនការអភិវឌ្ឍន៍ឃុំ រហូតដល់ ២.៥. បញ្ហា មូលហេតុ និង ដំណោះស្រាយ។
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**
- ជំពូក ៣ ៖ ផែនការប្រើប្រាស់ដីសម្រាប់ពេលអនាគត ឆ្នាំ២០១៧ ដល់ ២០៣២
  - ចាប់ពី ៣.១. តម្រូវការ ស្ថានភាព និង សក្តានុពលជាក់ស្តែង ៣.១.១. តម្រូវការដីទៅតាមប្រភេទ រហូតដល់ ៣.៥. សេចក្តីសន្និដ្ឋានរួម លើផែនការប្រើប្រាស់ដីអនាគត (២០១៧ ដល់ ២០៣២)
  - **ទំនាស់ និង ការតវ៉ាក្នុងកំឡុងពេលបិទផ្សាយ : គ្មាន**

- **ការវាយតម្លៃ** : ផ្អែកតាមឯកសារភស្តុតាង និងទិន្នន័យជាក់ស្តែង ដែលប្រមូលបាន លទ្ធផលនៃការបិទផ្សាយសាធារណៈនូវឯកសារ ផែនទី និង សៀវភៅព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចំណាក្រោម សម្រាប់ឆ្នាំ ២០១៧ ដល់ ២០៣២ ជាយោបល់គួរដាក់ជូនគណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មខេត្តកំពង់ធំ ដើម្បីពិនិត្យ និង សម្រេចជាខ្លង់ខ្ពស់។

ថ្ងៃ..................ខែ..........ឆ្នាំ..................ស័ក ព.ស. ២៥៦៤
ចំណាក្រោម ថ្ងៃទី..២៥..ខែ.វិច្ឆិកា.....ឆ្នាំ ២០២០
ប្រធានក្រុមប្រឹក្សាឃុំ និងជា
មេឃុំចំណាក្រោម
(ហត្ថលេខា និងត្រា)
ចេង_ប៊ុនធី

សកម្មភាពផ្សព្វផ្សាយជាសាធារណៈសេចក្តីព្រាងផែនការប្រើប្រាស់ដីនៅក្នុងឃុំចំណាក្រោម

# ឯកសារយោង

# ឯកសារយោង

១. របាយការណ៍នៃការវិភាគគ្បេត្រ-បរិស្ថានរបស់ឃុំចំណាក្រោមឆ្នាំ ២០១៧
២. របាយការណ៍ប្រចាំឆ្នាំ ២០១៦ ឬ ២០១៧ របស់វិស័យអាទិភាពនានា
៣. ឯកសារព័ត៌មានស្ថានភាពឃុំស្តីពីសេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ ២០១៥ ២០១៦ និង២០១៧
៤. ផែនការអភិវឌ្ឍន៍៥ឆ្នាំ របស់ឃុំចំណាក្រោម
៥. ទិន្នន័យឃុំ និងភូមិឆ្នាំ២០១៦ និង២០១៧ ពីមន្ទីរផែនការខេត្តកំពង់ធំ
៦. សៀវភៅផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងឃុំ ឆ្នាំ ២០១៧
៧. គោលការណ៍ និតិវិធី និងឧបករណ៍នៃការកសាងផែនការប្រើប្រាស់ដីក្នុងឃុំចំណាក្រោម
៨. ទិន្នន័យឃុំ ឆ្នាំ២០១៨ ពីក្រុមប្រឹក្សាឃុំចំណាក្រោម
៩. ផែនការអភិវឌ្ឍន៍ស្រុករយៈពេលប្រាំឆ្នាំ (២០១៨-២០២២)របស់ស្រុកស្ទោង ខេត្តកំពង់ធំ
១០. អនុក្រឹត្យស្តីពីការកំណត់ដែនព្រៃលិចទឹក ៦៤៧,៤០៦ហិកតា ស្ថិតនៅក្នុងខេត្តទាំង៦ជុំវិញបឹងទន្លេសាប (កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប)
១១. អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ៨៨.អនក្រ.បក ស្តីពីការបង្កើតតំបន់ការពារទេសភាពទំនាបខាងជើងទន្លេសាប ។